គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
Pour le Cambodge

*1990-2010*
*2 Decades of*
*NGO Solidarity*
*and Cooperation*

# ការពង្រីកសកម្មភាពរ៉ែ និងសិទ្ធិជនជាតិដើមភាគតិច
# ក្នុងខេត្ត មណ្ឌលគិរី
## ករណីសិក្សានៅភូមិហ្គាទី ស្រុកកែវសីមា និង ភូមិពូរ៉ាប៉ែត ស្រុកពេជ្រាដា




គំរោង វិភាគបញ្ហាអភិវឌ្ឍន៍
សិក្ខាកាម ( ជំនាន់២០ ) និង ក្រុម



ខែតុលា ឆ្នាំ២០១០

# ការពង្រីកសកម្មភាពរ៉ែ និង សិទ្ធិជនជាតិដើមភាគតិច ក្នុងខេត្តមណ្ឌលគិរី

## ករណីសិក្សានៅភូមិឃ្លាទី ស្រុកកែវសីមា និងភូមិពូរ៉ាឃ៉ែត ស្រុកពេជ្រាដា

គម្រោងវិភាគបញ្ហាអភិវឌ្ឍន៍
សិក្ខាកាម ( ជំនាន់ ២០) និង ក្រុម

ខែតុលា ឆ្នាំ២០១០

# មាតិកាអត្ថបទ


សេចក្តីថ្លែងអំណរគុណ.......... iii

មូលន័យសង្ខេប .......... iv

**សេចក្តីផ្តើម** .......... 1

- សន្និសីទអន្តរជាតិស្តីពីរ៉ែនៅរាជធានីភ្នំពេញ ខែឧសភា ឆ្នាំ២០១០ .......... 4
- របកគំហើញធនធានរ៉ែ: តើជាប្រយោជន៍ ឬក៏ជាឧបសគ្គសម្រាប់ប្រទេសកម្ពុជា? .......... 10
- គោលបំណងនៃការស្រាវជ្រាវ .......... 10
- វិធីសាស្ត្រនៃការស្រាវជ្រាវ .......... 11

**ការពង្រីកឧស្សាហកម្មរ៉ែខេត្តមណ្ឌលគីរីនិងភូមិសិក្សាស្រាវជ្រាវ** .......... 13

- ការពង្រីកសកម្មភាពរ៉ែទ្រង់ទ្រាយតូច .......... 13
- ការពង្រីកសកម្មភាពរ៉ែទ្រង់ទ្រាយធំរបស់ក្រុមហ៊ុន.......... 16
- ច្បាប់គ្រប់គ្រងរ៉ែនៅកម្ពុជា.......... 24
- ការពង្រីកសកម្មភាពរ៉ែនៅក្នុងភូមិ នៃខេត្តមណ្ឌលគីរី .......... 33
- ការពង្រីកសកម្មភាពរ៉ែ នៅភូមិហ្គាទី និងភូមិពូរ៉ាប៉ែត .......... 35

**សិទ្ធិជនជាតិជនជាតិដើមភាគតិច និងប្រតិបត្តិការធនធានរ៉ែ**.......... 43

- សិទ្ធិជនជាតិដើមភាគតិច ដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិ.......... 43
- សិទ្ធិជនជាតិដើមភាគតិចនិងការធ្វើអាជីវកម្មរ៉ែដោយមានទំនួលខុសត្រូវ .......... 46
- ក្របខណ្ឌច្បាប់ស្តីពី សិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា .......... 52
- ការចូលរួមជាមួយក្រុមហ៊ុនរ៉ែរបស់អ្នកភូមិហ្គាទី និងពូរ៉ាប៉ែត .......... 55

**សុវត្ថិភាពនៃការចិញ្ចឹមជីវិតរបស់អ្នកភូមិហ្គាទីនិង ភូមិពូរ៉ាប៉ែត ស្ថិតក្រោមការគំរាមកំហែងពីការរុករកនិងធ្វើអាជីវកម្មរ៉ែ** .......... 61

- ចំណាត់ថ្នាក់ប្រភពនៃការចិញ្ចឹមជីវិត .......... 61
- យុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិតផ្សេងៗ .......... 63
- ផលប៉ះពាល់ពីសកម្មភាពរ៉ែមកលើការចិញ្ចឹមជីវិតរបស់អ្នកភូមិ .......... 67
- រ៉ែ ជាជម្រើសនៃប្រភពចិញ្ចឹមជីវិត .......... 68

**សេចក្តីសន្និដ្ឋាន** .......... 71

**អនុសាសន៍សម្រាប់គោលនយោបាយ** .......... 77

ឧបសម្ព័ន្ធ១: អ្នកស្រាវជ្រាវជាសិក្ខាកាម និងក្រុមអេឌីអាយ .......... 78

បញ្ជីឯកសារស្រាវជ្រាវកន្លងមករបស់គម្រោងអេឌីអាយ .......... 79

# សេចក្ដីថ្លែងអំណរគុណ

សិក្ខាកាមអ្នកស្រាវជ្រាវនៃគម្រោងវិភាគបញ្ហាអភិវឌ្ឍន៍(ADI)និងក្រុមអ្នកបណ្ដុះបណ្ដាលសូមសំដែងនូវការដឹងគុណចំពោះជនជាតិដើមភាគតិចព្នងនៅភូមិហ្គាទី និងភូមិពូរ៉ាប៉ែតក្នុងខេត្តមណ្ឌលគីរីដែលបានផ្ដល់ការចែករំលែក នូវបទពិសោធន៍ក្នុងការទំនាក់ទំនងជាមួយក្រុមហ៊ុនរ៉ែកន្លងមក។ ក្រុមអ្នកស្រាវជ្រាវ សូមថ្លែងអំណរគុណផងដែរ ដល់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីនៅក្នុងខេត្តមណ្ឌលគីរីដែលបានចូលរួមសហការក្នុងការសិក្សាស្រាវជ្រាវនេះ។ សូមអរគុណដល់លោក ទៀន ហ៊ានតាង និង លោក វ៉ាំង សរិទ្ធ មកពីអង្គការអភិវឌ្ឍន៍និងភាពជាដៃគូក្នុងសកម្មភាព (DPA) ដែលបានជួយជ្រោមជ្រែងនៅពេលចុះធ្វើការសិក្សាស្រាវជ្រាវនៅភូមិហ្គាទី ក្នុងស្រុកកែវសីមា។ ដូចគ្នានេះសូមអរគុណដល់លោក ឯម សុភ័ក្ត្រ មកពីមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) និង លោក អ៊ឹម នឿន មកពីអង្គការ WWF ដែលបានជួយសម្រួលនៅពេលចុះសិក្សាស្រាវជ្រាវនៅភូមិពូរ៉ាប៉ែត ស្រុកពេជ្រាដា និងអរគុណអ្នកជួយរៀបចំលើការងារភស្តុភាផងដែរ។ លោក ម៉ម សម្បត្តិ នាយកប្រតិបត្តិនៃអង្គការ DPA និង ជាអតីតនាយកគណៈកម្មាធិការប្រតិបត្តិនៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) លើកទឹកចិត្តដល់គម្រោង ADI ក្នុងការធ្វើការសិក្សាស្រាវជ្រាវនេះ និងជម្រុញក្រុមអ្នកស្រាវជ្រាវ ដោយឆន្ទៈលើកកម្ពស់សកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវ។ លោក Mark Grimsditch មន្ត្រីផ្នែកច្បាប់មកពី ស្ថានទៅកាន់សន្តិភាពកម្ពុជា ដែលបានផ្ដល់គំនិតដ៏មានតម្លៃលើផ្នែកច្បាប់គ្រប់គ្រងរ៉ែនៅកម្ពុជា និងផ្ដល់ជាយោបល់ លើរបាយការណ៍ព្រាង។ លោក សំ ចាន់ធី មកពីវិទ្យាស្ថាន បរិស្ថានស្តុកខុម-ការិយាល័យអាស៊ី នៅប្រទេសថៃ ដែលផ្ដល់ជាយោបល់លើរបាយការណ៍ព្រាងដំបូង។ សូមអរគុណផងដែរដល់ លោក ឡាវ ប៊ុននិទ្ធី ការិយាល័យតំបន់អាស៊ីបូព៌ានៃអង្គការអុកហ្វាមអាមេរិក ដែល បានផ្ដល់ជាឯកសារពាក់ព័ន្ធ។ អ្នកសិក្សាស្រាវជ្រាវសូមសំដែងនូវការដឹងគុណ ចំពោះការជ្រោមជ្រែងពីអស់លោកទាំងអស់។ ការបកស្រាយដែលធ្វើឡើងនៅក្នុងរបាយការណ៍នេះ គឺជាការទទួលខុសត្រូវរបស់អ្នកស្រាវជ្រាវប៉ុណ្ណោះ។

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវរបស់គម្រោង ADI គឺដើម្បីលើកកម្ពស់ចំណេះដឹង អំពីបញ្ហាដែលទាក់ទងទៅនឹងការពង្រីកសកម្មភាពរ៉ែនិងសិទ្ធជនជាតិដើមភាគតិច ក្នុងខេត្តមណ្ឌលគិរី។ ការសិក្សាស្រាវជ្រាវធ្វើឡើងនៅខែឧសភា ឆ្នាំ២០០៩ ដោយប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ និងបរិមាណវិស័យ។ ការអង្កេតដោយប្រើកម្រងសំនួរ សំភាសន៍ទៅកាន់គ្រួសារជនជាតិព្នង ចំនួន ៣២ គ្រួសារ នៅភូមិហ្គាទី ស្រុកកែវសីមា និង ៣៩ គ្រួសារ នៅភូមិពូរ៉ាប៉ែត ក្នុងស្រុកពេជ្រាដា។ ស្របពេលជាមួយគ្នានោះដែរ ក៏មានការសំភាសន៍ជាមួយបុគ្គលសំខាន់ ៧ ដូចជា ថ្នាក់ដឹកនាំភូមិ អ្នកភូមិ អាជ្ញាធរឃុំ និង មន្ត្រីថ្នាក់ខេត្តជាដើម។ ការសិក្សាស្រាវជ្រាវ ក៏បានបញ្ចូលផងដែរនូវ ឯកសារច្បាប់ និង ប្រភពឯកសារផ្សេងៗ យ៉ាងច្រើនសន្ធឹកសន្ធាប់។

ជនជាតិព្នងនៅភូមិហ្គាទី និង ពូរ៉ាប៉ែត មិនបានផ្តល់នូវ ការយល់ព្រមដោយសេរី និងប្រាប់ឱ្យដឹងជាមុននៅពេលដែលមានប្រតិបត្តិការរ៉ែនៅក្នុងភូមិរបស់ពួកគាត់ទេ។ មានតែអ្នកភូមិហ្គាទីខ្លះប៉ុណ្ណោះ ដែលត្រូវបានទទួលព័ត៌មានអំពីសកម្មភាពរ៉ែ ប៉ុន្តែព័ត៌មានដែលបានពួកគាត់បានទទួលនោះ គឺក្រោយពេលដែលក្រុមហ៊ុនបានមកដល់ និង បានដំណើរការរករ៉ែនៅក្នុងភូមិ។ រីឯ អ្នកភូមិពូរ៉ាប៉ែតវិញ មិនត្រូវបានទទួលព័ត៌មានអំពីសកម្មភាពរ៉ែ ទាំងមុននិងក្រោយពេល ក្រុមហ៊ុនចាប់ផ្តើមប្រតិបត្តិការរករ៉ែនៅភូមិ។ ទោះបីស្ថិតក្នុងដំណាក់កាលដំបូងនៃសិក្សារុករករ៉ែក៏ដោយ តាមរយៈការអង្កេតតាមគ្រួសារ នៅភូមិទាំងពីរបានបង្ហាញអំពីផលប៉ះពាល់ច្រើនពីសកម្មភាពរ៉ែដូចជា ផលពីការបរបាញ់និងរកសត្វព្រៃមានការថយចុះ ត្រីដែលអ្នកភូមិរកបានក៏ថយចុះ ការថយចុះនូវផលិតផលព្រៃឈើ បន្លែ និងផ្លែឈើ ដែលធ្លាប់ប្រមូលបាន ហើយថែមទាំងមានការបំផ្លាញដើមជ័រច្បោះទៀតផង។ ក្នុងពេលនោះ សកម្មភាពរុករករ៉ែមិនបានផ្តល់នូវជម្រើសការងារផ្សេងៗ ដែលមានប្រាក់កម្រៃសមរម្យសម្រាប់អ្នករស់នៅក្នុងតំបន់ឡើយ។

ច្បាប់រ៉ែដែលមានតាំងពីឆ្នាំ ២០០១ មិនបានផ្តល់នូវក្របខណ្ឌគ្រប់គ្រាន់សម្រាប់ជាដំណោះស្រាយដែលមានទំនួលខុសត្រូវលើវិស័យរ៉ែនៅក្នុងតំបន់ជនជាតិដើមភាគតិចទេ ដូច្នេះក្របខណ្ឌច្បាប់ជាតិដែលមានលក្ខណៈទូលំទូលាយមួយ គួរតែត្រូវបានរៀបចំឡើង និង ជម្រុញការអនុវត្ត មុនពេលដែលក្រុមហ៊ុនរ៉ែជាច្រើនធ្វើការស្រាវជ្រាវរុករក និង ធ្វើអាជីវកម្មរ៉ែទ្រង់ទ្រាយធំនៅក្នុងតំបន់ជនជាតិដើមភាគតិច។ ជាងនេះទៅទៀតគេមិនត្រូវរួញរាក្នុងការទទួលស្គាល់ និង ការការពារសិទ្ធិជនជាតិដើមភាគតិច ព្រោះថានេះគឺជាគោលការណ៍ដ៏ប្រសើរបំផុត នៃអាជីវកម្មរ៉ែដែលមានទំនួលខុសត្រូវ។

# សេចក្តីផ្តើម

តាំងពីពាក់កណ្តាលទី២នៃសតវត្សរ៍ទី ១៩ មក ធនធានរ៉ែនៅប្រទេសកម្ពុជាត្រូវបានកំណត់ ដោយភូគព្ភវិទូជនជាតិបារាំង និង ចិន [១]។ រ៉ែដែលគេដឹងថាមានកាលពីដំបូង គឺរ៉ែបុកស៊ីដ ថ្មកាបោន ត្បូង មាស ម៉ង់ហ្គាណែស្ស ផូស្វាត អំបិល ស៊ីលីកា និង ពេជ្រថៃ។ បន្ទាប់មកទៀត មានរ៉ែផ្សេងៗទៀត ត្រូវបានរកឃើញដូចជាក្រូម ស្ពាន់ ដែក ថ្មកំបោរ នីកែល និង តង់ស្តែង [២]។ រហូតដល់សតវត្សរ៍ទី ២១ ធនធានរ៉ែទាំងនេះ ជារួមមិនត្រូវបានគេរុករក និង ធ្វើអាជីវកម្មទេ ដោយសារមានសង្គ្រាមរាប់ទសវត្សរ៍ និង កង្វះទុនវិនិយោគ។ ទើបតែមកដល់ពេលថ្មីៗនេះ មានក្រុមហ៊ុនវិនិយោគអន្តរជាតិធំៗ បានមកធ្វើការវិនិយោគយ៉ាងច្រើន លើផ្នែកឧស្សាហកម្មរ៉ែ ដែលទើបកើតឡើងក្នុងប្រទេសកម្ពុជា។ គួរកត់សំគាល់ថា ការវិនិយោគសម្រាប់ គម្រោងរ៉ែដែលយល់ព្រមដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានកើនពី ១៨១ លានដុល្លា ក្នុងឆ្នាំ ២០០៥ ដល់ ៤០៣ លានដុល្លា ក្នុងឆ្នាំ២០០៦ [៣]។ ធនធានរ៉ែ ព្រមជាមួយប្រេង និងឧស្ម័ន នៅពេលនេះត្រូវបានរាជរដ្ឋាភិបាលចាត់ទុកថា អាចផ្តល់ចំណូលយ៉ាងខ្ពស់។

ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម សុខ អាន បានថ្លែងនៅក្នុងសុន្ទរកថា កាលពីខែវិច្ឆិកា ឆ្នាំ ២០០៧ ពី "របកគំហើញនៃធនធានរបស់ប្រទេសកម្ពុជា " និង ឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាថា "ផលប្រយោជន៍នៃរបកគំហើញនេះនឹងត្រូវបានចែកចាយទៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៃសង្គម។" ឧបនាយករដ្ឋមន្ត្រី បានបញ្ជាក់ថា កំណើននៃចំណូលពីវិស័យប្រេង ឧស្ម័ន និងរ៉ែ នឹងជួយបំពេញដល់គោលបំណងអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា "ដែលជាការកាត់បន្ថយការពឹងផ្អែកលើជំនួយពីម្ចាស់ជំនួយ និងប្រាក់កម្ចី ដែលជាបន្ទុកធ្ងន់មួយ នឹងធ្វើអោយមានថវិកាច្រើនសម្រាប់កម្មវិធីអប់រំ សុខាភិបាល ហេដ្ឋារចនាសម្ព័ន្ធ និង កម្មវិធីសង្គមកិច្ច និងកំណើន នៃឱកាសមានការងារធ្វើសម្រាប់យុវវ័យកម្ពុជា ទាំងអ្នកមានជំនាញ ទាំងអ្នកគ្មានជំនាញ។" ឯកឧត្តម សុខ អាន បានបង្ហាញថា ចំនួននៃអាជ្ញាប័ណ្ណស្រាវជ្រាវរ៉ែ ដែលបានផ្តល់ទៅអោយក្រុមហ៊ុនបរទេស និងក្រុមហ៊ុនក្នុងស្រុក មានការកើនឡើង ហើយបាននិយាយដោយឡែកចំពោះអាជ្ញាប័ណ្ណផ្តល់ឱ្យ ក្រុមហ៊ុន BHP Billiton និង ក្រុមហ៊ុន Mitsubishi Corporation ដែលអាចនាំមកនូវប្រាក់វិនិយោគ រាប់ពាន់លានដុល្លាអាមេរិក [៤]។ កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខាក្នុង ឆ្នាំ២០០៦

---

1 Chea Sieng Hong, "Mineral Exploration and Mining Projects in Cambodia," Paper presented at the Conference on Mining Opportunities in the Greater Mekong Sub-Region, 16-17 June 2006, Vientiane, Lao PDR.

2 Wu, John C. "The Mineral Industry of Cambodia," in US Geological Survey Minerals Yearbook, 2006 and 2007.

3 Wu, "The Mineral Industry of Cambodia," in US Geological Survey Minerals Yearbook, 2007

4 H.E. Sok An, "Oil, Gas and Mineral Development – Cambodia's Resource Breakthrough," Speech delivered at the Conference on Cambodia's Investment, Trade and Infrastructure 2007, 8 November 2007, Phnom Penh, Cambodia

ផ្តល់ឱ្យក្រុមហ៊ុន ទាំងពីរនូវសិទ្ធិផ្តាច់មុខក្នុង ការរុករករ៉ែបុកស៊ីដ នៅលើផ្ទៃដីប្រមាណ ៩៩៦ គ.ម$^{២}$. ក្នុងខេត្តមណ្ឌលគិរី ព្រមទាំងលទ្ធភាពដែលអាចកសាង រោងចក្រចំរាញ់ជាតិអាលុយមីញ៉ូមផងដែរ។

ក្រោយមក នៅឆ្នាំ២០០៩ ក្រុមហ៊ុន BHP Billiton និង Mitsubishi Corporation បានដកខ្លួនចេញពីសម្បទានរ៉ែបុកស៊ីដ នៅខេត្តមណ្ឌលគិរី ប៉ុន្តែ មានក្រុមហ៊ុនរ៉ែធំៗមួយចំនួនទៀត កំពុងធ្វើការរុករករ៉ែយ៉ាងសកម្ម។ ក្រុមហ៊ុន Oz Minerals ដែលពីមុនមានឈ្មោះ Oxiana Limited បានទទួលអាជ្ញាប័ណ្ណរុករករ៉ែ លើផ្ទៃដី ៤៣៩ គ.ម$^{២}$. ក្នុងខេត្តមណ្ឌលគិរី ហើយមើលឃើញលទ្ធផលគួរជាទីសង្ឃឹម ក្នុងការសាកល្បងរករ៉ែមាសនៅ អូរខ្វាវ [៥]។ ក្រុមហ៊ុន Southern Gold ទទួលអាជ្ញាប័ណ្ណ លើផ្ទៃដី ១ ៦០០ គ.ម$^{២}$. ក្នុងខេត្តក្រចេះ និងខេត្តមណ្ឌលគិរី បាននិយាយថា ក្នុងជំហានដំបូងៗ តាមផែនទីភូគព្ភសាស្ត្រ បានរកឃើញរ៉ែមាសល្អៗ និង លោហៈធាតុផងដែរ [៦]។ ក្រុមហ៊ុន Kenertec Limited បាន ទទួលសិទ្ធិលើតំបន់ចំនួន ៨ ដែលមានផ្ទៃដីចំនួន ១ ៥២០ គ.ម$^{២}$. ក្នុងខេត្តព្រះវិហារ និងខេត្តភាគពាយ័ព្យហើយ បានរកឃើញ ស្ពាន់ ស័ង្កសី ដែកនិង ម៉ង់ហ្គាណែស្ស ប្រកបដោយគុណភាពក្នុងបរិមាណច្រើនគួរសម [៧]។ ក្រុមហ៊ុន Indochine Resources បានទទួលសិទ្ធិស្រាវជ្រាវធនធានរ៉ែក្នុងតំបន់ដែលមាន ផ្ទៃដី១ ៨០០ គ.ម$^{២}$. នៅ ខេត្តរតនៈគិរី [៨]។ ក្រុមហ៊ុន Southern Mining បានទទួលសម្បទាន លើផ្ទៃដីចំនួន ១០ ០០០ ហិចតា ដើម្បីរុករករ៉ែក្រូម នៅខេត្តពោធិ៍សាត់ [៩]។ នៅក្នុងឆ្នាំ ២០០២ សៀវភៅប្រចាំឆ្នាំស្ដីពីការ អង្កេតភូគព្ភសាស្ត្ររ៉ែ របស់សហរដ្ឋអាមេរិក បញ្ជាក់ថា មួយទសវត្សរ៍មុន ចាប់តាំងពីឆ្នាំ១៩៩៣មក ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានចេញអាជ្ញាប័ណ្ណរ៉ែតែ ១១ ប៉ុណ្ណោះ [១០]។ នៅក្នុងឆ្នាំ ២០០៤ តម្រូវការរ៉ែជាសកលកើនឡើងយ៉ាងឆាប់រហ័ស ដែលមានក្រុមហ៊ុនធំៗ ចាប់អារម្មណ៍មកលើកម្ពុជា។ ចាប់តាំងពីឆ្នាំ២០០៦ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានចេញអាជ្ញាប័ណ្ណរុករករ៉ែចំនួន ១០៤។ មកដល់ឆ្នាំ២០១០ ក្រុមហ៊ុនចំនួន ៥០ ទទួលបានសម្បទានជាង ១០០ (រូបទី១) [១១]។

---

[5] Kinetz, Erika and Yun Samean, "Mining Companies, Villagers Vie for Gold in Mondulkiri Province, "*The Cambodia Daily Weekend*, 14-15 July 2007.
[6] Commonwealth Communications, "Invest in Cambodia," London, 2009; Prospectors & Developers Association of Canada, "Cambodia's Mining Sector," 30 May 2007.
[7] Commonwealth Communications, "Invest in Cambodia."
[8] Beaumont, Pearl, *Extractive Industry Mining Study, Social &Environmental Impacts, Ratanakiri & Mondulkiri*, Development and Partnership in Action, July 2008.
[9] Prospectors & Developers Association of Canada, "Cambodia's Mining Sector,"
[10] Wu, John C. "The Mineral Industries of Cambodia and Laos," US Geological Survey Minerals Yearbook, 2002.
[11] Thompson, Richard, "Regional and International Country Experiences: Lessons Learned," Presentation made at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

## រូបទី១: ផែនទីអាជ្ញាប័ណ្ណរ៉ែនៅប្រទេសកម្ពុជា




ប្រភព : Yos Monireth, Director of Mineral Resources, “Opportunities and Challenges Facing the People Living in Mineral Exploration and Mining Areas,” Presentation Made at the International Mining Conference: Staking a Claim for Cambodia, Phnom Penh, May 26-27, 2010.

សុន្ទរកថាគន្លឹះរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីខែឧសភា ឆ្នាំ២០១០ ក្នុងសន្និសីទអន្តរជាតិស្តីពីរ៉ែនៅរាជធានីភ្នំពេញបានលើកឡើងថា កម្ពុជាមានភាពយឺតយ៉ាវក្នុងការអភិវឌ្ឍលើវិស័យរ៉ែនេះដោយសារបញ្ហាអសន្តិសុខនៅតាមតំបន់ព្រៃភ្នំ ដែលជាទីតាំងជម្រករ៉ែ កង្វះខាតធនធានមនុស្សនិងស្ថាប័ន។ លោកនាយករដ្ឋមន្ត្រីបានបន្ថែមទៀតថា "ដោយឡែក ប្រសិនបើការអភិវឌ្ឍន៏វិស័យរ៉ែនេះ ស្ថិតក្នុងរូបភាពវិជ្ជមានក្នុងដំណើរការ អភិវឌ្ឍន៏សង្គម- សេដ្ឋកិច្ច យើងក៏មិនបោះបង់ជម្រើសនោះដែរ។ ដូច្នេះរដ្ឋាភិបាល នឹងបន្តអនុវត្តវិធានការវិតត្បិត ដែលមានលក្ខណៈសង្គតិភាពជាមួយយន្តការ និងបទបញ្ញត្តិជាធរមាននានាលើការគ្រប់គ្រងក្នុងវិស័យនេះ... ពិតណាស់ថា ការចម្រាញ់ផលប្រយោជន៏ពីធនធានធម្មជាតិដោយខ្វះទស្សនវិជ្ជាអភិរក្ស នឹងរួមចំណែកបំប្លែងប្រវត្តិសាស្ត្រ ធ្វើអោយបាត់បង់មរតកវប្បធម៌ និងបង្កឱ្យមានអស្ថេរភាពបរិស្ថាន។ ប្រសាសន៏របស់នាយករដ្ឋមន្ត្រីគឺជា ការណែនាំមួយ នៅពេលដែលគាត់បញ្ជាក់ពីសក្តានុពលសម្រាប់វិស័យរ៉ែថា "ជាប្រភពចំណូលយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍជាតិ និងការកាត់បន្ថយភាពក្រីក្រ"។ គាត់ក៏បានណែនាំដែរថា បើគ្មានបទដ្ឋានរដ្ឋតឹងតែង រ៉ែអាចប្រែក្លាយតំបន់មួយដែលមានលក្ខណៈស្រស់បំព្រង ទៅជាតំបន់រហោស្ថាន តំបន់កខ្វក់ និងតំបន់អស្ថេរភាព ដោយសារធនធាន ធម្មជាតិរងសម្ពាធនៃការបំផ្លិចបំផ្លាញយ៉ាងខ្លាំងនោះ [១២]។

[12] Prime Minister H.E. Hun Sen, “Keynote Address” delivered at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

## សន្និសីទអន្តរជាតិស្តីពីរ៉ែនៅរាជធានីភ្នំពេញ ខែឧសភា ឆ្នាំ២០១០

តំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅកម្ពុជា Douglas Broderick បានកត់សំគាល់ដំបូង នៅក្នុង សន្និសីទ អន្តរជាតិស្តីពីរ៉ែថា ការរុករករ៉ែដោយក្រុមហ៊ុននៅកម្ពុជា បង្ហាញសក្តានុពលភូគព្ភសាស្ត្រខ្ពស់គួរអោយកត់សំគាល់។ ប៉ុន្តែគាត់បានបន្ថែមទៀតថា " យើងត្រូវមានការឈ្លាសវៃក្នុងការទាញយកវាអោយបានត្រឹមត្រូវ។ ការធានាអោយមានគោលនយោបាយ និង ការអនុវត្តត្រឹមត្រូវ " -ហើយមានការប្រកាន់ខ្ជាប់-គឺជាមធ្យោបាយតែមួយគត់ក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មរ៉ែ ដែលមានទំនួលខុសត្រូវនៅកម្ពុជា។ ក្នុងកិច្ចស្វាគមន៏ដល់វាគ្មិន និងប្រតិភូចូលរួម គាត់បានបង្ហាញពីបំណងនៃការជួបជុំនេះថា " យើងគិតថាសន្និសីទនេះមានសារសំខាន់ណាស់ ព្រោះវាជាជំហានមួយក្នុងដំណើរយ៉ាងវែងឆ្ងាយក្នុងការធានាអោយមានយន្តការសមស្រប ដើម្បីអភិវឌ្ឍវិស័យនេះប្រកបដោយទំនួលខុសត្រូវ។ នេះមានន័យថា ប្រការសំខាន់បំផុតគឺការការពារផ្នែកសង្គម និងបរិស្ថានត្រូវសរសេរឡើងទៅជាច្បាប់និងបទដ្ឋានផ្សេងៗ ទើបយើងបន្សល់ទុកកេរ្តិ៍ដំណែលនៃវិស័យរ៉ែជាវិជ្ជមាននៅក្នុងប្រទេស "[១៣]។

ដើម្បីជួយសម្រួលដល់អ្នកអានទៅនឹងការសិក្សាស្រាវជ្រាវនេះ យើងបានសង្ខេបសារគន្លឹះ៧ដែលលេចចេញពីសន្និសីទអន្តរជាតិ ស្តីពីតម្រូវការផលិតផលរ៉ែជាសកល ហានិភ័យ និងផលប្រយោជន៏ពីការធ្វើអាជីវកម្ម និងការរុករករ៉ែ សារសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងវិស័យរ៉ែ គំនិតផ្តួចផ្តើមសម្រាប់សកម្មភាពរ៉ែដែលមានទំនួលខុសត្រូវនៅប្រទេសម៉ុងហ្គោលី និង សង្ខេបរបាយការណ៏ និងសុន្ទរកថាបិទ[១៤]។

## តម្រូវការជាសកលចំពោះផលិតផលរ៉ែ

បទបង្ហាញនៅក្នុងសន្និសីទអន្តរជាតិរបស់លោក Richard Schodde ទីប្រឹក្សានៅស្ថាប័នយុទ្ធសាស្ត្រ (URC) បានធ្វើការ អះអាងថា បន្ទាប់ពីមានការធ្លាក់ចុះយ៉ាងយូរមក តម្លៃនៃការប្រើប្រាស់លោហៈធាតុបានកើនឡើងទូទាំងពិភពលោក ជាងមួយទសវត្សរ៍ចុងក្រោយនេះ[១៥] ដែលនាំអោយក្រុមហ៊ុនរ៉ែមានចំណូលខ្ពស់ និង ទទួលផលចំណេញច្រើន។ ថ្មីៗនេះក្នុងកំឡុង ឆ្នាំ២០០៣-២០០៨ ប្រទេសចិនមានតម្រូវការភាគច្រើននៅលើពិភពលោកគឺ ស្មើប្រមាណ ៦០-៩០ ភាគរយ នៃតម្រូវការសរុប ដែលមានដូចជា ទង់ដែង អាលុយមីញ៉ូម នីកែល និងដែក។ ខណៈដែល ការនាំចូលរ៉ែភាគច្រើន ដោយប្រទេសចិនត្រូវបានប្រើប្រាស់សម្រាប់តម្រូវការ

[13] Broderick, Douglas, "Introductory Remarks," presented at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.
[14] Papers and presentations made at the conference may be accessed on the UN website: www.un.org.kh/undp/international-conference-on-mining.
[15] Schodde, Richard, "Setting the Stage: Global Context for Mining and Extractive Industries," Paper presented at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

ក្នុងស្រុក។ លោហៈធាតុប្រមាណ ២០-៤០ភាគរយ ត្រូវបាននាំចេញជាផលិតផលសម្រេច សម្រាប់ប្រើប្រាស់ទៅកន្លែងផ្សេងទៀតទូទាំងពិភពលោក។ តម្រូវការរ៉ែរបស់ចិន បានជះឥទ្ធិពលមួយផ្នែក ដោយសារស្ថានភាពសេដ្ឋកិច្ចនៅប្រទេសដទៃទៀត។ វិបត្តិហិរញ្ញវត្ថុពិភពលោក បង្កអោយមានតម្រូវការរ៉ែ ធ្លាក់ចុះដែលធ្វើឱ្យតម្លៃលោហៈធាតុ និងកំរ៉ៃពីឧស្សាហកម្មកាន់តែទាប។ ទោះជាយ៉ាងណាក៏ដោយ Schodde បានអះអាងថាតម្លៃលោហៈធាតុធ្លាក់ចុះជាបណ្តោះអាសន្ន ហើយព្យាករណ៍ថា ត្រឹមឆ្នាំ២០១២ ឬ ២០១៣ នឹងកើនឡើងដូចមុនវិបត្តិឆ្នាំ២០០៧ ដែលចិនជាក្បាលម៉ាស៊ីននៃកំណើននេះ។ នៅកម្ពុជា ទាក់ទងនឹងតម្រូវការរ៉ែដែកទង់ដែង និង ធ្យូង នឹងកើនឡើងក្នុងរយៈពេលមធ្យម ហើយមាសក៏នឹងមានការកើនឡើងគួរសមដែរ។ ដើម្បីទទួលផលជាអតិបរមាពីរ៉ែ Schodde បានជម្រុញអោយរដ្ឋាភិបាលលើកទឹកចិត្តការវិនិយោគបរទេស លើការរុករករ៉ែ តាមរយៈការផ្តល់អត្រាពន្ធដែលមានលក្ខណៈប្រកួតប្រជែង និងបន្ធូរបន្ថយហានិភ័យ ពាណិជ្ជកម្ម ដោយអភិបាលកិច្ចល្អ និង តម្លាភាព។ ដើម្បីបានការទទួលស្គាល់ពីសង្គម (អាជ្ញាប័ណ្ណសង្គម) សម្រាប់ប្រតិបត្តិការនៅកម្ពុជា Schodde បានក្រើនរំលឹកដល់ក្រុមហ៊ុនរ៉ែឱ្យធ្វើសកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវលើបរិស្ថាន និងសង្គម។

## ហានិភ័យនិង ផលប្រយោជន៍ក្នុងការរុករក និងការត្រៀមលក្ខណៈធ្វើរ៉ែ

Roderick G. Eggert សាស្ត្រាចារ្យមកពីសាលារ៉ែនៅកូលូរ៉ាដូ យល់ឃើញថា ការរុករកនិងការត្រៀមលក្ខណៈ គឺជាការស៊ើបអង្កេត មុនពេលធ្វើសកម្មភាពរ៉ែ។ ក្នុងបទបង្ហាញ នាសន្និសីទអន្តរជាតិ Eggert អះអាងថា ផលប្រយោជន៍ពីការរុករក និងធ្វើអាជីវកម្មរ៉ែ ដែលមានភាពជោគជ័យសំខាន់គឺនៅពេលដែលរណ្តៅរ៉ែត្រូវបានរកឃើញ ធ្វើការវាយតម្លៃ និងវិវត្តទៅជាការយករ៉ែ។ នៅពេលនោះហើយ គាត់អោយប្រុងប្រយ័ត្នពីហានិភ័យផ្សេងៗ ដោយការរុករក និងធ្វើអាជីវកម្មរ៉ែ [១៦]។ ការប៉ះពាល់ពីអាជីវកម្មរ៉ែអាចមានច្រើនជាងផលប្រយោជន៍ ប្រសិនបើ ការងារជាច្រើនធ្លាក់ទៅអ្នកខាងក្រៅ ការបំផ្លាញបរិស្ថានកាន់តែធ្ងន់ធ្ងរ ការរំខានដល់ប្រជាពលរដ្ឋមូលដ្ឋាន ចំណូលពីរ៉ែសម្រាប់តែអភិវឌ្ឍជាតិ ជាជាងការអភិវឌ្ឍន៍នៅមូលដ្ឋាន ឬ រដ្ឋាភិបាលធ្វើការចំណាយលុយពន្ធ និង ភាគផលដោយខ្ជះខ្ជាយ។

Eggert បានបែងចែកដំណាក់កាលសកម្មភាពរ៉ែជាបួនៈ ការស្រាវជ្រាវនិងការត្រៀមលក្ខណៈ ការទាញយករ៉ែ ដំណើរការស្លរ៉ែ និងការច្នៃផលិត។ ការស្រាវជ្រាវនិងត្រៀមលក្ខណៈចែកចេញជាដំណាក់កាលតូចៗបួនទៀតៈ ១-ការរុករករ៉ែមុនពេលកំណត់តំបន់ភូមិសាស្ត្រ ២-ការស្រាវជ្រាវកាន់តែស៊ីជម្រៅ ដើម្បីវាយតម្លៃថាតើតំបន់ដែលរកឃើញគួរដំណើរការទាញយកបែបណា ៣-ការត្រៀមលក្ខណៈកំណត់ស្រទាប់រ៉ែដោយធ្វើការវាយ តម្លៃសេដ្ឋកិច្ចនិងបច្ចេកទេស ដើម្បីធ្វើការសំរេចចិត្តថាត្រូវធ្វើការយករ៉ែឬអត់ និង ៤-

[16] Eggert, Roderick G., "Mineral Exploration and Development: Risk and Reward," Paper presented at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

ការត្រៀមលក្ខណៈយករ៉ែ ដោយរៀបចំលើកផែនការនិងស្ថាបនា គ្រឿងបរិក្ខា និងហេដ្ឋារចនាសម្ព័ន្ធ។ ការចាប់ផ្តើម ពីការរុករករ៉ែ រហូតដល់ការទាញយករ៉ែ ចំណាយពេលប្រហែលជា ៥ទៅ ១៥ឆ្នាំ ដោយធ្វើឡើងជាបន្តបន្ទាប់។

Eggert បានពន្យល់ថាគ្រប់ដំណាក់កាលនៃការរុករកនិងការត្រៀមលក្ខណៈមានការប៉ះពាល់ដល់សហគមន៍មូលដ្ឋាន និងបរិស្ថានធម្មជាតិ។ ការប៉ះពាល់តែងតែមានតិចបំផុតនៅដំណាក់កាលរុករក។ នៅក្នុងពេលនេះមានមនុស្សតិចតួច ត្រូវចូលរួម ហើយបច្ចេកទេសក៏មិនប៉ះពាល់ខ្លាំងដែរ។ ការស្រាវជ្រាវស៊ីជម្រៅមានការប៉ះពាល់ខ្លាំងជាង ប៉ុន្តែមិនធ្ងន់ធ្ងរទេ បើប្រៀបជាមួយនិងដំណាក់កាលធ្វើការទាញយករ៉ែ។ បញ្ហានៅក្នុងដំណាក់ការនេះមានដូចជា ការធ្វើផ្លូវ ការខួងនិងជីក និងវត្តមាននៃការរស់នៅរបស់អ្នកខាងក្រៅដែលជាអ្នកភូគព្ភសាស្ត្រនិង កម្មកររ៉ែ ប្រមាណជាមួយឆ្នាំ ឬច្រើនជាងនេះ។ ផ្ទុយទៅវិញ ការត្រៀមលក្ខណៈកំណត់រកស្រទាប់រ៉ែនិងការទាញយករ៉ែមានហានិភ័យយ៉ាងធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គមដូចជា ការបំពាក់គ្រឿងបរិក្ខារនិងហេដ្ឋារចនាសម្ព័ន្ធនៅតំបន់មានមនុស្សរស់នៅ អាចបង្កអោយមានការផ្លាស់ប្តូរលំនៅដ្ឋាន និង ការចិញ្ចឹមជីវិត។ ការហូរចូលនៃកម្មកររ៉ែមកពីខាងក្រៅអាចបង្កអោយ មានផលលំបាកលើផ្នែកហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលមានស្រាប់ ដែលអាចត្រឹមតែបំពេញតម្រូវការរបស់អ្នកមូលដ្ឋានប៉ុណ្ណោះ។ ទំនាស់លើការចិញ្ចឹមជីវិត និងវប្បធម៌អាចកើតមានឡើងដោយសារភាពខុសគ្នាពីអ្នកខាងក្រៅ។ តាមទស្សនៈលើបរិស្ថានការទាញយករ៉ែ បង្កអោយមាននៅសល់កាកសំណល់ពេញផ្ទៃដី ដោយការកំទេចយករ៉ែ និងដំណើរការចំរោះយករ៉ែ។ Eggert បានអះអាងថា មានផលប៉ះពាល់សង្គមជាច្រើន ពីការយករ៉ែថ្មីៗ អាចត្រូវបានកាត់បន្ថយ ឬតាមរយៈការធ្វើផែនការដោយមានការពិគ្រោះយោបល់ តែគាត់ទទួលស្គាល់ថា មានការប្រែប្រួលខ្លះនៅក្នុងសហគមន៍ដែលមិនអាចជៀសវាងបាន និងមានលក្ខណៈអចិន្ត្រៃយ៍។

## ការទទួលស្គាល់សារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរត្រៀមលក្ខណៈទាញយករ៉ែ

ក្នុងបទបង្ហាញនាសន្និសីទអន្តរជាតិ Kuntala Lahir-Dutt អ្នកស្រាវជ្រាវនៃកម្មវិធីគ្រប់គ្រងធនធាននៅអាស៊ីប៉ាស៊ីហ្វិកនៃសាកលវិទ្យាល័យ ជាតិអូស្ត្រាលី លើកឡើងពីសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការត្រៀមលក្ខណៈទាញយករ៉ែ និងការស្វែងយល់ពីបរិបទវប្បធម៌ និងសង្គមនៅកន្លែងដែលធ្វើប្រតិបត្តិការរ៉ែ ដែលរឿងនេះភាគច្រើនគេតែងតែធ្វើព្រងើយកន្តើយ [១៧]។ ដូចគ្នាទៅនឹងផ្នែកភូគព្ភសាស្ត្រ និងវិស្វកម្មដែរ ដំណើរការចូលរួមរបស់ប្រជាពលរដ្ឋជាមួយសកម្មភាពរ៉ែ គឺមានលក្ខណៈស្មុគ្រស្មាញ និងសាំញ៉ាំ ហើយទាមទារឯកទេសសម្របសម្រួលទូលំទូលាយ។ Lahir-Dutt អះអាងថា ការធ្វើពាណិជ្ជកម្មរ៉ែដែលល្អ គឺជាញឹកញាប់

[17] Lahiri-Dutt, Kuntala, "The People Dimension of Mining: An Overview of Issues around Workers and Communities," Paper presented at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

មិនមានខូចខាតដល់សហគមន៍មូលដ្ឋាន។ ខណៈពេលដែលសកម្មភាពរ៉ែផ្តល់នូវឱកាសការងារតិចតួច និងជាប្រភពចំណូលសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ តែវាអាចផ្លាស់ប្តូរសហគមន៍ដែលរស់នៅតាមប្រពៃណី និងរស់នៅដោយខ្លួនឯង ទៅជាសហគមន៍មួយដែលពឹងផ្អែក ក្រីក្រ និងគ្មានអំណាច។

Lahir-Dutt អះអាងថា ប្រតិបត្តិការរ៉ែត្រូវទទួលស្គាល់នូវសិទ្ធិរបស់ប្រជាពលរដ្ឋមូលដ្ឋានគឺមិនគ្រាន់តែផ្តល់ព័ត៌មាននោះទេ ប៉ុន្តែព្រមទាំងមានទំនាក់ទំនងគ្នានិងផ្តល់ការចូលរួមសំរេចចិត្តក្នុងសកម្មភាពរ៉ែ។ កង្វល់បួនសំខាន់: ១-សិទ្ធិជាម្ចាស់ និងគ្រប់គ្រងដែនដីដោយសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច ២-សិទ្ធិស្វ័យសំរេចតាមរយៈការផ្តល់ការយល់ព្រមនិងការចូលរួម ៣-សិទ្ធិជនជាតិដើមភាគតិចក្នុងការធ្វើជាតំណាងអោយក្រុមរបស់ពួកគេ និង ៤-សិទ្ធិទទួលបានសន្តិសុខស្បៀង។ ការធ្វើរ៉ែត្រូវតែរៀបចំមធ្យោបាយដើម្បីដោះស្រាយបញ្ហាទាំងនេះ បើមិនដូច្នោះទេការទាញយករ៉ែនឹងនាំទៅរកចលាចលសង្គម និងការតវ៉ាជានិច្ច បើទោះជាអាចមានផលប្រយោជន៍ចំពោះអ្នកពាក់ព័ន្ធមួយចំនួន។

Lahir-Dutt បានស្នើមធ្យោបាយឡើងថា ប្រជាពលរដ្ឋមូលដ្ឋានអាចចូលរួមក្នុងដំណាក់កាលផ្សេងៗពីវដ្តនៃគម្រោងរ៉ែ។ នៅក្នុង *ដំណាក់កាលសិក្សារុករក* មានសារៈសំខាន់ណាស់ក្នុងការយល់ពីទិដ្ឋភាពវប្បធម៌ និងសង្គមនៅក្នុងតំបន់ បញ្ជាក់ពីចំនួនអ្នកដែលរស់នៅក្នុងតំបន់ ហើយចាប់ផ្តើមស្គាល់ យល់និងគោរពវប្បធម៌ និងទំនៀមទម្លាប់។ ក្នុង *ដំណាក់កាលវាយតម្លៃស្រទាប់រ៉ែ* គេត្រូវយល់ព្រមជាមុននិងផ្តល់ព័ត៌មានច្បាស់ដល់សហគមន៍។ ស្ត្រីគួរតែចូលរួមយ៉ាងសកម្មក្នុងការចរចាផលប៉ះពាល់អវិជ្ជមានលើប្រពៃណីវប្បធម៌មូលដ្ឋាន។ ក្នុង *ដំណាក់កាលរៀបចំផែនការធ្វើរ៉ែ* ការវាយតម្លៃផលប៉ះពាល់វប្បធម៌ជាអវិជ្ជមានដែលអាចកើតមានចំពោះសហគមន៍។ ផែនការផ្លាស់ប្តូរទីលំនៅនិង ការស្តារឡើងវិញ គួរដាក់បញ្ចូលទៅក្នុងផែនការធ្វើរ៉ែ។ ផែនការអភិវឌ្ឍន៍សហគមន៍គួរតែលើកកំពស់សមត្ថភាពសហគមន៍អោយមានជីវភាពនិងឱកាសសំបូរបែប លើកកំពស់សមធម៌ និងបង្កើនស្ថេរភាពសង្គម។ ក្នុង *ដំណាក់កាលសាងសង់* ក្រុមហ៊ុនគួរតែមានទំនាក់ទំនងជាប្រចាំជាមួយសហគមន៍ ដើម្បីការពារប្រព័ន្ធអេកូឡូស៊ី ស្ថេរភាពសេដ្ឋកិច្ច និង សុខុមាលភាពរួមគ្នា។ ក្នុង *ដំណាក់កាលប្រតិបត្តិការយករ៉ែ* ក្រុមហ៊ុនមិនគួរផ្តោតលើតែសុខុមាលភាពកម្មកររ៉ែ និង គ្រួសាររបស់ពួកគេនោះទេ ប៉ុន្តែត្រូវគិតពីអ្នករស់នៅក្នុងតំបន់ និងការត្រៀមខ្លួននៅពេលបញ្ឈប់សកម្មភាពរ៉ែផងដែរ។ ក្នុង *ដំណាក់កាលបញ្ឈប់* នៅពេលកំពុងដំណើរស្តារនិងកែលំអរបរិស្ថានឡើងវិញ ក្រុមហ៊ុនត្រូវប្រាស្រ័យទាក់ទងឱ្យសកម្ម ជាមួយអ្នករស់នៅមូលដ្ឋាន ដើម្បីអោយពួកគេអាចរកស៊ីចិញ្ចឹមជីវិតដោយនិរន្តភាពតាមរយៈគម្រោងផ្សេងៗ ការបណ្តុះបណ្តាល និងឥណទាន។

## សកម្មភាពរ៉ែដែលមានទំនួលខុសត្រូវសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

ក្នុងនាមសមាជិកគណៈកម្មការនាយកនៃគំនិតផ្តួចផ្តើមរ៉ែដែលមានទំនួលខុសត្រូវសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពប្រទេសម៉ុងហ្គោលី Zinaameder Batbayar បានចែករំលែកនូវបទពិសោធន៍ជាក់ស្តែងតាមរយៈបទបង្ហាញក្នុងសន្និសីទអន្តរជាតិស្តីពីរ៉ែ ថាតើរដ្ឋាភិបាល ឧស្សាហកម្មរ៉ែ និងសង្គមស៊ីវិល ធ្វើការរួមគ្នាដូចម្តេចដើម្បីលើកកំពស់សកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវ [១៨]។ គាត់បានពន្យល់ថា កាលពីខែវិច្ឆិកា ឆ្នាំ២០០៦ វេទិកាស្តីពីពហុភាគីពាក់ព័ន្ធលើកទីមួយ បានធ្វើឡើងដើម្បីពិភាក្សាពី សកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវក្នុងប្រទេសម៉ុងហ្គោលី ដែលមានតំណាងជាង ៨០ មកពីរដ្ឋាភិបាល សង្គមស៊ីវិល ឧស្សាហកម្ម និងអ្នកសិក្សាស្រាវជ្រាវ។ នៅចុងឆ្នាំ២០០៧ អ្នកចូលរួមដែលពាក់ព័ន្ធទាំងនោះ បានកំណត់ន័យមួយសម្រាប់សកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវ និង ចែងគោលការណ៍ចំនួនប្រាំបី។ ខ្លឹមសារដែលកំណត់ដោយអ្នកចូលរួមទាំងនោះលើកឡើងពី : សកម្មភាពរ៉ែដែលមានទំនួលខុសត្រូវជាសកម្មភាពមួយដែលមានលក្ខណៈទូលំទូលាយ និងមានតម្លាភាពក្នុងការគោរពសិទ្ធិដល់ អ្នកពាក់ព័ន្ធទាំងឡាយ ជាពិសេស ប្រជាពលរដ្ឋមូលដ្ឋាន មិនមានផលប៉ះពាល់ដល់សុខភាពមនុស្ស និង គិតគូរលើបរិស្ថាន អនុវត្តតាមគោលការណ៍ប្រតិបត្តិល្អ ជាអន្តរជាតិ និងអនុវត្តតាមនីតិរដ្ឋដើម្បីជាប្រយោជន៍ដល់ ប្រជាពលរដ្ឋម៉ុងហ្គោលី ប្រកបដោយនិរន្តរភាព។ គោលកាណ៍ទាំងប្រាំបីនោះមាន: ផ្តល់អោយមានការចូលរួមពីអ្នកពាក់ព័ន្ធ បើកចំហរ និងមានតម្លាភាព អនុវត្តតាមច្បាប់ ទទួលខុសត្រូវលើសន្តិសុខមនុស្ស និងបរិស្ថាន វិនិយោគសម្រាប់អនាគត ប្រសិទ្ធភាព ដោយក្តីមេត្តានិង សីលធម៌ និងបច្ចេកទេសទំនើប។ នៅខែមេសា ឆ្នាំ២០០៨ ការផ្តើមគំនិតសកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវ បានចាប់ផ្តើមអនុវត្តទៅតាមខ្លឹមសារដែលបានចែង។ សមាជិកគណៈកម្មការកណ្តាលទាំង ១៥ រូប រួមមានប្រាំរូបតំណាងរដ្ឋាភិបាល ប្រាំរូបតំណាងវិស័យឧស្សាហកម្ម និង ៥ រូបតំណាងសង្គមស៊ីវិល។

## សង្ខេបរបាយការណ៍ និងសុន្ទរកថាបិទនៅសន្និសីទអន្តរជាតិ

អគ្គនាយក ធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ឯកឧត្តម សុខ ឡេង ធ្វើការសង្ខេបពីសន្និសីទ។ ការសង្ខេបរបស់គាត់បានបង្ហាញយ៉ាងច្បាស់ថា រដ្ឋាភិបាលបានឮនិងកោតសរសើរនូវចំនុចផ្សេងៗ ដែលបានលើកឡើងពីវាគ្មិនឆ្នើមៗ [១៩]។ ឯកឧត្តម សុខ ឡេង បានបញ្ជាក់ជាចំនុចរួមមាន:

---

[18] Zinaameder Batbayar, “Responsible Mining Initiative for Sustainable Development,” Presentation made at the Inernational Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

[19] H.E. Sok Leng, “Summary Report,” made at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

- យើងបានពិភាក្សាពីសារសំខាន់នៃអភិបាលកិច្ចល្អ និង.... តួនាទីរបស់រដ្ឋាភិបាលធ្វើយ៉ាងណា ក្នុងការអភិវឌ្ឍន៍វិស័យរ៉ែ ។
- យើងដឹងថា ការអនុវត្តច្បាប់លើវិស័យនេះ នឹងត្រូវបន្ថែមនូវបទបញ្ញត្តិជាច្រើនទៀត ។
- យើងក៏បានសិក្សាផងដែរពីការផ្តើមគំនិតពីតម្លាភាពឧស្សាហកម្មនិស្សារណកម្ម ដែលអាចអនុវត្តសម្រាប់សម្រេចបាននូវគោលបំណងនៃតម្លាភាព ។
- យើងក៏ត្រូវគិតគូរផងដែរពីធនធានរ៉ែដ៏មានតម្លៃសម្រាប់សេដ្ឋកិច្ចយើងក្នុងទស្សវត្សរ៍ខាងមុខ... ដូច្នេះហើយយើងត្រូវការបង្កើនសមត្ថភាពមន្ត្រីរបស់យើងដែលទទួលបន្ទុកវិស័យរ៉ែ ។
- យើងក៏ដឹងច្បាស់ផងដែរបញ្ហាប្រឈមទូទៅ (ក្នុងចំណោមប្រទេសអាស៊ានដទៃទៀត) ដើម្បីធានាការការពារបរិស្ថាន ដោះស្រាយបញ្ហាសង្គមនៅក្នុងសហគមន៍ ដែលធ្វើសកម្មភាពរ៉ែខ្នាតតូច និង យុទ្ធសាស្ត្រគ្រប់គ្រងវិស័យឧស្សាហកម្មរ៉ែរបស់យើង ។
- យើងក៏ដឹងផងដែរថា... (ដែល) ត្រូវផ្តល់ជំនាញផ្នែកភូគព្ភសាស្ត្រនិងលើសកម្មភាពរ៉ែដោយផ្តោតលើផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងការរុករកនិងទាញយករ៉ែ ។
- យើងត្រូវប្រុងប្រយ័ត្នក្នុងការទាក់ទាញតែក្រុមហ៊ុនណា ដែលធ្វើតាមគោលការណ៍ប្រតិបត្តិល្អសម្រាប់ការវិនិយោគលើវិស័យរ៉ែនៅកម្ពុជា ។
- យើងត្រូវគិតគូរពីការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងវិស័យនេះ... សហគមន៍មូលដ្ឋានដែលជាប់ពាក់ព័ន្ធវិស័យនេះគួរមានជំនាញបច្ចេកទេស ដែលអាចប្រើបានប្រកបដោយនិរន្តរភាពលើវិស័យផ្សេងទៀត នៅពេលការទាញយករ៉ែត្រូវបានបញ្ចប់ ។

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ឯកឧត្តម ស៊ុយ សែម បានផ្តល់សុន្ទរកថាបិទសន្និសីទ និងមានយោបល់ថា បទពិសោធន៍ និងអនុសាសន៍ដែលមានក្នុងសន្និសីទនេះរួមចំណែកយ៉ាងសំខាន់ ដើម្បីរៀបចំសកម្មភាពជាក់លាក់ និងអនុវត្តសម្រាប់ទទួលបានលទ្ធផលយ៉ាងជោគជ័យ លើវិស័យរ៉ែនៅកម្ពុជា[២០] ។ ឯកឧត្តម ស៊ុយ សែម បានប្រកាសថា "បន្ថែមលើចំណូលថវិកាជាតិ ការអភិវឌ្ឍន៍លើវិស័យរ៉ែ រួមចំណែកផងដែរក្នុងការអនុវត្តគោលនយោបាយរដ្ឋាភិបាល... រួមមានការផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋនៅមូលដ្ឋានកាត់បន្ថយចំណាកស្រុកពីតំបន់ជនបទមកទីក្រុង ពង្រីកការប្រកបមុខរបរចិញ្ចឹមជីវិតសម្រាប់ប្រជាពលរដ្ឋនៅក្នុងតំបន់និង ផ្តល់ការឆ្លើយតបតាមគោលដៅកាត់បន្ថយភាពក្រីក្រ" ។

[20] H.E. Suy Sem, "Closing Speech," made at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

" វិនិយោគិនប្រតិបត្តិការលើវិស័យរ៉ែនៅក្នុងប្រទេស (ត្រូវ) មានទំនួលខុសត្រូវលើបរិស្ថាននិងសង្គម ដោយអនុវត្តតាមខ្លឹមសារ ដែលមានក្នុងច្បាប់និងបទប្បញ្ញត្តិផ្សេងៗ... នៅពេលដែលគិតអំពីរ៉ែនៅក្នុងប្រទេស ក្រុមហ៊ុន ត្រូវគិតអំពីសហគមន៍រស់នៅជុំវិញតំបន់រ៉ែតាមរយៈការចូលរួម និង គោរពតាមទម្លាប់ និង ប្រពៃណីអ្នកមូលដ្ឋាន។"

គាត់បានសន្និដ្ឋានជារួមថា "លទ្ធផលចេញពីសន្និសីទនេះមានសារសំខាន់ណាស់ សម្រាប់មន្ត្រីទទួលបន្ទុកវិស័យរ៉ែ វិនិយោគិនរ៉ែ និងអ្នកពាក់ព័ន្ធ ហើយយើងចង់ឃើញការអនុវត្ត និងសកម្មភាពជាក់ស្តែងដែលទាញចេញពីលទ្ធផលនៃសន្និសីទនេះ។ យើងនឹងខិតខំប្រឹងប្រែងកាត់បន្ថយការលំបាកទាំងឡាយតាមរយៈការគ្រប់គ្រងនិង អភិវឌ្ឍវិស័យនេះអោយមានតម្លាភាព ប្រសិទ្ធភាព និងនិរន្តរភាព។"

## របកគំហើញធនធានរ៉ែ: តើជាប្រយោជន៍ ឬក៏ជាឧបសគ្គសម្រាប់ប្រទេសកម្ពុជា?

ការធ្វើវិនិយោគយ៉ាងច្រើនរបស់ក្រុមហ៊ុនសាជីវកម្ម លើការរុករក និងធ្វើអាជីវកម្មរ៉ែ នៅកម្ពុជា ទទួលស្គាល់នូវការទទួលស្គាល់បានចំណូលយ៉ាងសន្ធឹកសន្ធាប់មកវិញបន្ថែមទៀត ដល់ម្ចាស់ភាគហ៊ុន។ ដូចគ្នានេះដែរ ការធ្វើអាជីវកម្មរ៉ែខ្នាតធំអាចនាំមកនូវប្រាក់ចំណូលយ៉ាងធំសម្បើមដល់រដ្ឋាភិបាល។ ក្នុងពេលទន្ទឹមគ្នានេះដែរ អាជីវកម្មរ៉ែគឺជាសហគ្រាសមួយដែលនាំមកជាមួយនូវការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធបរិស្ថាន និង សុខុមាលភាពរបស់សហគមន៍មូលដ្ឋាន។ សំនួរដែលលើកឡើងគឺថា: តើការរីកលូតលាស់យ៉ាងឆាប់រហ័សនៃឧស្សាហកម្មរ៉ែនៅប្រទេសកម្ពុជា នឹងរួមចំណែកបែបណាដល់ការអភិវឌ្ឍន៍ មូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេសបានទូលំទូលាយឬផ្តល់ផលប្រយោជន៍សម្រាប់ម្ចាស់ក្រុមហ៊ុនបរទេសនិងក្រុមអ្នកមាននៅក្នុងប្រទេស ក្នុងខណៈដែលមានការខាតបង់តំបន់ការពារជីវចំរុះ និងផ្លាស់ប្តូរលំនៅដ្ឋានអ្នកស្រុកក្នុងតំបន់? ចម្លើយសម្រាប់សំនួរនេះគឺមានសារៈសំខាន់ណាស់ សម្រាប់ខេត្តមណ្ឌលគិរី។ គួរកត់សម្គាល់ថា ការរស់រានមានជីវិតនៃវប្បធម៌ជនជាតិព្នងអាចកើតឡើងទៅបាន អាស្រ័យដោយការប្រកាន់ខ្ជាប់នូវសកម្មភាពធ្វើអាជីវកម្មរ៉ែប្រកបដោយទំនួលខុសត្រូវពីសំណាក់រដ្ឋាភិបាលនិងក្រុមហ៊ុនព្រោះដែនដីដែលជនជាតិព្នងរស់នៅកំពុងតែមានការរុករករ៉ែ។

## គោលបំណងនៃការស្រាវជ្រាវ

ការសិក្សារបស់គម្រោងវិភាគបញ្ហាការអភិវឌ្ឍន៍ (ADI) គឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាទាក់ទងនឹងការពង្រីកសកម្មភាពរ៉ែ និងសិទ្ធិជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគិរី។ ដើម្បីបង្ហាញនូវបញ្ហាទាំងនេះ ការសិក្សាស្រាវជ្រាវផ្តោតជាសំខាន់លើបទពិសោធន៍ របស់ជនជាតិដើមភាគតិចនៅក្នុងភូមិពីរដែលជាកន្លែងមានប្រតិបត្តិការរុករករ៉ែ។ ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងពិសេសគឺ: ១- ដើម្បីស្វែងយល់ពី

ការពង្រីកសកម្មភាពរ៉ែនៅខេត្តមណ្ឌលគិរី និងភូមិដែលចុះសិក្សាស្រាវជ្រាវ ២- ដើម្បីពិនិត្យមើលពីសិទ្ធិរបស់ជនជាតិដើមភាគតិច និងការចូលរួមរបស់ពួកគេក្នុងប្រតិបត្តិការរ៉ែនៅតាមតំបន់ដែលបានស្រាវជ្រាវ និង ៣- ដើម្បីវាយតម្លៃអំពីសុវត្ថិភាពនៃការប្រកបរបរចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិច នៅក្នុងភូមិដែល បានស្រាវជ្រាវ និងផលប៉ះពាល់ពីសកម្មភាពរ៉ែមកលើជីវភាពរស់នៅរបស់អ្នកភូមិ។

## វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ ត្រូវបានធ្វើឡើងក្នុងខេត្តមណ្ឌលគិរី ជាមួយជនជាតិដើមភាគតិចព្នង នៅភូមិហ្គាទី ស្រុកកែវសីមា និង ភូមិពូរ៉ាប៉ែត ស្រុកពេជ្រាដា ដែលជាផ្នែកមួយនៃវគ្គរបស់គម្រោង ADI ក្នុងខែឧសភា ឆ្នាំ ២០០៩។ ទីតាំងភូមិដែលបានជ្រើសរើស ជាភូមិដែលមានសកម្មភាពរុករករ៉ែកើតឡើង និងកន្លែងដែលអាចចូលដល់ និងអាចសម្រួលដល់សិក្ខាកាមត្រឹម១០នាក់ និងក្រុមអ្នកស្រាវជ្រាវនៅក្នុងភូមិនីមួយៗ។ ភូមិទាំងនេះ ជាភូមិដែលកំពុងមានការស្រាវជ្រាវដំបូងនៃការរុករករ៉ែ ដែលខុសពីភូមិផ្សេងទៀតនៅក្នុងឃុំមេម៉ង់ ស្រុកកែវសីមាដែលបានទទួលរងនូវ " ការបំផ្លាញស្ទើរតែពិបាកនិង ស្រោចស្រង់ឡើងវិញ " [២១] ។

ការសិក្សាស្រាវជ្រាវបានប្រើប្រាស់ទាំងវិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យ ដោយការអង្កេតប្រើប្រាស់កម្រងបញ្ជីសំនួរជាមួយគ្រួសារជនជាតិព្នងចំនួន ៣២ ក្នុងចំណោមគ្រួសារទាំង ៣៥ ក្នុងភូមិហ្គាទីក្នុងរយៈពេលចំនួនបួនថ្ងៃ និង ក្នុងភូមិពូរ៉ាប៉ែត ចំនួន ៣៩គ្រួសារ ក្នុងចំណោម ៥៨គ្រួសារ ក្នុងរយៈពេល ៣ថ្ងៃ។ ព្រមទាំងធ្វើការសំភាសន៍ជាមួយ បុគ្គលសំខាន់ៗ ដូចជា ថ្នាក់ដឹកនាំភូមិ អ្នកភូមិ អាជ្ញាធរឃុំ និងមន្ត្រីផ្នែករ៉ែក្នុងខេត្តជាដើម។ អ្នកស្រាវជ្រាវក៏បានប្រើប្រាស់ឯកសារពិគ្រោះផ្សេងៗទៀត ជាច្រើន ដូចជា របាយការណ៍ថ្មីៗ ស្តីអំពីសកម្មភាពរ៉ែនៅក្នុងប្រទេស ឯកសារច្បាប់គ្រប់គ្រងរ៉ែនៅកម្ពុជា និងឯកសារស្តីពីសិទ្ធិមនុស្សអន្តរជាតិ ដែលទាក់ទងនឹងជនជាតិដើមភាគតិច។

ការចូលរួមរបស់អ្នកស្រាវជ្រាវនៅក្នុងសិក្ខាសាលា និងសន្និសីទផ្សេងៗទៀត អំពីបញ្ហារ៉ែ បានរួមចំណែក យ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវនេះដូចជា ការចូលរួមកិច្ចពិភាក្សារយៈពេលកន្លះថ្ងៃក្នុងស្រុកកែវសីមា ដែលរៀបចំឡើងដោយអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) នៅក្នុងខែឧសភា ឆ្នាំ២០០៩ សិក្ខាសាលាពេញមួយថ្ងៃ នៅភ្នំពេញ ដែលរៀបចំដោយ គម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) នៃ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា និងអង្គការ DPA ក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ និង សិក្ខាសាលាកន្លះថ្ងៃនៅភ្នំពេញដែលរៀបចំដោយមូលនិធិ Heinrich Boll ក្នុងខែតុលា ឆ្នាំ២០១០។ លើសពីនេះទៀត អ្នកស្រាវជ្រាវក៏បានបញ្ចូលនូវការពិភាក្សាដ៏មានសារៈសំខាន់ផ្អែកលើសុន្ទរកថា ការសិក្សា

---

[21] Assessment of WWF Project Manager cited in Kinetz and Samean, “Mining Companies, Villagers Vie for Gold in Mondulkiri Province.”

ស្រាវជ្រាវ និងបទបង្ហាញជាច្រើន នៅក្នុងសន្និសីទអន្តរជាតិស្តីអំពីរ៉ែនៅភ្នំពេញ ដែលរៀបចំឡើងដោយគម្រោងអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ក្នុងខែឧសភា ឆ្នាំ២០១០។

ដូចគ្នាទៅនឹងបទពិសោធន៍ របស់អ្នកស្រាវជ្រាវផ្សេងទៀត បានធ្វើការសិក្សាស្រាវជ្រាវលើវិស័យរ៉ែដែរ ក្រុម ADI និងសិក្ខាកាមបានជួបផលលំបាកមួយចំនួនក្នុងការប្រមូលព័តិមាននៅតំបន់ស្រាវជ្រាវ [២២]។ នៅក្នុងភូមិពូរ៉ាប៉ែត អ្នកស្រាវជ្រាវត្រូវបានឃាត់ដោយប៉ូលីស ឃុំក្រង់តេះ ពេលកំពុងធ្វើការសំភាសន៍ នៅក្នុងថ្ងៃទីពីរ នៃការចុះភូមិ។ ប៉ូលីសឃុំ លើកឡើងថា ក្រុមស្រាវជ្រាវមិនមានលិខិតអនុញ្ញាតពីអភិបាលខេត្ត ដើម្បីចុះ។ ទោះបីជាមានការបញ្ឈប់របស់ប៉ូលីសក៏ដោយ អ្នកស្រាវជ្រាវនៅតែបន្តការចុះសិក្សាស្រាវជ្រាវ នៅតាមភូមិ ដោយសារគម្រោង ADI នៃអង្គការ CCC បានជូនព័តិមានជាផ្លូវការពីការចុះភូមិ ដល់អភិបាលខេត្តក្នុងរយៈពេលពីរសប្តាហ៏មុន។ ក្រុមសិក្សាស្រាវជ្រាវក៏បានជួបជាមួយមេឃុំ ពូរ៉ាប៉ែត នៅពេលចាប់ផ្តើមចុះសិក្សាស្រាវជ្រាវដែរ។ នៅថ្ងៃទីបីនៃការចុះសិក្សាស្រាវជ្រាវប៉ូលីសឃុំក៏បានបន្តបញ្ឈប់ក្រុមអ្នកស្រាវជ្រាវ។ ដោយសារតែការព្យាយាមចរចា របស់ប្រធានក្រុមស្រាវជ្រាវរបស់គម្រោង ADI មិនបានទទួលជោគជ័យ អ្នកសិក្សាស្រាវជ្រាវក៏បានចាកចេញពីភូមិនៅថ្ងៃទីបី ដែលតាមគម្រោងត្រូវចុះ ធ្វើការសិក្សារយៈពេលបួនថ្ងៃ។ តែទោះជាយ៉ាងណាអ្នកស្រាវជ្រាវអាចប្រមូលព័តិមានគ្រប់គ្រាន់តាមបំណង។

នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត អ្នកស្រាវជ្រាវមិនបានទទួលព័តិមានពិស្តារ របស់ក្រុមហ៊ុនរ៉ែពាក់ព័ន្ធនៅភូមិហ្គាទី និង ពូរ៉ាប៉ែតឡើយ ដោយហេតុថា ព័តិមានទាំងនេះ ត្រូវចាត់ទុកជាការសម្ងាត់ និង មិនបើកចំហរជាសាធារណៈឡើយ។ ចំណែកឯ ព័តិមានទូទៅអំពីឧស្សាហកម្មរ៉ែនៅកម្ពុជា ដែលបានស្នើទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនិង ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ក៏មិនបានទទួលដែរ។ អ្នកស្រាវជ្រាវត្រូវបញ្ចូលនិងផ្ទៀងផ្ទាត់រាល់ព័តិមានអំពីរ៉ែ ដែលទទួលបានពីប្រភពផ្សេងៗ រួមទាំងបទបង្ហាញសាធារណៈដោយតំណាងរដ្ឋាភិបាល កិច្ចសន្ទនាក្រៅផ្លូវការជាមួយមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកក្រុមហ៊ុនរ៉ែ ការសិក្សាស្រាវជ្រាវជាក់ស្តែងដែលមានរបាយការណ៍ថ្មីៗ និងកំណត់ត្រាជាសាធារណៈផ្សេងៗទៀត។ ជាលទ្ធផល ធ្វើអោយមានចន្លោះប្រហោងនូវទិន្នន័យមួយចំនួន ហើយក៏ជាការគូសបញ្ជាក់នូវតម្រូវការអោយមាន តម្លាភាព និងគណនេយ្យភាពក្នុងវិស័យឧស្សាហកម្មរ៉ែនៅកម្ពុជាផងដែរ។

---

[22] ជាឧទាហរណ៏ការសិក្សាស្រាវជ្រាវរបស់អង្គការអុកហ្វាមអាមេរិក ដោយមានការសហការជាមួយក្រសួងឧស្សាហកម្មរ៉ែនិងថាមពល បានលើកឡើងថាៈ ប្រជាពលរដ្ឋក្នុងតំបន់ និងអ្នករករ៉ែខ្លះ គ្មានឆន្ទៈក្នុងការផ្តល់ព័តិមានដល់ក្រុមអ្នកធ្វើអង្កេតដោយការភ័យខ្លាចរបស់ពួកគេពីការរំលោភបំពាន ពីកងកម្លាំងប្រដាប់អាវុធ ឬសន្តិសុខក្រុមហ៊ុនរ៉ែនៅក្នុងតំបន់។ ចំពោះករណីខ្លះទៀត កងកម្លាំងប្រដាប់អាវុធ ក្នុងតំបន់មិនអនុញ្ញាតឱ្យក្រុមអង្កេតទៅមើលទីតាំងរ៉ែមាសទេ។ សូមមើល Sieng Sotham, *Small-scale Gold Mining in Cambodia: A Situation Assessment*, Oxfam America, July 2004.

# ការពង្រីកឧស្សាហកម្មរ៉ែខេត្តមណ្ឌលគិរី
# និង ភូមិសិក្សាស្រាវជ្រាវ

តំបន់ភាគឦសាននៃប្រទេសកម្ពុជា ដែលក្នុងនោះមានខេត្តមណ្ឌលគិរីផងដែរ គឺជាស្រុកកំណើតដែលមានក្រុមជនជាតិដើមភាគតិចច្រើនក្រុមរស់នៅ។ រហូតមកដល់ទសវត្សរ៍ទី ១៩៨០ អ្នកធ្វើអាជីវកម្មរ៉ែជាជនជាតិខ្មែរមិនងាយបានចូល ដល់ទីនោះទេ។ មុននេះ ភូគព្ភវិទូជនជាតិបារាំងបានរកឃើញកន្លែងមានរ៉ែមាសចំនួន ១២ កន្លែង នៅប៉ែកបច្ចឹម និងពាយ័ព្យនៃប្រទេសកម្ពុជា ។ ការរកឃើញនៅក្នុងទសវត្សរ៍ទី ១៩៨០ នូវកន្លែងថ្មី មានរ៉ែមាសចំនួន ៧ កន្លែងទៀត នៅភាគឦសានប្រទេសកម្ពុជា ដែលនាំអោយជនជាតិខ្មែរនាំគ្នាសម្រុកទៅជីករកមាសដោយបុគ្គលក្នុងតំបន់នោះ។ រហូតមកដល់ឆ្នាំ២០០៤ គេដឹងថាមានរ៉ែមាសតែ ១៩ កន្លែងតែប៉ុណ្ណោះ នៅកម្ពុជា [២៣]។ ផ្នែកនេះចាប់ផ្តើមធ្វើការពិភាក្សាពីការពង្រីកសកម្មភាពរ៉ែទ្រង់ទ្រាយតូចនៅកម្ពុជា រួចគិតអំពីការពង្រីកពេលថ្មីៗនេះលើសកម្មភាពរុករករ៉ែរបស់ក្រុមហ៊ុនធំ នៅក្នុងខេត្តមណ្ឌលគិរី និងផលរបស់វា ចំពោះសិប្បករធនធានរ៉ែនៅក្នុងតំបន់សម្បទាន។ ផ្នែកនេះក៏ធ្វើការកត់សំគាល់ផងដែរទៅលើក្រុមហ៊ុន និងសមាគមសង្គមស៊ីវិល ដែលបានបង្កើតឡើងថ្មីៗនេះ ដើម្បីឆ្លើយតបទៅនឹងការធ្វើសកម្មភាពរ៉ែខ្នាតធំ។ ច្បាប់ស្តីពីការគ្រប់គ្រងរ៉ែនៅកម្ពុជា ក៏ធ្វើការពិភាក្សាច្រើនផងដែរ មុននិងពិនិត្យមើលជារួមលើ ផលប៉ះពាល់ពីសកម្មភាពរ៉ែលើសហគមន៍មូលដ្ឋាន ដែលភាគច្រើនជាជនជាតិដើមភាគតិច នៅក្នុងខេត្តមណ្ឌលគិរី។ បន្ទាប់មក ពិនិត្យមើលលំអិតពីសកម្មភាពពង្រីករ៉ែ នៅភូមិទាំងពីរដែលបានធ្វើការសិក្សាស្រាវជ្រាវ។

## ការពង្រីកសកម្មភាពរ៉ែទ្រង់ទ្រាយតូច

ការសិក្សាស្រាវជ្រាវរបស់អង្គការ អុកហ្វាមអាមេរិក ស្តីពីការធ្វើអាជីវកម្មរ៉ែមាសខ្នាតតូចនៅកម្ពុជា ធ្វើឡើងដោយសហការជាមួយ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដែលត្រូវបានបោះពុម្ព នៅខែកក្កដា ឆ្នាំ២០០៤ រួមមានករណីសិក្សាចំនួន ២ នៅភាគឦសាន នៃ ប្រទេសកម្ពុជា។ មកដល់ដំណាច់សម័យកាល នៃការធ្វើអាជីវកម្មផ្ទាល់ខ្លួន ការសិក្សានេះបានផ្តល់ព័ត៌មាន សំខាន់ៗ ស្តីពីឧស្សាហកម្មរ៉ែរបស់កម្ពុជា ដែលកំពុងតែស្ថិតក្នុងដំណាក់ការអន្តរកាល។ ការស្រាវជ្រាវនេះបាន បង្ហាញនិន្នាការជាច្រើន ដែលបានកើតឡើង ក្នុងវិស័យអាជីវកម្មរ៉ែនៅពេលនោះ។ និន្នាការទាំងនេះរួមមាន: ១-ចំនួនថយចុះនៃអ្នកជីករ៉ែដោយខ្លួនឯងដោយសារ ក្រុមហ៊ុនសម្បទានក្តោបក្តាប់យកអស់តំបន់រ៉ែ។ ២-មានការជីកយករ៉ែកាន់តែច្រើននិងមានភាពស្មុគស្មាញ។ ៣-ការប្រើបច្ចេកទេសយកមាសដោយប្រើជាតិគីមី និង៤-ការដែលក្រុមហ៊ុនសម្បទាន

---

[23] Sieng Sotham, *Small-scale Gold Mining in Cambodia.*

មិនគោរពតាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ ជាមួយរដ្ឋាភិបាល។ ការស្រាវជ្រាវនោះបានអំពាវនាវអោយ រដ្ឋាភិបាលពង្រឹងការអនុវត្តន៏ច្បាប់ ក្នុងការធ្វើសកម្មភាពរ៉ែ និងអោយក្រុមហ៊ុនរ៉ែ មានទំនួលខុសត្រូវក្នុង ដំណើរការសកម្មភាពរបស់គេ[២៤] ។

## ប្រភេទនៃអ្នកជីករ៉ែមាស

ការស្រាវជ្រាវរបស់អង្គការ អុកហ្វាម អាមេរិក រកឃើញនៅពេលស្រាវជ្រាវថា អ្នកជីករ៉ែមាសមាន ៤ ប្រភេទធំៗ គឺ អ្នកស្រុកមូលដ្ឋាន កម្មករក្រីក្រដែលធ្វើចំណាកស្រុក អ្នកជីករ៉ែចំណាកស្រុកដែលមានទ្រព្យធន និង ក្រុមហ៊ុនសម្បទាន។ អ្នកស្រុកមូលដ្ឋានច្រើន តែជាកសិករដែលរស់នៅជិតតំបន់ជីករ៉ែ ដែលពួកគេជីកមាស ដើម្បីរកចំណូលបន្ថែម។ ភាគច្រើន ពួកគេរែងមាសដោយដៃ ដោយមិនមានប្រើម៉ាស៊ីនទេ។ ពួកគេភាគច្រើនជាបុរស ធ្វើការនៅក្បែរភូមិ ហើយមិនចង់ទៅជីកកន្លែងណាឆ្ងាយទេ។ ក្នុងពេលថ្មីៗនេះ អ្នកស្រុកមូលដ្ឋានត្រូវបានជួលធ្វើការអោយអ្នកមាន ក្រុមហ៊ុនជីករ៉ែ និងក្រុមហ៊ុនសម្បទាន។

កម្មករចំណាកស្រុកក្រីក្រច្រើនតែជាអ្នកមិនមានដីធ្លី ដែលប្តូរទីតាំងជីករ៉ែ ពីមួយ ទៅទីតាំងជីករ៉ែមួយទៀត ដើម្បីរកជីកមាសចិញ្ចឹមជីវិត។ គេច្រើនធ្វើដំណើរជាគ្រួសារទាំងមូល ហើយមានទីតាំងពាក់កណ្តាលអចិន្ត្រៃយ៍ នៅក្នុងជុំវិញនៃកន្លែងជីកមាស។ កម្មករចំណាកស្រុកទាំងនេះធ្វើការពេញមួយឆ្នាំ ដោយសមាជិកគ្រួសារទាំងអស់ជីកមាស រួមទាំងកូនផង។ គេពឹងផ្អែកលើឧបករណ៍កាន់ដោយដៃ និងឧបករណ៍ធ្វើដោយខ្លួនឯងសម្រាប់បំបែកថ្ម និងរែងចំរោះ។

អ្នកជីករ៉ែចំណាកស្រុកដែលមានទ្រព្យធន រស់នៅតាមទីប្រជុំជនស្រុកនិងខេត្ត ហើយជួលអ្នកមូលដ្ឋាន ឬ កម្មករចំណាកស្រុកអោយធ្វើការអោយគេ។ តាមធម្មតា សកម្មភាពរបស់គេមានប្រើម៉ាស៊ីន និងឧបករណ៍ ដូចជា ប្រដាប់បំបែកថ្ម និងរែងចំរោះ ដែលជាការនាំអោយគេអាចជីកមាសបានច្រើនជាងអ្នកក្នុងមូលដ្ឋាន និងអ្នកធ្វើចំណាកស្រុកក្រីក្រ។ អាជីវកម្មជីករ៉ែរបស់អ្នកមានទ្រព្យ ពេលខ្លះមានការការពាររបស់អាជ្ញាធរមូលដ្ឋាន ឬកងកំលាំងប្រដាប់អាវុធ។ ក្នុងករណីដែលរ៉ែមាសស្ថិតនៅក្នុងតំបន់សម្បទាន ពួកអ្នកជីករ៉ែដែលមានទ្រព្យបានបង់ប្រាក់អោយសម្បទានិក ដើម្បីបានជីករ៉ែនៅទីនោះ។

សម្បទានិកទទួលបានអាជ្ញាប័ណ្ណពីរដ្ឋាភិបាល ហើយប្រើសិទ្ធិផ្តាច់មុខ ដើម្បីរុករក និងធ្វើអាជីវកម្មរ៉ែធម្មជាតិនៅក្នុងតំបន់កំណត់។ តាមធម្មតា សម្បទានិកបង្កើតការិយាល័យនៅតាមការដ្ឋានយករ៉ែ ហើយជួលអ្នកស្រុក និងអ្នកធ្វើចំណាកស្រុកក្នុងការជីករ៉ែ។ ពេលខ្លះ សម្បទានិកផ្តល់ការ អនុញ្ញាតឱ្យអ្នកជីករ៉ែដែលមានទ្រព្យទាំងនោះ ធ្វើអាជីវកម្មក្នុងតំបន់របស់គេ ដោយបង់ប្រាក់កំរៃ។

[24] Sieng, *Small-scale Gold Mining in Cambodia.*

ច្បាប់ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ចាត់ទុករាល់សកម្មភាពរ៉ែណា ដែលគ្មានអាជ្ញាប័ណ្ណគឺជាការខុសច្បាប់។ នៅពេលក្រុមហ៊ុនអនុវត្តសិទ្ធិផ្តាច់មុខរបស់គេនៅក្នុងតំបន់រ៉ែ អ្នកជីករ៉ែផ្ទាល់ខ្លួន ទាំងអ្នកនៅក្នុងស្រុកនិងអ្នកចំណាកស្រុក ត្រូវបានហាមឃាត់មិនអោយចូលតំបន់ទាំងនោះដើម្បីជីករ៉ែទៀតឡើយ។ ដូចត្រូវបានរៀបរាប់ក្នុងរបាយការណ៍របស់អង្គការអុកហ្វាមថា "នៅពេលដំបូងៗ អ្នកណាក៏អាចជីករ៉ែមាសបានដែរ អោយតែដឹង និងមានគ្រឿងឧបរណ៍។ តែនៅពេល មានសម្បទានរ៉ែផ្តល់អោយក្រុមហ៊ុនធំៗ ដោយរដ្ឋាភិបាល មានករណីភាគច្រើនអ្នកស្រុកមិនត្រូវបានគេអនុញ្ញាតឱ្យចូលទៅ តំបន់រ៉ែនិងជីដូនតារបស់គេឡើយ [២៥]។

## វិធីយករ៉ែ

ការសិក្សារបស់អង្គការអុកហ្វាមអាមេរិកបានកំណត់ថា ការជីករណ្តៅចំហ និងការលុងរណ្តៅចំហៀងថាជាវិធីពីរចំបងក្នុងការយករ៉ែមាសនៅប្រទេសកម្ពុជា។ វិធីសាស្ត្រដែលត្រូវបានប្រើ អាស្រ័យលើទីតាំងដែលមានរ៉ែមាស។ គេប្រើឧបករណ៍ក្នុងស្រុកក្នុងការយោងរ៉ែនិងកម្ទករចេញពីបាតរណ្តៅរ៉ែ។ គេប្រើឈើទល់នៅក្នុងរណ្តៅលុងចំហៀង ដើម្បីកុំអោយបាក់ដីសង្កត់។ ការស្រាវជ្រាវបានបង្ហាញថា មានការជីកយករ៉ែ កាន់តែជ្រៅទៅ ហើយកន្លែងខ្លះមានរហូតដល់ជំរៅ ៨០ ម៉ែត្រ។

សកម្មភាពជីកយករ៉ែបាននាំអោយខូចទេសភាព។ រណ្តៅត្រូវបានទុកអោយនៅចំហ ហើយអាចនាំមកនូវគ្រោះថ្នាក់សម្រាប់សត្វនិងមនុស្ស ដោយការធ្លាក់ចូលក្នុងរណ្តៅ។ ការកាប់បំផ្លាញព្រៃឈើក៏កើតមានផងដែរ ដោយសារការជំរះដីសំរាប់ជីករ៉ែ និងយកឈើទល់រណ្តៅ។

## បច្ចេកទេសក្នុងការរែងយករ៉ែមាស

ការស្រាវជ្រាវរបស់អង្គការអុកហ្វាមអាមេរិក បានកត់សំគាល់ឃើញថា នៅប្រទេសកម្ពុជា គេប្រើវិធីបីយ៉ាងក្នុងការញែកយកមាសចេញពីរ៉ែគឺការបាញ់ទឹកហើយរែង ការស្លជាមួយជាតិបារ៉ត និងការលាងជាមួយជាតិគីមីដែលមានសារធាតុពុល។ ចំពោះវិធីទី១ គេកិនបំបែករ៉ែអោយខ្ទេចផង ដោយប្រើប្រដាប់បំបែកថ្មរួចហើយរែង យកមាសដែលធ្លាក់ទៅក្រោម។ បន្តិចម្តងៗ គេលែងប្រើវិធីបែបបុរាណនេះ ហើយបែរមកប្រើបច្ចេកទេសដោយ ប្រើជាតិគីមីវិញដែលអាចទាញយកមាសបាន ទោះមានតិចតួចក៏ដោយ។ វិធីពីរយ៉ាងចុងក្រោយនេះគឺជាវិធីដែលប្រើជាតិគីមីពុលខ្លាំង ដែលអាចប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន បើសិនជាមិនប្រើអោយបានត្រឹមត្រូវទេនោះ។ ការស្រាវជ្រាវនោះ បានកត់សំគាល់ឃើញការប្រើប្រាស់ជាតិគីមីនោះ មិន

[25] Sieng, *Small-scale Gold Mining in Cambodia.*

បានសមស្រប នៅកន្លែងយករ៉ែ ដែលបាននាំអោយមានការបំពុលបរិស្ថាន ការបាត់បង់ជីវិតមនុស្ស សត្វពាហនៈ សត្វព្រៃ និងត្រី។

ក្នុងចំណោមបច្ចេកទេសដែលប្រើជាតិគីមី អ្នកស្រាវជ្រាវបានកត់សំគាល់ឃើញថាមានការប្រើវិធីលាងជាមួយជាតិគីមីដែលមានសារធាតុពុល ច្រើនជាងវិធីស្លជាមួយជាតិបារ៉ត។ ការលាងជាមួយ ជាតិគីមីដែលមានសារធាតុពុលមានប្រសិទ្ធភាព ច្រើនជាង ហើយអ្នកធ្វើអាជីវកម្មធំ និងក្រុមហ៊ុនប្រើវិធីនេះ ដែលនាំអោយងាយយកអស់រ៉ែមាសល្អៗ។

## ការគោរពតាមកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ

ការស្រាវជ្រាវរបស់អង្គការអុកហ្វាមអាមេរិក គូសបញ្ជាក់ថា ក្រុមហ៊ុនដែលបានទទួលអាជ្ញាប័ណ្ណ ពីរដ្ឋាភិបាលមិនមែនសុទ្ធតែគោរពតាមខ្លឹមសារ នៅក្នុងកិច្ចព្រមព្រៀងទេ។ ឧទាហរណ៍ ក្រុមហ៊ុនភាគច្រើន ធ្វើសកម្មភាព ក្រោមការអនុញ្ញាតអោយធ្វើការរុករក តែគេទារលុយដោយខុសច្បាប់ពីអ្នកដែលធ្វើអាជីវកម្ម លើធនធានរ៉ែ នៅក្នុងតំបន់សម្បទានរបស់គេ។ ទន្ទឹមនឹងនោះ បទដ្ឋានសុវត្ថិភាព សុខភាព និងបរិស្ថានដែលមាននៅក្នុងកិច្ចព្រមព្រៀង ដើម្បីការពារកម្មករ និងសហគមន៍មូលដ្ឋាន ជាញឹកញាប់ មិនត្រូវបានគេគោរព។ ការសិក្សានោះ បានសុំអោយរដ្ឋាភិបាលប្រកាន់យកជំហានធ្វើយ៉ាងណាអោយក្រុមហ៊ុនសម្បទាន គោរពតាមលក្ខខណ្ឌ ក្នុងកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ និង ធ្វើតាមបទដ្ឋាននៃសកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវ។

## ការពង្រីកសកម្មភាពរ៉ែទ្រង់ទ្រាយធំរបស់ក្រុមហ៊ុន

របាយការណ៍របស់អង្គការ អុកហ្វាមអាមេរិក ស្តីពីអាជីវកម្មរ៉ែមាសទ្រង់ទ្រាយតូច បានសង្កេតឃើញថា មិនដូចក្នុងប្រទេសដទៃទេ ឧស្សាហកម្មរ៉ែនៅក្នុងប្រទេសកម្ពុជាច្រើនធ្វើដោយក្រុមហ៊ុនខ្មែរ ចិន ឬ កូរ៉េ ចំណែកក្រុមហ៊ុនរ៉ែធំៗ មិនមានវត្តមានទេ។ មិនយូរប៉ុន្មាន ស្ថានភាពនេះត្រូវបានផ្លាស់ប្តូរ។ ពីឆ្នាំ ២០០៦ ក្រុមហ៊ុនរ៉ែធំៗ និង ក្រុមហ៊ុនរួមភាគហ៊ុនជាច្រើនរបស់អូស្ត្រាលី ដូចជា ក្រុមហ៊ុន BHP Billiton និង Misubishi Coroporation, Oz Minerals, Southern Gold និង Transol បានទទួល អាជ្ញាប័ណ្ណរ៉ែ ដើម្បីរុករករ៉ែលើផ្ទៃដីធំៗ ក្នុងខេត្តមណ្ឌលគីរី ដើម្បីរកមាស បុកស៊ីដ និងរ៉ែដទៃទៀត (រូបទី២)។ មកដល់ខែកក្កដា ឆ្នាំ២០០៨ មុនក្រុមហ៊ុន BHP Billiton និង Misubishi Coroporation ដកចេញទៅ មានក្រុមហ៊ុនរ៉ែចំនួន ១៥ បានកាន់អាជ្ញាប័ណ្ណរុករករ៉ែលើផ្ទៃដីសរុប ៤ ៤៧៣ គ.ម$^{២}$. ឬ ៣១ ភាគរយ នៃផ្ទៃដី

**រូបទី ២: ក្រុមហ៊ុនមានអាជ្ញាប័ណ្ណរ៉ែ ដែលបានស្គាល់ នៅខេត្តមណ្ឌលគិរី រាប់ពីខែកក្កដា ឆ្នាំ២០០៨**

| ក្រុមហ៊ុន | ម្ចាស់ | ទីកន្លែង (ស្រុក) | ឆ្នាំផ្តល់អាជ្ញាប័ណ្ណ | ទំហំដី (គ.ម $^{២}$.) |
|---|---|---|---|---|
| Anquing Cambodian Investment Company Co,Ltd | ចិន | កែវសីមា | 2006 | 216 |
| AZ Distribution Co, Ltd* | ខ្មែរ | អូររាំង | 2005 | |
| BHP Billiton World Exploration Inc and Mitsubishi Corporation** | អូស្ត្រាលី<br>ជប៉ុន | សែនមនោរម្យ<br>ពេជ្រាដា<br>អូររាំង<br>កែវសីមា | 2006 | 996 |
| CAMBO CANAKIRI Development Limited | | ពេជ្រាដា | 2006 | 160 |
| Cambodia Hai Lan Mineral Company Limited | ចិន | កែវសីមា | 2004 | 80 |
| Chin Siv Nginh CSN Cambodia Import Export | | កែវសីមា | 2006 | 216 |
| China Forwin International Investment Phnom Penh Mining Co, Ltd*** | ចិន | កែវសីមា | 2006 | 112 |
| D&Z Investment Co, Ltd | | កោះញែក | 2006 | 156 |
| Gold Metal Group Co, Ltd | វៀតណាម | ពេជ្រាដា | 2006 | 158 |
| Liberty Mining International Pty Ltd.**** | អូស្ត្រាលី | កែវសីមា | 2008 | 62 |
| Maxum Metal Pty Ltd.**** | អូស្ត្រាលី | កែវសីមា<br>ពេជ្រាដា<br>អូររាំង<br>សែនមនោរម្យ | 2008 | 823 |
| Moeung Sok | | ពេជ្រាដា | 2006 | 204 |
| Oksan Cambodia Inc | កូរ៉េ | កែវសីមា | 2003 | 84 |
| Oz Minerals***** និង Shin Ha Mining Company | អូស្ត្រាលី | កែវសីមា | 2007 | 439 |
| Sonuba Paul Cham Co, Ltd.* | ខ្មែរ | អូររាំង | 2004 | 271.5 |
| Southern Gold Ltd | អូស្ត្រាលី | កែវសីមា | 2007 | 274 |
| Summer Gold Investment PVT Ltd | | កែវសីមា | 2005 | 202 |
| Zhong-Xin Industry Investment Cambodia Co | ចិន | កែវសីមា | 2007 | 19.6 |

*Ownd by BHP Billiton and Mitsubishi
**BHP Billiton and Mitsubishi reportedly withdrew from their concession in the second half of 2009.
***China Forwin reportedly withdrew from Cambodia after a Chinese expert died of malaria.
****Owned by Transol Corporation
*****Oz Minerals was established in July 2008 as the result of a merger between Oxiana Limited and Zinifex.

Sources: Pearl Beaumont, *Extractive Industry Mining Study, Social and Environmental Impacts, Ratanakiri & Mondulkiri*, Development and Partnership in Action, July 2008. NGO Position Paper, *Environmental and Social Impacts of Expansion of the Extractive Industries Sector;* Kinetz and Yun, “Mining Companies, Villagers Vie for Gold in Mondulkiri Province”; and Lazarus, Kate A., *In Search of Aluminum: China’s Role in the Mekong Region*, Heinrich Boll Stiftung Cambodia, WWF Denmark, and the International Institute for Sustainable Development, 2009.

១៤ ២៨៨ គ.ម$^{២}$. នៅក្នុងខេត្តមណ្ឌលគិរី (រូបទី៣)[26]។ ការប្តូរពីសិប្បករធនធានរ៉ែ ទៅជាសម្បទានិកតូចៗ ជិតឈានដល់ដំណាក់កាលចុងក្រោយ ហើយយុគសម័យថ្មីនៃការរុករករ៉ែដោយក្រុមហ៊ុនអន្តរជាតិធំៗ បានចាប់ផ្តើមឡើង។ នៅពេលថ្មីៗនោះដែរ ការរុករករ៉ែរបស់ក្រុមហ៊ុនរ៉ែធំៗ នៅតាមទីតាំងដែលមានតម្លៃខ្ពស់ បានបង្កឱ្យមានការ លេចឡើងវិញនូវសិប្បកម្មធនធានរ៉ែ ដែលនិងពិភាក្សាវែកញែកលើភាពស្របច្បាប់សម្រាប់សិប្បកម្មធនធានរ៉ែនេះ។

### រូបទី៣: ផែនទីតំបន់សម្បទានរ៉ែក្នុងខេត្តមណ្ឌលគិរី




*ប្រភព*: World Wide Fund for Nature (WWF) *Livelihood Sustainability Analysis in Mondulkiri Province*, Phnom Penh: WWF Greater Mekong-Cambodia Country Program, 2008.

[26] និន្នាការប្រហាក់ប្រហែលគ្នាក៏ស្តែងឡើងក្នុងខេត្តរតនគិរីផងដែរ។ នៅខែសីហា ឆ្នាំ២០១០ អាជ្ញាធរខេត្តរតនគិរីបានផ្តល់ទិន្នន័យដែលបង្ហាញថា៤០ភាគរយនៃផ្ទៃដីខេត្ត ឬប្រហែលជា ៤ ៤០០ គ.ម$^{២}$. ត្រូវបានផ្តល់អាជ្ញាប័ណ្ណរុករករ៉ែឆ្នាំថ្មីៗនេះ ដល់ក្រុមហ៊ុនចំនួន១០ សូមមើល Neou Vannarin and Paul Vrieze, “Ten Mining Firms Exploring 40 Percent of R’kiri,” *The Cambodia Daily*, 3 August 2010.

## សិប្បករធនធានរ៉ែស្ទើរតែបានបញ្ចប់ក្នុងការសម្រុករករ៉ែនៅខេត្តមណ្ឌលគិរី

នៅខែមិថុនា ឆ្នាំ២០១០ មន្ត្រីស្រុកកែវសីមា ខេត្តមណ្ឌលគិរីបានបញ្ជាអោយសិប្បករធនធានរ៉ែចេញពីតំបន់រ៉ែនៅ អូរខ្វាវ អូរចុងដែលក្រុមហ៊ុន Oz Mineral បង្ហាញជាដំបូងថា មានធនធានរ៉ែមាស ៦០៥ 000 អោន ហើយអាចមានរហូតដល់ ២ លានអោន។ សិប្បករធនធានរ៉ែមានពីខេត្តកំពង់ចាម ក្រចេះ កំពង់ធំ ស្វាយរៀង និងខេត្តព្រៃវែង ដែលមានចំនួនប្រហែល ៤៥ ទៅ ៦៩គ្រួសារ។ មន្ត្រីស្រុក កែវសីមាបានអះអាងថា សិប្បករធនធានរ៉ែ បានចូលមកក្នុងតំបន់នៅឆ្នាំ ២០០៦ បន្ទាប់ពីក្រុមហ៊ុន Oz Mineral ទទួលបានសម្បទាន ខណៈដែលអ្នកសម្របសម្រួលអង្គការអាដហុកប្រចាំខេត្តបានអះអាងថា អ្នករករ៉ែមកមុនពេលនោះ គឺចន្លោះឆ្នាំ២០០២និង ២០០៤។ មន្ត្រីស្រុកកែវសីមាមានគំនិតក្នុងការពង្រាយ កំលាំងសន្តិសុខដើម្បីបណ្តេញពួកគេទាំងនោះ។ ពួកគេក៏មានគំនិតកាត់ផ្តាច់នូវការផ្គត់ផ្គង់ជាតិគីមីសម្រាប់រែងមាស និងពិចារណាក្នុងការដាក់ ពាក្យបណ្តឹងទៅតុលាការខេត្តចោទប្រកាន់គ្រួសារទាំងនោះពីបទមិនមានអាជ្ញាប័ណ្ណសមស្រប [២៧]។

ខណៈដែលអ្នករករ៉ែមានការគំរាមកំហែង មានសេចក្តីរាយការណ៍ថា អ្នករករ៉ែបានដាក់ពាក្យទៅអាជ្ញាធរមូលដ្ឋានដើម្បីទទួលបានអាជ្ញាប័ណ្ណសមស្រប។ ស្ត្រីម្នាក់បានថ្លែងថា " ក្រុមហ៊ុនធំនិងមានលុយច្រើនមកពីបរទេសនិងក្នុងស្រុកគេផ្តល់អាជ្ញាប័ណ្ណអោយ ហេតុអីបានជាយើងអ្នករករ៉ែមាសតូចតាច ហើយអ្នករករ៉ែផ្សេងទៀតគេហាមឃាត់?[២៨] " ជាក់ស្តែង ច្បាប់រ៉ែឆ្នាំ២០០១ បានបង្ហាញពីការផ្តល់អាជ្ញាប័ណ្ណដល់សិប្បករធនធានរ៉ែដែរ (មាត្រា១១,១)តែមានភាពមិនជាក់លាក់ តើសិប្បករធនធានរ៉ែនោះត្រូវអនុវត្តតាមលក្ខខណ្ឌអ្វីខ្លះ និងយ៉ាងដូចម្តេច ទៅតាមច្បាប់ដើម្បីវាស់វែងដូចជា ការសិក្សាពីលទ្ធភាព ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និង ផែនការសុវត្ថិភាពសាធារណៈ [២៩]។

វាគ្មិនម្នាក់បានពន្យល់នៅក្នុងសន្និសីទអន្តរជាតិស្តីពីរ៉ែថា នៅពេលដែលប្រទេសអាស៊ានមួយចំនួនទទួលស្គាល់ភាពស្របច្បាប់របស់អ្នករករ៉ែខ្នាតតូចសម្រាប់សិប្បកម្មធនធានរ៉ែ គឺជារឿយៗត្រូវគេចាត់ទុកថាខុសច្បាប់ [៣០]។ នៅក្នុងសន្និសីទអន្តរជាតិ ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលបានប្រកាសផងដែរ ថា សិប្បកម្មធនធានរ៉ែខុសច្បាប់ នៅក្នុងតំបន់សម្បទាននឹងត្រូវបញ្ឈប់ ទោះបីជាគាត់ព្រម

---

[27] Kutch Naren and Simon Marks, "Artisan Miners Told to Leave OZ Miners Site," *The Cambodia Daily*, 22 June 2010; Marks, Simon and Kuch Naren, "Seeking Legalization, Miners Face Uphill Battle," *The Cambodia Daily*, 3-4 July 2010.

[28] Marks and Kuch, "Seeking Legalization, Miners Face Uphill Battle."

[29] ច្បាប់រ៉ែមាត្រា១១ (១) ចែងថា "អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែអាចផ្តល់ឱ្យចំណោះតែប្រជាពលរដ្ឋខ្មែរប៉ុណ្ណោះ ក្នុងគោលបំណងអនុវត្តការងារស្វែងរុករកនិងធ្វើអាជីវកម្មធនធានរ៉ែដោយប្រើប្រាស់ឧបករណ៍សម្ភារៈសាមញ្ញដែលមាននៅក្នុងមូលដ្ឋាន ហើយប្រើប្រាស់កម្លាំងផ្ទាល់ខ្លួន ឬជាលក្ខណៈគ្រួសារដែលមានចំនួនមិនលើសពី៧ (ប្រាំពីរ) នាក់ "។

[30] Spiegel, Samuel, "Governance Approaches in Artisanal Gold Mining Communities: Supporting Livelihoods and Enhancing Social Opportunities in the Asia Pacific Countries," Presentation made at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

អោយមានដំណោះស្រាយមួយដែលអាចផ្តល់ភាពស្របច្បាប់ ក្នុងការធ្វើរ៉ែនៅតំបន់មានសក្តានុពលតិច និងត្រូវចងក្រងគ្នាជាក្រុមសហគមន៍រ៉ែខ្នាតតូច [៣១]។ បញ្ហាលេចឡើងនៅក្នុងស្រុកកែវសីមាគឺថា តើគ្រួសារសិប្បករធនធានរ៉ែ ដែលបច្ចុប្បន្នស្ថិតក្នុងតំបន់សម្បទានក្រុមហ៊ុន Oz Mineral ទាំងនោះ គួរមិន ឬទទួលបានសំណងសមស្របឬយ៉ាងណា មុនពេលគេបង្ខំឱ្យចាកចេញពីតំបន់នោះ [៣២]។

ការឆ្លើយតបដែលមានទំនួលខុសត្រូវដល់សិប្បករធនធានរ៉ែនៅខេត្តមណ្ឌលគិរីគឺមិនមែនងាយឡើយ។ ការសិក្សារបស់អង្គការអុកហ្វាមអាមេរិក បញ្ជាក់យ៉ាងច្បាស់ថា គ្រោះថ្នាក់ផ្នែកបរិស្ថានបង្កដោយអ្នករករ៉ែខ្នាតតូចដែលប្រើប្រាស់នូវបារ៉ត និងជាតិគីមីដែលមានសារធាតុពុលក្នុងបច្ចេកទេសចំរោះ។ ការសិក្សាបានកត់សំគាល់ផងដែរថា ការបំផ្លាញផ្ទៃដីរ៉ែមាសស្រទាប់លើ បាននាំឱ្យកើតមានរណ្តៅជ្រៅនិងកាន់តែគ្រោះថ្នាក់។ ខណៈដែលអ្នករុករករ៉ែខ្នាតតូចនៅខេត្តមណ្ឌលគិរី ហាក់ដូចជាថយចុះក្នុងទសវត្សរ៍ចុងក្រោយនេះ លទ្ធភាពនៃការរករ៉ែ ដោយក្រុមហ៊ុនធំៗនៅតំបន់សំបូររ៉ែ អាចនាំអោយលេចឡើងវិញនូវសិប្បកម្មធនធានរ៉ែដែរ។ ចំណែក ទីប្រឹក្សាផ្នែកឧស្សាហកម្មនីសារណៈកម្ម នៃគម្រោងអភិវឌ្ឍន៏សហប្រជាជាតិនៅកម្ពុជា បានលើកឡើងថា សិប្បកម្មធនធានរ៉ែ ជាប្រភពចំណូលសំខាន់មួយ ហើយអាចជាឱកាសសេដ្ឋកិច្ចមួយផ្នែកសម្រាប់គ្រួសារមួយចំនួន ហើយបានបន្ថែមថា ដំណោះស្រាយរយៈពេលខ្លីដូចជាការបណ្តេញចេញ គឺជាមធ្យោបាយមួយដែលមិនទទួលជោគជ័យនៅជុំវិញពិភពលោក [៣៣]។

គំនិតខាងលើមានការឆ្លុះគ្នាទៅនឹងបទបង្ហាញនៅក្នុងសន្និសីទអន្តរជាតិ ដែលលើកឡើងថា អាហ្វ្រិកជាឧទាហរណ៍នៃរបៀបដែលក្រុមហ៊ុនធំ បានប្រកាន់យកនូវទម្លាប់រកស៊ីដែលផ្តល់ឱកាសឱ្យអ្នកដទៃទៀតដែរជាជាងការប្រើប្រាស់កំលាំងប៉ូលីសក្នុងការបញ្ឈប់សិប្បកម្មធនធានរ៉ែ [៣៤]។ ចំណែកឯវាគ្មិនផ្សេងទៀតអះអាងថា កំរិតជីវភាព រស់នៅសម្រាប់អ្នករករ៉ែខ្នាតតូចនៅតែខ្ពស់នៅពេលដែលមានការផ្តល់បច្ចេកទេសធ្វើមាសសមស្រប និងការដាក់បញ្ចូលអ្នករករ៉ែទាំងនោះ ចូលក្នុងវិស័យផ្លូវការជាលក្ខណៈសហករ និងកម្មវិធីពាណិជ្ជកម្ម [៣៥]។ វាគ្មិនទីបីមានមតិគាំពារ អោយប្តូរអ្នកដែលមានជីវភាពពឹងផ្អែកលើសិប្បកម្មធនធានរ៉ែពីធ្វើការខុសច្បាប់ទៅជា ផ្នែកក្រៅផ្លូវការវិញ។ វាគ្មិនរូបនោះបានផ្តល់ជា អនុសាសន៏ក្នុងការពិនិត្យឡើងវិញនូវគោលនយោបាយរដ្ឋនិងស្ថាប័ន ធានាឱ្យបាននូវនិតិវិធីច្បាប់សម្រាប់ផ្តល់នូវផលប្រយោជន៏ជាក់ស្តែង និងរៀបចំគម្រោងដើម្បីភ្ជាប់ទំនាក់ទំនងឱ្យសកម្មចូលរួម ជាមួយអ្នករករ៉ែ ក្រៅផ្លូវការទាំងនោះ [៣៦]។

---

[31] H.E. Suy Sem, "Closing Speech."
[32] Marks, Simon, "NGOs Appeal for Resolution at Oz Minerals Gold Mine Site," *The Cambodia Daily*, June 2010.
[33] Marks and Kuch, "Seeking Legalization, Miners Face Uphill Battle."
[34] Lahiri-Dutt, "The People Dimension of Mining."
[35] Ali, Saleem H., "Developing Cambodia's Mining Sector: An Environmental Perspective," Paper presented at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.
[36] Spiegel, "Governance Approaches in Artisanal Gold Mining Communities."

## អ្នករករ៉ែ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការបង្កើតសមាគមដើម្បីឆ្លើយតបនឹងសកម្មភាពរ៉ែខ្នាតធំ

នៅពេលដែលមានបញ្ហាចំរូងចំរាស់គ្នាពីសិប្បករធនធានរ៉ែ នៅស្រុកកែវសីមា មានតំណាងមកពីសាជីវកម្មរ៉ែនិង សមាគមសង្គមស៊ីវិលបង្ហាញនូវទស្សនៈផ្សេងគ្នាពីបញ្ហាដែលលេចឡើងនេះ [៣៧]។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ ដោយសារការកើនឡើងនូវការរុករករ៉ែទ្រង់ទ្រាយធំនៅកម្ពុជាបានធ្វើឱ្យសមាគមសង្គមស៊ីវិល និងក្រុមហ៊ុនសាជីវកម្មកំពុងតែលើកកំពស់លើវិស័យនេះ ដើម្បីជាប្រយោជន៍រៀងៗខ្លួន។ ការផ្តួចផ្តើមគំនិតទាំងនេះ គឺដើម្បីជួយឱ្យមានការចូលរួមរបស់សាជីវកម្មរ៉ែ និងសង្គមស៊ីវិល ជាមួយរដ្ឋាភិបាលក្នុងការជជែក និងពិភាក្សាវែកញែកលើការរៀបចំ និងអនុវត្តច្បាប់រ៉ែដែលមានទំនួលខុសត្រូវ។ ក្រុមទាំងនោះមាន សមាគមកម្ពុជាសម្រាប់ក្រុមហ៊ុនរុករកនិងធ្វើអាជីវកម្មរ៉ែ (CAMEC) កម្ពុជាសម្រាប់តម្លាភាពចំណូលធនធាន (CRRT) និង បណ្តាញផលប៉ះពាល់សង្គមនិងបរិស្ថាន ដោយឧស្សាហកម្ម និស្សារណៈកម្ម (EISEI)។

## សមាគមកម្ពុជាសម្រាប់ក្រុមហ៊ុនរុករក និងធ្វើអាជីវកម្មរ៉ែ

សមាគមកម្ពុជាសម្រាប់ក្រុមហ៊ុនរុករក និងធ្វើអាជីវកម្មរ៉ែ (CAMEC) គឺជាសមាគមមួយរបស់ក្រុមហ៊ុនរុករករ៉ែដែលបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មក្នុងខែមករា ឆ្នាំ២០១០ ដោយមានបេសកកម្ម "ដើម្បីជួយអភិវឌ្ឍ លើការរុករករ៉ែ និងការទាញយករ៉ែ និងប្រតិបត្តិការទៅតាមបទដ្ឋានអន្តរជាតិ ដែលត្រូវបានទទួលស្គាល់ និងគោរពពីគ្រប់អ្នកពាក់ព័ន្ធ។ គោលការណ៍របស់សមាគមនេះ ដើម្បីបង្ហាញដល់រាជរដ្ឋាភិបាលពីការព្រួយបារម្ភលើបញ្ហាដែលប្រឈមឧស្សាហកម្មរ៉ែនិង ស្វែងរកសំលេងគាំទ្រ ក្នុងការផ្លាស់ប្តូរជាសំខាន់ចំពោះច្បាប់ និង គោលនយោបាយទាំងចាស់និងថ្មី ដែលមានឥទ្ធិពលដល់វិស័យរ៉ែ។ សមាជិក CAMEC រួមមាន Oz Minerals, Liberty Mining International, Southern Gold, Indochine Resources Cambodia, Cambodian Resources Limited, Kingdom Resources, and Prairie Pacific Mining.

CAMEC ជាសមាជិកនៅក្នុងក្រុមការងាររវាងរដ្ឋាភិបាល-វិស័យឯកជន ដែលទទួលបន្ទុកលើច្បាប់ពន្ធដារ និង អភិបាលកិច្ចល្អ ដែលមានសហប្រធាន ឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ។ ប្រធាន CAMEC រំលឹកដែរថា គោលបំណងមួយដ៏សំខាន់ក្នុងចំណោមគោលបំណងដ៏ទៃទៀត របស់សមាគមគឺចង់បានការលើកទឹកចិត្តទៅលើការបង់ពន្ធ ពោលគឺកាត់បន្ថយពន្ធនាំចូល សម្ភារៈប្រើប្រាស់ក្នុងការរុករករ៉ែ។ ប្រធាន CAMEC ក៏ចង្អុលបង្ហាញដែរថា ក្រុមហ៊ុនត្រូវការផ្នែកច្បាប់ក្នុងការធានាថា ក្រុមហ៊ុនមានសិទ្ធិធ្វើអាជីវកម្មរ៉ែបានបន្ទាប់ពីបានចំណាយទុនយ៉ាងច្រើន ក្នុងការរុករកស្រាវជ្រាវនៅគ្រាដំបូង និង ឱ្យមានច្បាប់ជាក់លាក់ទាក់ទងទៅនឹង ថាតើក្រុមហ៊ុននឹងបែងចែកភាគផលក៏រិតណា។ អនុប្រធាន CAMEC ទទួលស្គាល់ថា

---

[37] Marks and Kuch, "Seeking Legalization, Miners Face Uphill Battle" and Marks, "NGOs Appeal for Resolution at Oz Minerals Gold Mine Site."

សមាគមមិនទាន់មានគោលជំហររួមគ្នាមួយលើគោលការណ៍ការពារបរិស្ថាន និង ការផ្លាស់ប្តូរទៅលំនៅដ្ឋានរបស់ប្រជាពលរដ្ឋនៅឡើយ [៣៨]។

## កម្ពុជាសម្រាប់តម្លាភាពចំណូលធនធាន

កម្ពុជាសម្រាប់តម្លាភាពចំណូលធនធាន (CRRT) បានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃនៅខែមេសា ឆ្នាំ២០០៩ ដោយអង្គការមួយក្រុម ដើម្បីពិនិត្យមើលលើចំណូលពីវិស័យឧស្សាហកម្មនិស្សារណៈកម្មដូចជា ប្រេង ហ្គាស និងរ៉ែ។ ទស្សនៈវិស័យរបស់ CRRT គឺចង់ឃើញធនធានដែលបានមកពី វិស័យឧស្សាហកម្មនិស្សារណៈកម្ម ឱ្យមានការគ្រប់គ្រង ប្រកបដោយទំនួលខុសត្រូវសង្គមដែលមានតម្លាភាព គណនេយ្យភាព និងមានការចូលរួម ដើម្បីឱ្យមានសមភាពផលប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់រូប។ សមាជិកបណ្តាញ មានការជឿជាក់លើបីចំនុចសំខាន់ៗ ទី១ សាធារណៈជនត្រូវទទួលបានព័ត៌មានគ្រប់គ្រាន់ ដើម្បីចូលរួមពិភាក្សាជាចំហរ ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រងចំណូលហិរញ្ញវត្ថុ ពីវិស័យឧស្សាហកម្មនិស្សារណៈកម្ម។ ទី២ ផ្តល់ព័ត៌មានទូលំទូលាយពីប្រតិបត្តិការអាជីវកម្មធនធាន និស្សារណៈកម្ម និង ចំណូល ដើម្បីងាយស្រួល ដល់ការជួយឃ្លាំមើលជាសាធារណៈ លើវិស័យឧស្សាហកម្មនិស្សារណៈកម្ម និងទី៣ ចំណូលពីវិស័យឧស្សាហកម្ម និស្សារណៈកម្មគួរតែប្រើប្រាស់អោយបានត្រឹមត្រូវនិងមានប្រសិទ្ធភាពដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ទាំងបច្ចុប្បន្ន និងអនាគត។

CRRT ជម្រុញឱ្យរដ្ឋាភិបាលចូលរួមជាមួយស្ថាប័ន គំនិតផ្តួចផ្តើមដើម្បីតម្លាភាព ឧស្សាហកម្មនិស្សារណៈកម្ម (EITI) ដែលជាសម្ព័ន្ធរដ្ឋាភិបាល អ្នកវិនិយោគ សង្គមស៊ីវិល និងស្ថាប័នពហុភាគីជាច្រើន ក្នុងគោលបំណងពង្រឹង អភិបាលកិច្ចក្នុងប្រទេសដែលមានធនធានច្រើន។ EITI ស្ថាប័នតម្រូវអោយក្រុមហ៊ុន និងរដ្ឋ ផ្សព្វផ្សាយព័ត៌មានឱ្យបានទៀងទាត់ លើចំណូល និងចំណាយ " ឱ្យបានទូលំទូលាយ និងងាយយល់ ដែលសាធារណជនងាយទទួលបាន"។ ព័ត៌មានអំពី ចំណាយ និងចំណូល ត្រូវតែអាចជឿជាក់បាន ដោយមានការត្រួតពិនិត្យពីសវនកម្មឯករាជ្យនិង ដោយមានការដឹងឮពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗ រួមទាំងសង្គមស៊ីវិល។ ប្រធាន EITI អាស៊ីនិងអឺរ៉ុប អះអាងថា សមាជិកភាពរបស់ EITI ត្រូវលើកកំពស់បរិយាកាសវិនិយោគ ពង្រឹងស្ថាប័ន និងប្រឆាំងអំពើពុករលួយ ដោះស្រាយ ហានិភ័យលើការងារអភិបាលកិច្ច និង កាត់បន្ថយជម្លោះ បង្កើនកិច្ចសហប្រតិបត្តិការរវាង រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ផ្តល់វេទិកាពិភាក្សាវែកញែក លើកំណែទម្រង់ ក៏ដូចជាធ្វើឱ្យអាជីវកម្មល្អប្រសើរ [៣៩]។

---

[38] Marks, Simon, "Hoping Industry Will Mature, Miners Join Foreces," *The Cambodia Daily*, 13-14 February 2010; Marks, Simon "Government Offers Pretty Words on Mining," *The Cambodia Daily*, 28 May 2010.

[39] Bartlett, Samuel R., "The Case for Implementing the Extractive Industry Transparency Initiative (EITI)," Presentation made at the International Conference on Mining: Staking a Claim for Cambodia, Phnom Penh, 26-27 May 2010.

ប្រធាន CRRT បានលើកឡើងថា រដ្ឋាភិបាលគួរតែគិតគូរពិចារណាក្នុងការចុះហត្ថលេខា ជាមួយ EITI និងបោះពុម្ពផ្សាយ ថាតើកម្រៃបន្ថែមប៉ុន្មានដែលទទួលបានពីការចុះហត្ថលេខា រួមទាំងថវិកាដែលត្រូវដាក់ចូលទៅក្នុងមូលនិធិអភិវឌ្ឍន៍សង្គម។ ដំណើរការដេញថ្លៃរបស់រដ្ឋាភិបាល លើសិទ្ធិក្នុង ការរុករករ៉ែ និងភាគផល គួរតែមានផ្សព្វផ្សាយសម្រាប់ជាសាធារណៈ។ នៅខែមេសា ឆ្នាំ២០១០ អគ្គលេខាធិការរងនៃ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានប្រកាសថា រដ្ឋាភិបាល ទទួលយកនូវគោលការណ៍ ដែលបានចែងនៅក្នុង EITI ប៉ុន្តែកម្ពុជាមិនទាន់ក្លាយជាសមាជិក EITI ដរាបណាច្បាប់ស្តីពីតម្លាភាព និងពន្ធត្រូវ បានបង្កើតដើម្បីឆ្លើយតបនឹងតម្រូវការដែលអាចក្លាយជាសមាជិកនៃស្ថាប័ននេះ [៤០]។

## បណ្តាញផលប៉ះពាល់សង្គមនិងបរិស្ថានដោយឧស្សាហកម្មនិស្សារណៈកម្ម

បណ្តាញផលប៉ះពាល់សង្គម និងបរិស្ថានដោយឧស្សាហកម្មនិស្សារណៈកម្ម (EISEI) ត្រូវបានរៀបចំដោយក្រុមអង្គការ ដែលមានគោលបំណងលើកកំពស់ និង បង្កើនកិច្ចពិភាក្សា ក្នុងចំណោមសហគមន៍ ដែលទទួលការប៉ះពាល់ ក្រសួងពាក់ព័ន្ធ និង វិស័យឯកជន ដែលជាច្រកមួយជម្រុញឱ្យគ្រប់អ្នកពាក់ព័ន្ធ ទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍន៍វិស័យឧស្សាហកម្មនិស្សារណៈកម្មនៅកម្ពុជា ហើយកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមាន ដល់ដីធ្លី និងប្រជាពលរដ្ឋ។ កិច្ចពិភាក្សានេះ មានគោលបំណងជួយសម្រួលដល់លទ្ធភាពក្នុងការទទួលព័ត៌មាន និងផ្តល់សំលេងដល់សហគមន៍ដែលគ្មានតំណាង ដើម្បីបានបង្ហាញបញ្ហាដែលលេចឡើងពីការរុករក និងធ្វើអាជីវកម្មធនធានរ៉ែ។

បណ្តាញ EISEI មានសកម្មភាពប្រាំ ដើម្បីសម្រេចគោលបំណង: ១- ផ្សព្វផ្សាយ និងតម្រូវឱ្យ ទទួលបាននូវការយល់ព្រមដោយសេរី និងប្រាប់ឱ្យដឹងជាមុន ពីសហគមន៍ដែលអាចមានសក្តានុពលប៉ះពាល់លើដំណើរការនៃការអភិវឌ្ឍន៍ឧស្សាហកម្មនិស្សារណៈកម្ម។ ២- កាត់បន្ថយលទ្ធភាព ដែលតម្រូវឱ្យសហគមន៍ចាកចេញពីដីធ្លីនិង ការរារាំងលើការប្រើប្រាស់ធនធានធម្មជាតិដែលកើតឡើងដោយសារ គម្រោងឧស្សាហកម្មនិស្សារណៈកម្ម។ ៣- កាត់បន្ថយលទ្ធភាពប៉ះពាល់របស់គម្រោងឧស្សាហកម្មនិស្សារណៈកម្ម លើសង្គម និងបរិស្ថានរយៈពេលវែង។ ៤- បន្ថយវត្តមានរបស់គម្រោងឧស្សាហកម្មនិស្សារណៈកម្ម នៅក្នុងតំបន់ដែលមានតម្លៃវប្បធម៌ និង អេកូឡូស៊ីខ្ពស់។ ៥- ចូលរួមសកម្មក្នុងការគាំទ្រការគ្រប់គ្រងភាពកខ្វក់ និង ការបំពុលដោយគម្រោង ឧស្សាហកម្មនិស្សារណៈកម្មប្រកបដោយទំនួលខុសត្រូវ។

---

[40] Marks, Simon, "Gov't Should Join Transparency Push, NGOs Say," *The Cambodia Daily*, 26-27 June 2010; See also Marks, Simon, "Gov't Urged to Address BHP Probe," *The Cambodia Daily*, 24-25 April 2010.

## ច្បាប់គ្រប់គ្រងការយករ៉ែនៅកម្ពុជា

ការវិនិយោគវិស័យរ៉ែនៅកម្ពុជាត្រូវផ្តល់ដោយច្បាប់ស្តីពីការគ្រប់គ្រង និងអាជីវកម្មធនធានរ៉ែ ឬ ច្បាប់រ៉ែដែលអនុម័តនាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១។ ច្បាប់រ៉ែស្របគ្នាទៅនឹងមាត្រា ៥៨ នៃច្បាប់រដ្ឋធម្មនុញ្ញរបស់ ព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសថា ធនធានរ៉ែទាំងអស់ជាទ្រព្យសម្បត្តិរបស់រដ្ឋ (មាត្រា២)។ ច្បាប់រ៉ែ បែងចែកប្រភេទអាជ្ញាប័ណ្ណជាប្រាំមួយប្រភេទ ដែលរួមទាំងអាជ្ញាប័ណ្ណរុករក និងធ្វើអាជីវកម្មរ៉ែ (មាត្រា១១) ហើយចាត់ទុកថា រាល់សកម្មភាពរ៉ែទាំងអស់គឺខុសច្បាប់ បើសិនជាការធ្វើប្រតិបត្តិការដោយមិនមានអាជ្ញាប័ណ្ណ ពីអាជ្ញាធរមានសមត្ថកិច្ចដែលបច្ចុប្បន្ននេះគឺក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (មាត្រា៥)។ ការកើនឡើង យ៉ាងឆាប់រហ័ស នៃសកម្មភាពរ៉ែទ្រង់ទ្រាយធំៗ ចាប់ពីឆ្នាំ២០០៦ បានបង្ហាញឱ្យឃើញនូវកង្វះខាតច្រើន លើច្បាប់រ៉ែ ដែលជះឥទ្ធិពលដល់ ការពង្រីកសកម្មភាពរ៉ែនៅខេត្តមណ្ឌលគិរី។ សម្បទានរ៉ែ និង អាជ្ញាប័ណ្ណ ក្របខណ្ឌច្បាប់ ត្រូវបានយកមកលាតត្រដាងនៅក្នុងផ្នែកនេះដោយពិស្តារខ្លះៗ។

## សម្បទាន និងអាជ្ញាប័ណ្ណរ៉ែ

ដើម្បីធ្វើប្រតិបត្តិការយករ៉ែខ្នាតធំនៅកម្ពុជា ក្រុមហ៊ុនត្រូវទទួលសម្បទានរ៉ែ និងអាជ្ញាប័ណ្ណយករ៉ែ។ សម្បទានរ៉ែគឺ កំណត់តំបន់ភូមិសាស្ត្រសម្រាប់ដំណើរការសកម្មភាព។ រីឯអាជ្ញាប័ណ្ណរ៉ែផ្តល់ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការរ៉ែនៅក្នុងតំបន់កំណត់ក្រោមលក្ខខណ្ឌជាក់លាក់។ ដូចបានកត់សំគាល់ខាងលើ អាជ្ញាប័ណ្ណ គឺស្ថិតក្រោមច្បាប់រ៉ែ និង ផ្តល់ដោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។ បទបញ្ញត្តិលើការគ្រប់គ្រងសម្បទានរ៉ែមិនទាន់មានភាពជាក់លាក់ ជាពិសេសក្នុងដំណាក់កាលទទួលសម្បទាន និងនីតិវិធីលំអិតក្នុងការផ្តល់សម្បទាន។ ឯក្របខណ្ឌគតិយុត្តិសម្រាប់ចេញអាជ្ញាប័ណ្ណ នៅមិនទាន់មានលក្ខណៈពេញលេញ ហើយអាជ្ញាប័ណ្ណ សម្រាប់ការធ្វើអាជីវកម្មរ៉ែបច្ចុប្បន្នស្ថិតនៅក្រោម" កិច្ចព្រមព្រៀងធនធានរ៉ែ "រវាងក្រុមហ៊ុន និងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលផ្អែកលើករណីជាក់ស្តែង។ ឯកសារនោះបង្ហាញគោលការចាំបាច់នៃសម្បទាន ប្រភេទរ៉ែសម្រាប់ធ្វើអាជីវកម្ម និង ទំហំនៃពេលវេលា [៤១]។

យោងតាមច្បាប់រ៉ែ អាជ្ញាប័ណ្ណស្វែងរុករកអាចផ្តល់ឱ្យចំពោះបុគ្គលរូបវ័ន្ត ឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើការស្វែងរុករកនិងសិក្សាអំពីសក្តានុពលធនធានរ៉ែ (មាត្រា១១,៥)។ ក្រុមហ៊ុនដែលមានអាជ្ញាប័ណ្ណស្វែងរុករក អាចយកសំណាកពីតំបន់រ៉ែ ប៉ុន្តែមិនអាចទាញយកក្នុងលក្ខណៈ

[41] Personal communications with Mark Grimsditch, 10 September 2010.

ពាណិជ្ជកម្មឡើយ [42]។ អាជ្ញាប័ណ្ណរុករកត្រូវបានផ្តល់សម្រាប់រយៈពេលពីរឆ្នាំ និងអាចត្រូវបានបន្តជូនរហូតដល់រយៈពេលប្រាំមួយឆ្នាំ។ ការបន្តបន្ថែមទៀតអាចត្រូវបានផ្តល់ជូន អាស្រ័យលើសិទ្ធិសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល [43]។ ប្រសិនបើសកម្មភាពរុករកបង្ហាញថា បរិមាណស្រទាប់រ៉ែអាចធ្វើអាជីវកម្មក្នុងលក្ខណៈពាណិជ្ជកម្មបាន នោះក្រុមហ៊ុនអាចដាក់ពាក្យសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។

ដូចមានចែងនៅក្នុងច្បាប់រ៉ែ អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវបានផ្តល់ឱ្យចំពោះតែសម្បទានិកដែលមានអាជ្ញាប័ណ្ណស្វែងរុករកប៉ុណ្ណោះ ក្នុងគោលបំណងស្វែងរុករកនិង ជីកយករ៉ែណាដែលមានជម្រករ៉ែមានប្រសិទ្ធភាពសេដ្ឋកិច្ច ហើយឋិតនៅតែក្នុងរង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករក។ ជាងនេះទៅទៀត ម្ចាស់អាជ្ញាប័ណ្ណស្វែងរុករក ត្រូវភ្ជាប់នូវលទ្ធផលវិភាគផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ បរិស្ថាន សង្គម និងសេដ្ឋកិច្ច ដើម្បីកំណត់លទ្ធភាពផ្នែកសេដ្ឋកិច្ច-សង្គម ក្នុងដំណើរប្រតិបត្តិការរ៉ែ (មាត្រា១១.៦)។ អនុលោមតាម *អនុក្រឹត្យស្តីពី គោលការណ៍សម្រាប់ ការវិនិយោគលើធនធានរ៉ែ* សំណើសុំអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែទាំងអស់ត្រូវផ្តល់ការយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) [44]។

ច្បាប់រ៉ែ បង្ហាញពីភាពចាំបាច់នៃការរៀបចំអនុក្រឹត្យមួយដើម្បីកំណត់ទម្រង់និងខ្លឹមសារ នៃការសិក្សាលទ្ធភាពទាញយករ៉ែចុងក្រោយ ក្រោមមាត្រា ១១.៦ សម្រាប់ការចេញអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។ ប៉ុន្តែ មកដល់ដើមឆ្នាំ ២០១០ អនុក្រឹត្យនេះ នៅមិនទាន់បានអនុម័តនៅឡើយ ហើយអាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែត្រូវបានចេញក្រោម កិច្ចព្រមព្រៀងធនធានរ៉ែ ពោលគឺអនុស្សារណៈនៃការយោគយល់រវាងក្រុមហ៊ុននិងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ខ្លឹមសារលម្អិតនៃកិច្ចព្រមព្រៀងទាំងនេះកំពុងត្រូវបានចរចាផ្អែកលើករណីជាក់ស្តែង និង រួមមានព័ត៌មាន សំខាន់ស្តីពីទំហំតំបន់ភូមិសាស្ត្ររយៈពេលនៃអាជ្ញាប័ណ្ណ ថ្លៃជួលដី និង ភាគផល ។ កិច្ចព្រមព្រៀងទាំងនេះ ក៏មានលក្ខណៈសម្ងាត់ផងដែរ [45]។

## ការប្រព្រឹត្តរបស់សម្បទានិក

ក្រុមហ៊ុនទទួលអាជ្ញាប័ណ្ណ និងអ្នកម៉ៅការទទួលខុសត្រូវលើភាពសមស្របនៃប្រតិបត្តិការយករ៉ែ ដែលមានក្នុងច្បាប់រ៉ែ។ បទដ្ឋាននានារួមមាន ការធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពលើផ្នែកបច្ចេកទេស និង

---

42 អង្គការមិនមែនរដ្ឋាភិបាលរាយការណ៍អំពីការចោទប្រកាន់ដោយសហគមន៍មូលដ្ឋានថា ក្រុមហ៊ុនរ៉ែដែលមានអាជ្ញាប័ណ្ណរុករកបានធ្វើសកម្មភាពអាជីវកម្មដែលផ្ទុយនឹងច្បាប់។ សូមមើល "Environmental and Social Impacts of Expansion of the Extractive Industries Sector," in *NGO Position Papers on Cambodia Development in 2007-08: Monitoring the Implementation of 2007 CDCF Joint Monitoring Indicators and the National Strategic Development Plan 2006-10*, Phnom Penh, November 2008.

43 Prakas on Registration and Conditions to Issue, Renew and Transfer Mineral Licenses (Article 6, 4) cited in Grimsditch, Mark, *Analsyis of the Legal Framework Related to Mining in the Kingdom of Cambodia*, April 2010.

44 Grimsditch, *Analysis of the Legal Framework Related to Mining in the Kingdom of Cambodia*.

45 Grimsditch, *Analsis of the Legal Framework Related to Mining in the Kingdom of Cambodia*.

ហិរញ្ញវត្ថុ កិច្ចការពារបរិស្ថានដូចមានចែងលម្អិតនៅក្នុង *ច្បាប់ស្តីពីការការពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិ* ឆ្នាំ១៩៩៦ ដែលតម្រូវឱ្យមាន ការធានានូវកិច្ចការពារសុខភាពនិងសុវត្ថិភាពរបស់កម្មករ កិច្ចការពារសុវត្ថិភាពសាធារណៈនៅក្នុង និងនៅជុំវិញទីតាំងរ៉ែ ការផ្តល់ការបណ្តុះបណ្តាលគ្រប់គ្រាន់ជូននិយោជិត និងការប្រើទំនិញ និងសេវាកម្ពុជា តាមដែលអាចធ្វើទៅបាន (មាត្រា ២១,១-៦)។ ឯកសារមួយចំនួន គឺចាំបាច់ដើម្បីអនុលោមតាមបទដ្ឋានទាំងនេះ ដូចជាកម្មវិធីការងាររុករកឬ ការសិក្សាលទ្ធភាពយករ៉ែ ផែនការស្តារនិងរក្សាស្ថានភាពឡើងវិញ ការធានាហិរញ្ញវត្ថុ ផែនការរ៉ែដើម្បីសុខភាពនិងសុវត្ថិភាព និងផែនការអប់រំ និងបណ្តុះបណ្តាល និងផ្តល់ការងារ។ គោលការណ៍ណែនាំសម្រាប់ព័ត៌មានលម្អិតនៃឯកសារទាំងនេះ នឹងត្រូវបានកំណត់នៅក្នុងប្រកាសមួយ (មាត្រា ២២)។ ជាក់ស្តែង ច្បាប់រ៉ែពុំមានមាត្រាកំណត់យ៉ាងជាក់លាក់នូវបទដ្ឋានទំនួលខុសត្រូវពាក់ព័ន្ធជាមួយជនជាតិដើមភាគតិចឡើយ។

*ប្រកាសស្តីពីការចុះបញ្ជី និងលក្ខខណ្ឌដើម្បីចេញបន្ត និងផ្ទេរអាជ្ញាប័ណ្ណរ៉ែ* បំពេញបន្ថែមលើជំពូកនេះនៃច្បាប់រ៉ែ តែមិនមានកំណត់ចំនួនជាក់លាក់នៃឯកសារដែលជាតម្រូវការក្នុងមាត្រា២២ នោះទេ។ ប៉ុន្តែប្រកាសនេះមាន រាយបញ្ជីឯកសារដែលក្រុមហ៊ុនគួរភ្ជាប់ជាមួយពាក្យសុំអាជ្ញាប័ណ្ណរ៉ែ ក្រោយពេលចុះបញ្ជីជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ ឯកសារទាំងនេះរួមមានពាក្យសុំនិងឯកសារថតចម្លងវិញ្ញាបនប័ត្រចុះបញ្ជីពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ព័ត៌មានលម្អិតអំពីតំបន់ស្នើសម្រាប់ធ្វើប្រតិបត្តិការ របាយការណ៍ស្តីពីសមត្ថភាព ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានធ្វើសវនកម្មសម្រាប់រយៈពេល ៣ឆ្នាំ ផែនការសម្រាប់ការរុករកឬការយករ៉ែ រួមទាំងថវិកា ឯកសារ ភស្តុតាង ដែលបង្ហាញបទពិសោធន៍ផ្នែកបច្ចេកទេសរបស់ក្រុមហ៊ុនក្នុងវិស័យរ៉ែឬឧស្សាហកម្ម របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) និង ផែនការស្តារឡើងវិញ ព្រមទាំងផែនការជ្រើសរើសនិយោជិតកម្ពុជា និង ផែនការអប់រំ និង ការបណ្តុះបណ្តាល (មាត្រា ៤)[៤៦]។

នៅខេត្តមណ្ឌលគិរី ការអនុវត្តរបស់ក្រុមហ៊ុនរ៉ែ មិនមែនសុទ្ធតែគោរពតាមបទដ្ឋាននោះឡើយ។ កិច្ចប្រជុំមួយ ក្រោមការដឹកនាំរបស់ឯកឧត្តម ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កាលពីខែមីនា ឆ្នាំ២០០៩ បានបង្ហាញថា ក្រុមហ៊ុនរ៉ែចំនួន ១២ នៅខេត្តមណ្ឌលគិរី មិនបានផ្តល់ព័ត៌មានជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពី សកម្មភាពរបស់ខ្លួនឡើយ។ រដ្ឋលេខាធិការមួយរូបនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលមានប្រសាសន៍ថា វាគឺជាប្រការសំខាន់ដែលក្រុមហ៊ុនល្មើសទាំង ១២ ត្រូវផ្តល់ដំណឹងជូនមន្ត្រីអំពី ប្រតិបត្តិការរបស់ពួកគេ ដើម្បីឱ្យក្រសួងអាចតាមដានការអនុវត្តលក្ខខណ្ឌនៃកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ។ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែនិង ថាមពល នៅខេត្តមណ្ឌលគិរីបានទទួលស្គាល់ថាៈ "ក្រុមហ៊ុនទាំងអស់សុទ្ធតែមានអាជ្ញាប័ណ្ណ

---

[46] សូមមើល Grimsditch, *Analsis of the Legal Framework Related to Mining in the Kingdom of Cambodia.*

ប៉ុន្តែ ពួកគេមិនដែលរាយការណ៍ ប្រាប់យើងអំពីអ្វីដែលពួកគេកំពុងធ្វើឡើយ។" ក្រុមហ៊ុនទាំង ១២ ត្រូវបានស្នើសុំឱ្យ ផ្តល់របាយការណ៍ក្នុង រយៈពេល ១៥ ថ្ងៃ [៤៧]។

**ថ្លៃឈ្នួល ការបែងចែកភាគផល និងប្រាក់ចំណូល**

ដូចការសម្ងាត់នៅជុំវិញការផ្តល់សម្បទាន និងអាជ្ញាប័ណ្ណរ៉ែអញ្ចឹងដែរ ការបង់ថ្លៃនានាដែលត្រូវបានធ្វើពាក់ព័ន្ធនឹង កិច្ចព្រមព្រៀងទាំងនេះ ក៏បាននាំឱ្យមានការបារម្ភដូចគ្នាដែរអំពីកង្វះខាតនៃការបញ្ចេញព័ត៌មាន និង តម្លាភាព។ រាជរដ្ឋាភិបាលត្រូវទទួលបានចំណូលស្របច្បាប់ពីឧស្សាហកម្មរ៉ែ ហើយច្បាប់រ៉ែចែងថា អ្នកដាក់ពាក្យសុំឬ ម្ចាស់អាជ្ញាប័ណ្ណត្រូវបង់ជូនរដ្ឋនូវថ្លៃនៃការចុះបញ្ជី ដាក់ពាក្យសុំព្យួរបន្ត ផ្ទេរ និង ថ្លៃជួលដីប្រចាំឆ្នាំ (មាត្រា ២៧)។ សំណួរត្រូវបានចោទសួរអំពីភាពផ្លូវការឬក្រៅផ្លូវការនៃថ្លៃទាំងនេះ នៅពេលរឿងចម្រូងចម្រាស់មួយពាក់ព័ន្ធនឹងការបង់ប្រាក់ដោយក្រុមហ៊ុន BHP Billiton បានក្លាយជាចំណុចយកចិត្តទុកដាក់មួយនៃការជជែកជាសាធារណៈ។

កាលពីខែឧសភា ឆ្នាំ២០០៧ *កាសែតកាំបូឌាដេលី* បានរាយការណ៍ថា រដ្ឋមន្ត្រីក្រសួងធនធានទឹក ឯកឧត្តម លឹម គានហោ បានជម្រាបជូនរដ្ឋសភាថាក្រុមហ៊ុន BHP Billiton បានបង់ប្រាក់ចំនួន ២.៥ លានដុល្លា ដើម្បីទទួលបានសម្បទានរ៉ែបុកស៊ីតនៅខេត្តមណ្ឌលគិរី។ គួរឱ្យភ្ញាក់ផ្អើល ការបង់ប្រាក់នោះត្រូវបានរៀបរាប់ បន្ថែម ទៀតថាជា "ប្រាក់ទឹកតែ" ដែលជាភាសាប្រើសម្រាប់ការបង់ប្រាក់ក្រៅផ្លូវការ។[៤៨] ក្រុមហ៊ុន BHP Billiton ក្រោយពេល នោះ បានបញ្ជាក់ថា ខ្លួនបានបង្កើតមូលនិធិមួយសម្រាប់គម្រោងអភិវឌ្ឍន៍សង្គម ដែលមានទឹកប្រាក់ ចំនួន ២.៥ លានដុល្លាអាមេរិក សម្រាប់ប្រទេសកម្ពុជា ប៉ុន្តែ បានបដិសេធការអះអាងថា វិភាគទានទាំងនេះគឺជា "ប្រាក់ទឹកតែ"។ ក្រុមហ៊ុន BHP Billiton ក៏បានបញ្ជាក់ផងដែរថាខ្លួនបានបង់ប្រាក់ជូនរាជរដ្ឋាភិបាលចំនួន ១ លានដុល្លារអាមេរិក អនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ដើម្បីផ្តល់សិទ្ធិរុករករ៉ែបុកស៊ីត នៅខេត្តមណ្ឌលគិរី រួមគ្នាជាមួយក្រុមហ៊ុន Mitsubishi Corporation [៤៩]។

កាលពីខែមេសា ឆ្នាំ២០១០ រឿងចម្រូងចម្រាស់ក្រុមហ៊ុន BHP Billiton បានផ្ទុះឡើងជាថ្មីទៀតនៅលើ ទំព័រកាសែត នៅពេលដែលក្រុមហ៊ុននេះបានទទួលស្គាល់ថា ខ្លួនបានផ្តល់ជូនគណៈកម្មការផលប័ត្រ និង ផ្សារហ៊ុន អាមេរិកនូវភស្តុតាងទាក់ទិននឹងលទ្ធភាពរំលោភច្បាប់ប្រឆាំងអំពើពុករលួយ ដែលពាក់ព័ន្ធជាមួយមន្ត្រីរដ្ឋាភិបាល។ ក្រោមច្បាប់អាមេរិកស្តីពីអំពើពុករលួយនៅបរទេស ក្រុមហ៊ុន BHP Billiton និង ក្រុមហ៊ុនផ្សេងទៀតដែលផលប័ត្ររបស់ខ្លួនត្រូវបានធ្វើពាណិជ្ជកម្មនៅសហរដ្ឋអាមេរិក ហាមឃាត់ការសូកប៉ាន់ មន្ត្រី

---

47 Kimsong, Kay, "Government Targets Miners," *The Phnom Penh Post*, 29 April 2009.
48 'Gov't Gets $2.5 Million for Mine Exploitation Contract,' *The Cambodia Daily*, 22 May 2007.
49 Global Witness, *Country for Sale*, February 2009.

រដ្ឋាភិបាលនៅបរទេស។ ក្រុមហ៊ុន BHP Billiton បដិសេធមិនព្រមបញ្ជាក់ថាតើ អាចមានការរំលោភច្បាប់បែបនេះ ឬយ៉ាងណា នៅកម្ពុជា [៥០] ។

បន្ទាប់មក គណៈបក្សប្រឆាំងសម រង្ស៊ី (SRP) បានសុំឱ្យរាជរដ្ឋាភិបាលពន្យល់អំពីទំនាក់ទំនងជាមួយក្រុមហ៊ុនBHP Billitonនិងសុំឱ្យបំភ្លឺថាតើរាជរដ្ឋាភិបាលគ្រប់គ្រងប្រាក់ចំណូលពីឧស្សាហកម្មរ៉ែយ៉ាងដូចម្តេច។ អង្គការ កម្ពុជាសម្រាប់តម្លាភាពចំណូលធនធាន (CRRT) បានគាំទ្រសំណើរបស់គណៈបក្សសម រង្ស៊ី ដែលស្នើសុំឱ្យរាជរដ្ឋាភិបាល បញ្ចេញព័ត៌មានអំពីការគ្រប់គ្រងមូលនិធិសង្គម និង អ្នកដែលពាក់ព័ន្ធក្នុងការវិភាជន៍មូលនិធិរបស់ខ្លួន [៥១]។ សុន្ទរកថានៅក្នុងសន្និសីទអន្តរជាតិស្តីពីរ៉ែកាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ នាយករដ្ឋមន្ត្រី បានថ្លែងថា ការបង់ប្រាក់ចូលមូលនិធិសង្គមដែលទទួលបានពីក្រុមហ៊ុនឯកជន គឺដាក់ចូលទៅក្នុងថវិកាជាតិ ថ្វីបើលោកមិនបានផ្តល់ព័ត៌មានលម្អិតថាតើប្រាក់ទាំងនេះត្រូវបានបង់ចូលនៅទីណា ឬ ថាតើប្រាក់ចំនួនប៉ុន្មានត្រូវបានទទួលដោយរាជរដ្ឋាភិបាលមកដល់ពេលនេះ [៥២]។ ជាការពិត សំណួរពាក់ព័ន្ធនឹងថ្លៃបង់នឹងនៅតែមាន រហូតដល់ពេលដែលរាជរដ្ឋាភិបាលបង្កើតប្រព័ន្ធមួយ ដែលបញ្ចេញព័ត៌មានពេញលេញអំពីប្រាក់ចំណូលទាំងអស់ពីឧស្សាហកម្មរ៉ែ។

## ការរក្សាការសម្ងាត់ និងការបញ្ចេញឯកសារ

កង្វះតម្លាភាព និងគណនេយ្យភាពសាធារណៈក្នុងវិស័យរ៉ែត្រូវបានដាក់បញ្ចូលក្នុងក្របខណ្ឌគតិយុត្តិ។ មាត្រា ១៩ នៃច្បាប់រ៉ែ ចែងថាម្ចាស់អាជ្ញាប័ណ្ណដែលស្ថិតនៅក្រោមច្បាប់នេះ ត្រូវដាក់ជូនរដ្ឋមន្ត្រីទទួលបន្ទុកធនធានរ៉ែនូវពាក្យសុំ របាយការណ៍ ផែនការ និង ការជូនដំណឹង តាមកាលបរិច្ឆេទកំណត់ និង រក្សាទុកបញ្ជី និង ឯកសារនានា។ ប៉ុន្តែ មាត្រា ២០ ធានាឱ្យបានប្រាកដថា ការរក្សាការសម្ងាត់នៃឯកសារ និងព័ត៌មានទាំងអស់ដូចដែលមានចែងនៅក្នុងមាត្រា ១៩ នៃច្បាប់នេះ ត្រូវរក្សាទុករហូតដល់ពេលចប់ អាជ្ញាប័ណ្ណ ឬ ក្រោយពេលទទួលបានការយល់ព្រមពីម្ចាស់អាជ្ញាប័ណ្ណ ដើម្បីអនុញ្ញាតឱ្យមានការបញ្ចេញជាសាធារណៈ។ ព័ត៌មានទាក់ទិននឹងបញ្ហាបរិស្ថាននិងសង្គម អាចត្រូវបានបញ្ចេញជូនសាធារណៈជនបាន អាស្រ័យលើសិទ្ធិសម្រេច របស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។

បទប្បញ្ញត្តិស្តីពីការសម្ងាត់ដែលមានចែងនៅក្នុងច្បាប់រ៉ែ គឺជាឧបសគ្គដ៏ធ្ងន់ធ្ងរសម្រាប់ ការឃ្លាំមើលឯករាជ្យលើវិស័យឧស្សាហកម្មរ៉ែ។ វិស័យសាធារណៈ និងសូម្បីតែក្រសួងពាក់ព័ន្ធនានា ដូចជាក្រសួងបរិស្ថាន

[50] Gillison, Douglas and Kuch Naren, “Minister’s ‘Tea Money’ Remark Vexes BHP,” *The Cambodia Daily*, 23 April 2010.
[51] Yun Samean and Simon Marks, “SRP Calls for Explanation of ‘Social Fund’,” *The Cambodia Daily*, 6 May 2010.
[52] Yun Samean and Simon Marks, “ PM Says ‘Social Funds’ Go Into National Budget,” *The Cambodia Daily*, 27 May 2010.

ជាដើម មិនអាចតាមដាន និងរាយការណ៍អំពីការអនុវត្តន៍របស់ក្រុមហ៊ុនរ៉ែបាន ដោយគ្មានការទទួលព័ត៌មានអំពីព្រំដែន សម្បទានដែលបានឯកភាព រយៈពេលនៃប្រតិបត្តិការ រ៉ែដែលត្រូវទាញយក និងការបង់ថ្លៃចំណូល និង ភាគផល។ ម្យ៉ាងទៀត គេមិនដឹងច្បាស់ទេថាតើការរឹតត្បិតលើការសម្ងាត់នៃច្បាប់រ៉ែ សំដៅទៅលើការសិក្សាលទ្ធភាពយករ៉ែ ផែនការស្តារស្ថានភាព កម្មវិធីសុខភាពនិងសុវត្ថិភាព និងផែនការអប់រំបណ្តុះបណ្តាល និងការងារដែលត្រូវបានកំណត់ក្រោមមាត្រា២១ ស្តីពីការប្រព្រឹត្តរបស់សម្បទានិក[៥៣]។

ផ្ទុយទៅវិញ *ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ* ឬ *ច្បាប់ស្តីពីបរិស្ថាន* ឆ្នាំ ១៩៩៦ ដែលគ្របដណ្តប់ផងដែរលើសកម្មភាពយករ៉ែ ជម្រុញឱ្យមានតម្លាភាព និងគណនេយ្យភាព ដែលច្បាប់នេះប្រកាសថា ក្រោយពេលមានសំណើពីសាធារណជន ក្រសួងបរិស្ថានត្រូវផ្តល់ព័ត៌មានអំពីសកម្មភាពរបស់ខ្លួន និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន នៅក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ភាពផ្ទុយ និងមិនស៊ីសង្វាក់គ្នាក្នុងច្បាប់លើការគ្រប់គ្រងរ៉ែ បង្ហាញនូវភាពចាំបាច់ត្រូវមានការពិនិត្យមើលឡើងវិញលើក្របខណ្ឌគតិយុត្តិ។

## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

*ច្បាប់ស្តីពីបរិស្ថាន* កំណត់ថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ត្រូវធ្វើលើគ្រប់គម្រោងអភិវឌ្ឍន៍ទាំងអស់ និង ត្រូវយល់ព្រមដោយក្រសួងបរិស្ថាន (មាត្រា៦)។ ច្បាប់ស្តីពីការយករ៉ែគូសបញ្ជាក់គោលការណ៍នេះឡើងវិញនិងតម្រូវឱ្យអ្នកយករ៉ែបំពេញនូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (មាត្រា២១)។ *អនុក្រឹត្យស្តីពីនីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន* ឆ្នាំ ១៩៩៩ កំណត់នីតិវិធីសម្រាប់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ជាបឋម ក្រុមហ៊ុនត្រូវបញ្ជូនការវាយតម្លៃដំបូងលើហេតុប៉ះពាល់បរិស្ថាន (IEIA) និងរបាយការណ៍ស្តីពីលទ្ធភាព អនុវត្តគម្រោងជូនក្រសួងបរិស្ថាន។ ប្រសិនបើក្រសួងបរិស្ថានយល់ឃើញថាគម្រោងនឹងមានផលប៉ះពាល់ធ្ងន់ធ្ងរលើធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី សុខភាព ឬ សុខុមាលភាពសាធារណៈ ក្រុមហ៊ុនត្រូវតែដាក់ជូន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទាំងស្រុងដើម្បីពិនិត្យមើល។ ក្រសួងបរិស្ថានមានពេល ៣០ ថ្ងៃ ដើម្បីពិនិត្យមើល ការវាយតម្លៃដំបូងលើហេតុប៉ះពាល់បរិស្ថាន និង ប្រសិនបើចាំបាច់ រយៈពេល ៣០ ថ្ងៃថែមទៀត ដើម្បីពិនិត្យមើល ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាំងស្រុង ដែលក្រោយពេលនោះ ក្រសួងត្រូវតែផ្តល់របកគំហើញ និងអនុសាសន៍។ ប្រសិនបើក្រសួងបរិស្ថាន ខកខានមិនបានឆ្លើយតបក្នុងរយៈពេលនេះទេ អនុក្រឹត្យនេះសន្មត់ថា ការវាយតម្លៃ ដំបូងលើផលប៉ះពាល់បរិស្ថាន ឬការវាយតម្លៃផលប៉ះពាល់បរិស្ថានរបស់ក្រុមហ៊ុនមានការគោរពតាមច្បាប់ (មាត្រា ៦-៨, ១៥, ១៧, ១៨)។

[53] Grimsditch, *Anaysis of the Legal Framework Related to Mining in the Kingdom of Cambodia.*

ដោយសមត្ថភាពមានកម្រិតរបស់ក្រសួងបរិស្ថានលើកម្រិតនៃជំនាញ បុគ្គលិក បច្ចេកទេស និងថវិកា ការបារម្ភត្រូវបានគេលើកឡើងថាការវាយតម្លៃរយៈពេល ៣០ ថ្ងៃដែលត្រូវបានចែង នៅក្នុង អនុក្រឹត្យនេះ អាចមិនគ្រប់គ្រាន់សម្រាប់ឱ្យក្រសួងបរិស្ថាន វាយតម្លៃឱ្យបានគ្រប់គ្រាន់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើប្រតិបត្តិការរ៉ែខ្នាតធំ នៅតំបន់ឆ្ងាយក្នុងប្រទេសនោះទេ។ *ប្រកាសស្តីពីគោលការណ៍ ណែនាំសម្រាប់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន* ឆ្នាំ២០០០ រឹតតែបន្ថែមឧបសគ្គ ដោយសារប្រកាសនេះ មិនមានចែងឱ្យបានគ្រប់គ្រាន់ថាតើព័ត៌មានអ្វីចាំបាច់ត្រូវដាក់បញ្ចូលក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ថ្មីៗនេះ ប្រកាសត្រូវបានអនុម័តលើអ្វីដែលគួរបញ្ចូលទៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន[៥៤]។

ការអភិវឌ្ឍន៍រ៉ែប្រកបដោយទំនួលខុសត្រូវតម្រូវឱ្យមានការវិភាគបរិស្ថានដ៏ហ្មត់ចត់ ដែលជំរុញអោយមានការចូលរួមសាធារណៈ[៥៥]។ *អនុក្រឹត្យស្តីពីនីតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន* លើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈ ក្នុងការអនុវត្តកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងគិតគូរវាល់គំនិត និងសំណើ ទទួលបានពីការចូលរួមនេះ មុនពេលអនុវត្តគម្រោង (មាត្រា១)។ ប៉ុន្តែ ការប្រញាប់ផ្តល់អាជ្ញាប័ណ្ណរុករក ឃើញថា ជាការមើលរំលងលើអនុក្រិត្យនេះ។ នៅចុងឆ្នាំ ២០០៧ ក្រសួងបរិស្ថានបានប្រកាសឱ្យក្រុមហ៊ុនរ៉ែមិនចាំបាច់ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាលក្ខខណ្ឌចាំបាច់មុនទទួលអាជ្ញាប័ណ្ណរុករកទៀតទេ[៥៦]។ ជំហរនេះគឺផ្ទុយនឹងច្បាប់រ៉ែដែលតម្រូវយ៉ាងជាក់លាក់ ឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ម្ចាស់អាជ្ញាប័ណ្ណរុករក(មាត្រា២១, ២)។ កាលពីឆ្នាំ២០០៨ អង្គការមិនមែនរដ្ឋាភិបាល នៅខេត្តមណ្ឌលគិរីបានសម្តែងការបារម្ភថាក្រុមហ៊ុនរ៉ែមិនបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះឡើយ[៥៧]។

## ការយកដីក្នុងតំបន់ការពារ

ល្បឿននៃការផ្តល់សម្បទាន និងអាជ្ញាប័ណ្ណរ៉ែបានកើនឡើងយ៉ាងលឿន ជាពិសេស នៅក្នុងតំបន់សំបូរដោយជីវចម្រុះ តែការមិនអាចរំលោភលើតំបន់ការពារទាំងឡាយនៅកម្ពុជាស្ថិតនៅតែជាចម្ងល់ដដែល។ តំបន់ការពារទាំង ២៣ ក្នុងប្រទេស ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ ដោយ *ព្រះរាជក្រឹត្យស្តីពីកិច្ចការពារ តំបន់ធម្មជាតិ* ត្រូវបានគ្រប់គ្រងដោយក្រសួងបរិស្ថាន និងគ្របដណ្តប់លើផ្ទៃដីទំហំ ៣២ ២៨៩ គ.ម$^{២}$.។ *ប្រកាសស្តីពីកិច្ចការពារតំបន់ធម្មជាតិ* ឆ្នាំ១៩៩៤ បានហាមឃាត់ការយករ៉ែនៅក្នុងតំបន់ទាំងនេះ (មាត្រា ៤)។ ប៉ុន្តែ ដោយសារច្បាប់ស្តីពីការយករ៉ែឆ្នាំ២០០១ មិនមានហាមឃាត់យ៉ាងច្បាស់លាស់នូវការយករ៉ែក្នុងតំបន់ការពារទើបធ្វើឱ្យការការពារដោយស្របច្បាប់ សម្រាប់តំបន់អភិរក្សទាំងនេះត្រូវបាត់បង់[៥៨]។ នៅក្នុង

---

54 Personal communications with Mark Grimsditch, 2 October 2010.
55 Miranda et al, *Framework for Responsible Mining.*
56 Environmental and Social Impacts of Expansion of the Extractive Industries Sector," November 2008.
57 Beaumont, Pearl, *Extractive Industry Mining Study Social & Environmental Impacts Ratanakiri & Mondulkiri*, Development and Partnership in Action (DPA), July 2008.
58 Global Witness, *Country for Sale.*

សិក្ខាសាលាមួយកាលពីឆ្នាំ ២០០៤ មន្ត្រីក្រសួងបរិស្ថាន និងអង្គការមិនមែនរដ្ឋាភិបាលខាងអភិរក្ស បានលើកឡើងថា ការយករ៉ែបានកំពុងកើតឡើងក្នុងតំបន់ការពារចំនួន ៩ ហើយកំពុងគំរាមកំហែង តំបន់ការពារចំនួន ១៣ ទៀត[៥៩]។

ខេត្តមណ្ឌលគិរីមានតំបន់ការពារជម្រកសត្វព្រៃចំនួនបួន និង ព្រៃការពារចំនួនពីរ ដែលមានផ្ទៃដីសរុប ១ ២៦៧ ៣២២ ហិកតា។ ទីជម្រកសត្វព្រៃក្រោមក្រសួងបរិស្ថាន រួមមានភ្នំព្រិច (២២២ ៥០០ ហិកតា) ភ្នំណាំលៀ (៤៧ ៥០០ ហិកតា) លំផាត់ (២៥០ ០០០ ហិកតា) និង ស្នួល (៧៥ ០០០ ហិកតា)។ ព្រៃការពារស្ថិតក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រួមមានព្រៃការពារមណ្ឌលគិរី (៣៧២ ៩៧១ ហិកតា) និង តំបន់អភិរក្សជីវចម្រុះសីមា (២៩៨ ៨៥១ ហិកតា)។ មកដល់ឆ្នាំ ២០០៨ យ៉ាងហោចណាស់ផ្ទៃដី ២៨២ ៧០០ ហិកតា ឬ ២២ ភាគរយនៃតំបន់ការពារទាំងនេះត្រូវបានគ្របដណ្តប់ដោយសម្បទានរ៉ែ[៦០]។

ការអនុម័ត*ច្បាប់ស្តីពីតំបន់ការពារ* ឆ្នាំ២០០៨ បានផ្តល់ក្របខណ្ឌមួយ សម្រាប់ការពារជីវចម្រុះនៅពេលណាដែលមានការទាញយកផលពីធនធានធម្មជាតិ ដែលរួមមានធនធានរ៉ែ សម្រាប់ការអភិវឌ្ឍន៍ជាតិ។ ក្រោមច្បាប់នេះ ដែនដីនៃតំបន់ការពារ នីមួយៗត្រូវបែងចែកយ៉ាងហ្មត់ចត់ទៅជាបួនតំបន់: តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ប្រកបដោយនិរន្តរភាព និង តំបន់សហគមន៍។ ការយករ៉ែនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស មិនត្រូវបានអនុញ្ញាតឡើយ (មាត្រា១១)។ សកម្មភាពយករ៉ែអាចធ្វើបាននៅក្នុងតំបន់ប្រើប្រាស់ប្រកបដោយនិរន្តរភាព តាមសំណើពីក្រសួងបរិស្ថាន ក្រោយពេលពិគ្រោះយោបល់ ជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និង សហគមន៍មូលដ្ឋាន (មាត្រា១១, ៣)។ ទោះបីជាមានបទប្បញ្ញត្តិទាំងនេះក្តី ក៏អង្គការមិនមែនរដ្ឋាភិបាល បានសម្តែងការបារម្ភអំពីសេចក្តីថ្លែងការណ៍ របស់ក្រសួងបរិស្ថាន កាលពីខែធ្នូ ឆ្នាំ២០០៧ ថាការកំណត់តំបន់ការពារ នឹងត្រូវបានធ្វើឡើងក្រោយពេលដែល ផែនការមេស្តីពីធនធានរ៉ែ ត្រូវបានរៀបចំរួច ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមហ៊ុនរ៉ែ[៦១]។

នាយកប្រចាំប្រទេសនៃអង្គការ WWF នៅកម្ពុជាអះអាងថា តំបន់ស្នូលត្រូវតែបានការពារទល់នឹងសកម្មភាពយករ៉ែ ដោយសារប្រព័ន្ធអេកូឡូស៊ីផ្សេងៗ ពឹងផ្អែកលើតំបន់ស្នូលទាំងនេះ។ ហេតុដូច្នេះ តំបន់សម្បូរជីវចម្រុះនៅក្នុងតំបន់ការពារត្រូវតែបានកំណត់ផែនទីមុនពេលផ្តល់សិទ្ធិយករ៉ែ[៦២]។ ជំហរនេះគឺស្របគ្នានឹងបទដ្ឋានអន្តរជាតិសម្រាប់ការយករ៉ែប្រកបដោយទំនួលខុសត្រូវ ដែលគូសបញ្ជាក់ភាពមិនអាចរំលោភបាន នៃ

---

[59] Douglas Gillison, "Cambodia Braces for a Mining Invasion," *Asia Sentinel*, 21 September 2007.
[60] "Forests, Plantations and Concessions," in *NGO Position Papers on Cambodia Development in 2007-08: Monitoring the Implementation of 2007 CDCF Joint Monitoring Indicators and the National Strategic Development Plan 2006-10*, Phnom Penh, November 2008.
[61] "Environmental and Social Impacts of Expansion of the Extractive Industries Sector," November 2008.
[62] Kinetz and Yun, "Mining Companies, Villagers Vie for Gold in Mondulkiri Province"; Gillison, "Cambodia Braces for a Mining Invasion."

តំបន់ "មិនឱ្យចូល" ពោលគឺ តំបន់ដែលមានសក្តានុពល រ៉ែតែមានលក្ខណៈប៉ះពាល់ខ្លាំងខាងបរិស្ថាន និងសង្គម ដែលអាចគ្រោះថ្នាក់ប្រយោជន៍ខ្ពស់ពីការអភិវឌ្ឍន៍ក្នុងទីតាំងទាំងនេះ [៦៣] ។

## ការយករ៉ែក្នុងតំបន់ព្រៃ

*ច្បាប់ស្តីពីព្រៃឈើ* ឬ *ច្បាប់ព្រៃឈើ* ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០២ អនុញ្ញាត ឱ្យមានការយករ៉ែនៅក្នុងតំបន់ព្រៃទុកបម្រុងអចិន្ត្រៃយ៍ អាស្រ័យលើការសិក្សាវាយតម្លៃជាមុន ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការអនុញ្ញាតដោយរាជរដ្ឋាភិបាលកម្ពុជា ដែលរួមមានវិធានការការពារនិង វិធានការស្តារឡើងវិញ។ យោងតាម*ច្បាប់ព្រៃឈើ*នេះ ម្ចាស់អាជ្ញាប័ណ្ណយករ៉ែត្រូវតែៈ ១- ជៀសវាង ហេតុបណ្តាល ឬធ្វើឱ្យមានការហូរច្រោះដី ការធ្វើឱ្យខូចដល់ការលូតលាស់រុក្ខជាតិ ការខូចខាតប្រព័ន្ធជលសាស្ត្រនិង គុណភាពទឹក និង ២- ក្រោយពេលចប់គម្រោង ស្តារឡើងវិញទីកន្លែង យកថ្ម ដី និង ដីខ្សាច់ ការយករ៉ែ ឬ និស្សារណកម្មធនធានធម្មជាតិផ្សេងទៀត ឱ្យបានដូចសភាពដើម តាមពេលវេលាកំណត់ ដោយលិខិតអនុញ្ញាត (មាត្រា៣៥)។ ម្យ៉ាងទៀត សាមីជនមានសិទ្ធិយករ៉ែ ត្រូវតែគោរពតាម បទប្បញ្ញត្តិទូទៅនៃ *ច្បាប់ព្រៃឈើ* ដែលធានាការចូលរួមពីសាធារណៈ នៅក្នុងសេចក្តីសម្រេចចិត្តណាមួយរបស់រាជរដ្ឋាភិបាល ដែលមានសក្តានុពលផលប៉ះពាល់ដល់ប្រជាពលរដ្ឋពាក់ព័ន្ធទូទៅ ជីវភាពរស់នៅសហគមន៍ និង ធនធានព្រៃឈើ (មាត្រា៤)។ *ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ* ស្របគ្នានឹង *ច្បាប់ព្រៃឈើ* តម្រូវឱ្យត្រៀមរៀបចំធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផ្សព្វផ្សាយ ដើម្បីសុំយោបល់សាធារណៈអំពីសកម្មភាពពាក់ព័ន្ធ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានលើសង្គម និងបរិស្ថាន នៃតំបន់ព្រៃដែលមានប្រព័ន្ធអេកូឡូស៊ីសំខាន់ (មាត្រា ៤)។

*ច្បាប់ព្រៃឈើ* ឆ្នាំ២០០២ លើកឡើងវិញពីការការពារសិទ្ធិដងជ័ររបស់សហគមន៍មូលដ្ឋាន ដែលចែងនៅក្នុង*ច្បាប់ព្រៃឈើ* ឆ្នាំ ១៩៨៨។ ផ្ទុយទៅនឹងការប្រតិបត្តិទូទៅរបស់សម្បទានព្រៃឈើដែលធ្វើប្រតិបត្តិការមុន មានបំរាមកាប់ឈើឆ្នាំ ២០០១ ច្បាប់នេះហាមឃាត់ការកាប់ឈើដែលសហគមន៍បានដងជ័រសម្រាប់ការប្រើប្រាស់ ជាប្រពៃណី (មាត្រា២៩)។ *ច្បាប់ព្រៃឈើ* ឆ្នាំ ២០០២ ក៏ទទួលស្គាល់និងការពារដូចគ្នាដែរ នូវសិទ្ធិប្រើប្រាស់ ជាប្រពៃណីរបស់សហគមន៍ក្នុងការប្រមូលនិងប្រើប្រាស់ផលិតផលនិង អនុផលព្រៃឈើ។ បទប្បញ្ញត្តិទាំងនេះនៅក្នុង*ច្បាប់ព្រៃឈើ* ធានាថាអ្នកមានតាំងទីលំនៅក្នុងតំបន់ព្រៃឈើមិនត្រូវបានហាមឃាត់ការចូលក្នុងតំបន់ព្រៃឈើដោយសម្បទានិករ៉ែឡើយ [៦៤] ។

---

63 Miranda, Marta, David Chambers, and Catherine Coumans, "Framework for Responsible Mining: A Guide to Evolving Standards," 19 October 2005.

64 McAndrew, John P., and Oeur Il, "Access to Natural Resources: Case Studies of Cambodian Hill Tribes," in Jayantha Perera ed., *Land and Cultural Survival: The Communal Land Rights of Indigenous Peoples in Asia*, Manila, Asian Development Bank, 2009.

## ការពង្រីកសកម្មភាពរ៉ែនៅក្នុងភូមិ នៃខេត្តមណ្ឌលគិរី

ចាប់តាំងពីក្រុមហ៊ុនរ៉ែធំៗ ចូលមកខេត្តមណ្ឌលគិរី ក្នុងឆ្នាំ ២០០៦មក មិនទាន់មានការស្រាវជ្រាវច្បាស់លាស់ណាមួយត្រូវបានធ្វើឡើងនៅក្នុងខេត្ត ស្តីពីផលប៉ះពាល់នៃសកម្មភាពរ៉ែ ទៅលើសហគមន៍មូលដ្ឋានទេ។ គេមើលឃើញខ្លះពីកង្វល់របស់សហគមន៍ តាមរយៈការសិក្សាមួយ ដែលធ្វើឡើងដោយអង្គការអភិវឌ្ឍន៍ភាពជាដៃគូក្នុងសកម្មភាព (DPA) ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយធ្វើការនៅស្រុកកែវសីមា។ នៅខែមេសា និងខែឧសភា ឆ្នាំ២០០៨ អ្នកស្រាវជ្រាវអង្គការ DPA បានសម្ភាសន៍ភាគច្រើនជា ជនជាតិដើមភាគតិច នៅតាមភូមិចំនួន ១៨ ក្នុងឃុំចំនួន ៧ ក្នុងស្រុកចំនួន ៤ ក្នុងខេត្តមណ្ឌលគិរី ដើម្បីស្ទាបស្ទង់ កង្វល់នៅពេលនេះ និងនៅពេលអនាគត លើសកម្មភាពរ៉ែដែលនៅជិតសហគមន៍របស់គេ។ ជាទូទៅ អ្នកឆ្លើយមានកង្វល់ពី កង្វះការពិគ្រោះយោបល់ និងសំណង ការបាត់បង់មធ្យោបាយចិញ្ចឹមជីវិត ការខូចបរិស្ថាន ការចាប់យកដី ការបំពានលើដីធ្លី ការបំផ្លាញព្រៃឈើការបាត់បង់ចំពោះទីកន្លែងជំនឿស័ក្តិសិទ្ធិ និងការគំរាមកំហែងបណ្តេញចេញ (រូបទី៤)[៦៥]។

| **រូបទី៤: សេចក្តីសង្ខេបនៃកង្វល់ដែលប្រមូលដោយអ្នកស្រាវជ្រាវរបស់អង្គការ DPA នៅតាមភូមិចំនួន ១៨ នៅជិតការដ្ឋានរ៉ែ នៅខេត្តមណ្ឌលគិរី ខែមេសា និងឧសភា ឆ្នាំ២០០៨** | |
|---|---|
| **ទីតាំងភូមិ** | **កង្វល់របស់សហគមន៍ទៅលើសកម្មភាពរ៉ែ** |
| ភូមិ ពូឆប<br>ភូមិ ពូអន្ទ្រែង<br>ភូមិ ពូលេស<br>(ឃុំដាក់ដាំ ស្រុកអូររាំង) | -ការពិគ្រោះយោបល់មានធ្វើតែជាមួយនឹងចាស់ទុំក្នុងភូមិ និងមេឃុំ-តែមិនមែនជាមួយអ្នកភូមិទូទៅទេ<br>-ការខួងដីមានធ្វើនៅក្បែរផ្លូវ<br>-សត្វធ្លាក់ចូលទៅក្នុងរណ្តៅ<br>-ការបាត់បង់ដីសក្ការៈ |
| ភូមិ ពូរ៉ាប៉ែត<br>ភូមិ ត្រាំកាច់<br>ភូមិ ក្រងតេះ<br>(ឃុំក្រងតេះ ស្រុកពេជ្រាដា) | -ក្រុមហ៊ុនពិគ្រោះយោបល់តែជាមួយអតីតមេឃុំ អភិបាលស្រុកនិង ខេត្តប៉ុណ្ណោះ<br>-បាត់បង់ដើមឈើសម្រាប់ប្រមូលជ័រ សត្វព្រៃ និងធនធានព្រៃឈើ ដែលមានសារៈសំខាន់សម្រាប់រកចំណូល<br>-ការបំពុលទឹក<br>-ការបាត់បង់ទីផ្សារ<br>-ការបាត់បង់ដី |

[65] Beaumont, *Extractive Industry Mining Study, Social and Environmental Impacts, Ratanakiri & Mondulkiri.*

| | |
|---|---|
| ភូមិ ប៊ូស្រា<br>ភូមិ ឡាម៉េស<br>ភូមិ ពូចា<br>ភូមិ ពូលូ<br>(ឃុំប៊ូស្រា ស្រុកពេជ្រាដា) | -កង្វល់ផ្នែកបរិស្ថាន<br>-ការបាត់បង់តំបន់រ៉ែសម្រាប់កូនចៅជំនាន់ក្រោយ<br>-ការបាត់បង់កន្លែងសក្ការៈ<br>-កំណើននៃការឈឺ និងស្លាប់<br>-បាត់បង់ធនធានសម្រាប់កូនចៅជំនាន់ក្រោយ |
| ភូមិ ពូតាំង ១<br>ភូមិ ពូតាំង ២<br>ភូមិ ពូតាំង ៤<br>(ឃុំរមនា ស្រុកពេជ្រាដា) | -ការពិគ្រោះយោបល់មានធ្វើតែជាមួយនឹងចាស់ទុំក្នុងភូមិ និងមេឃុំ តែមិនមែន ជាមួយអ្នកភូមិទូទៅទេ |
| ភូមិ ហ្គាទី<br>(ឃុំស្រែព្រះ ស្រុកកែវសីមា) | -ការពិគ្រោះយោបល់មានធ្វើតែជាមួយនឹងចាស់ទុំក្នុងភូមិ និងមេឃុំ តែមិនមែនជាមួយអ្នកភូមិទូទៅទេ<br>-បាត់បង់ធនធានព្រៃឈើ ពិសេសដើមឈើយកជ័រ<br>-បាត់បង់សត្វព្រៃ<br>-គ្រោះថ្នាក់បរិស្ថាន ដូចជាការបំពុលទឹក<br>-សត្វធ្លាក់ចូលទៅក្នុងរណ្តៅ |
| ភូមិ អូរក្លូ (តំបន់មេសាន)<br>(ឃុំចុងផ្លាស់ ស្រុកកែវសីមា) | -ការកើនឡើង និងការពង្រីកនៃជំរុំជីករករ៉ែ<br>-អ្នកភូមិរងការបង្ខំ និងគំរាមកំហែងអោយលក់ដី សម្រាប់អោយគេជីកយករ៉ែ<br>-ការបាត់បង់ដីស្រែ ចំការ និងសមត្ថភាពចិញ្ចឹមសត្វ<br>-បាត់បង់មុខរបរ<br>-ការប៉ះពាល់លើសុខភាព និងសុខមាលភាពរបស់មនុស្ស<br>-ការស្លាប់ដោយធ្លាក់ចូលក្នុងរណ្តៅរ៉ែ<br>-ការខូចបរិស្ថាន |
| ភូមិ អូខ្វាវ (តំបន់អូរខ្វាវ)<br>(ឃុំចុងផ្លាស់ ស្រុកកែវសីមា) | -ការប្រើជាតិគីមីក្នុងរ៉ែមាសដែលប៉ះពាល់ដល់សុខភាពនិងបរិស្ថាន<br>-ការបាត់បង់ដីស្រែ ចំការ និងសមត្ថភាពចិញ្ចឹមសត្វ<br>-បាត់បង់មុខរបរ |
| ភូមិ កែទៀត<br>ភូមិ ណងកេលិក<br>(ឃុំណងកេលិក ស្រុកកោះញែក) | -ការពិគ្រោះយោបល់មានធ្វើតែជាមួយនឹងអាជ្ញាធរមូលដ្ឋាន<br>-ការបាត់បង់ដីស្រែ ចំការ និងវាលស្មៅសម្រាប់សត្វស៊ី<br>-ការបាត់បង់ព្រៃ និងផ្ទះ |

ប្រភព: Pearl Beaumont, *Extractive Industry Mining Study, Social and Environment Impacts, Ratanakiri & Mondulkiri,* Phnom Penh, Development and Partnership in Action (DPA), July 2008

ថ្មីបើក្រុមហ៊ុនរ៉ែនៅខេត្តមណ្ឌលគីរី រហូតមកដល់ពេលនេះ បានទទួលត្រឹមតែអាជ្ញាប័ណ្ណរុករករ៉ែក្តី អង្គការមិនមែនរដ្ឋាភិបាលបានសង្កេតឃើញថា ក្រុមហ៊ុនខ្លះបានឈានដល់ដំណាក់កាលធ្វើអាជីវកម្មហើយ។ ដូច្នេះការធ្វើអាជីវកម្មរ៉ែ នៅក្រោមអាជ្ញាប័ណ្ណរុករកគឺ ជាការរំលោភលើកិច្ចព្រមព្រៀង ដែលទាមទារឱ្យមានការផ្អាកអាជ្ញាប័ណ្ណ ដោយរង់ចាំការស៊ើបអង្កេតសិន [៦៦] ។

យោងតាមលទ្ធផលរកឃើញពីការស្រាវជ្រាវមុនៗ អ្នកស្រាវជ្រាវរបស់គម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) បានចុះធ្វើការសិក្សាផ្ទាល់នៅតាមមូលដ្ឋាន នៅភូមិហ្កាទី ស្រុកកែវសីមា និង ភូមិពូរ៉ាប៉ែត ក្នុងស្រុកពេជ្រាដា ដែលខាងក្រោមនេះ គឺជាការពណ៌នាពីសកម្មភាពដំណើរការទាញរ៉ែនៅតាមភូមិមួយៗក្នុងតំបន់នេះ។

## ការពង្រីកសកម្មភាពរ៉ែ នៅភូមិហ្កាទី និងភូមិពូរ៉ាប៉ែត

ការពង្រីកសកម្មភាពរ៉ែនៅភូមិហ្កាទីក្នុងស្រុកកែវសីមា និងភូមិពូរ៉ាប៉ែតក្នុងស្រុកពេជ្រាដាបាន ធ្វើឡើង ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នា។ អ្នកភូមិជនជាតិព្នងបានគិតថា តំបន់ដែលមានរ៉ែ នៅភូមិទាំងពីរ គឺជាកន្លែងស័ក្តិសិទ្ធិ។ សកម្មភាពរ៉ែបានចាប់ផ្តើម នៅពេលដែលមានអ្នកចំណាកស្រុករករ៉ែជាជនជាតិខ្មែរចូលមកភូមិហ្កាទី នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ និង ភូមិពូរ៉ាប៉ែត នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០។ ការហូរចូលនូវអ្នកចំណាកស្រុកជនជាតិខ្មែរជាបន្តបន្ទាប់ ដោយមានទាំងសំភារៈនិងបច្ចេកទេសទំនើប ធ្វើអោយឆាប់ខ្សត់ធនធានរ៉ែមាសស្រទាប់ដីខាងលើ ហើយមកត្រឹមពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០ ជាពេលដែលអ្នករុករករ៉ែផ្ទាល់ខ្លួនមានច្រើន ហើយក៏បញ្ចប់ទៅវិញនៅភូមិទាំងពីរ។ ក្នុងឆ្នាំ២០០៦ ក្រុមហ៊ុនចិន ហាយឡានបានចាប់ផ្តើមសកម្មភាពរុករករ៉ែនៅភូមិហ្កាទី និងក្រុមហ៊ុនវៀតណាម ហ្គោលមេថលគ្រុបបានចាប់ផ្តើមប្រតិបត្តិការនៅភូមិពូរ៉ាប៉ែត។ ក្រុមហ៊ុនទាំងពីរបានទទួលអាជ្ញាប័ណ្ណរុករករ៉ែលាតសន្ធឹងយ៉ាងធំនៅតំបន់ ក្នុងភូមិទាំងពីរ។

### ការពង្រីកសកម្មភាពរ៉ែនៅភូមិហ្កាទី

តំបន់រុករករ៉ែមាសនៅភូមិហ្កាទី ស្ថិតនៅតាមបណ្តោយអូរខ្នង ដែលជនជាតិព្នងចាត់ទុកថាជាតំបន់ព្រៃគោរពបូជា មានចម្ងាយប្រហែលជា ៤ គ.ម. ពីលំនៅដ្ឋានក្នុងភូមិ (រូបទី៥)។ ទោះបីជា ជនជាតិព្នងតែងចូលទៅ ក្នុងតំបន់ព្រៃនោះជារឿយៗ ដើម្បីប្រមូលអនុផលព្រៃឈើ ដងជ័រ នេសាទ និងប្រម៉ាញ់សត្វតាមបែបប្រពៃណីក៏ដោយ ក៏ពួកគេមិនធ្លាប់បានកាប់ទន្រ្ទានព្រៃធ្វើចំការវិលជុំនោះឡើយ ដោយគិតថា

[66] “NGO Position Paper on Environmental and Social Impacts of Expansion of Extractive Industries Sector”, November 2008.

ព្រៃមាសនេះជាកន្លែងស័ក្តិសិទ្ធិ។ រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ មានអ្នកគោចររករ៉ែជាជនជាតិខ្មែរ ដែលធ្លាប់ជីករ៉ែនៅឃុំមេម៉ង់បានមកដល់ភូមិហ្គាទី ហើយបានរកឃើញមាស នៅអូរខ្ទង។ ការរកឃើញរបស់គាត់បានផ្សព្វផ្សាយពីម្នាក់ទៅម្នាក់នៅតាមផ្សារលក់មាស ដែលធ្វើអោយទាក់ទាញខ្មែរចំណាកស្រុក ដទៃទៀត មកតំបន់នេះ ដើម្បីរកលាភសំណាង។ សិប្បករធនធានរ៉ែជនជាតិខ្មែរទាំងនេះ បានសង់ជំរកនៅកន្លែងរុករករ៉ែ ដើម្បីស្នាក់នៅ និងធ្វើការតែម្នាក់ឯង ឬជាមួយប្រពន្ធ និងកូន។ អ្នកភូមិជនជាតិព្នងមួយចំនួនក៏បានរករ៉ែជាលក្ខណៈបុគ្គល ដើម្បីរកប្រាក់ បន្ទាប់ពីទំនេរពីការដាំដុះដំណាំចំការ។

**រូបទី ៥: ផែនទីភូមិហ្គាទី និងតំបន់រុករករ៉ែរបស់ក្រុមហ៊ុន ហាយឡាន នៅឃុំស្រែព្រះ**




កាលពីដំបូង អ្នករុករករ៉ែ ជាជនជាតិខ្មែរ ទាំងនោះប្រើប្រាស់ឧបករណ៍ដោយដៃមានដូចជា ចបជីក ចបកាប់ និងប៉ែល ដែលអាចទិញបាននៅក្នុងស្រុក។ អ្នករុករករ៉ែបានប្រើប្រាស់ឧបករណ៍ទាំងនោះ ដើម្បីសំអាតដី ហើយជីករណ្តៅរាក់ៗដែលមានជំរៅប្រហែល ០.៥ ម៉ែត្រ រួចលាងដីរ៉ែ និងចំរោះយកមាស។ ជនជាតិខ្មែរទាំងនោះ ជីករុករករ៉ែជាលក្ខណៈបុគ្គល ឬជាមួយគ្រួសារ ឬជាក្រុមនៅកន្លែងរណ្តៅរ៉ែមាស ហើយចែកផលដែលបានមកស្មើៗគ្នា។ ដោយតំបន់នោះអាចផ្តល់មាសច្រើន ដូច្នេះហើយអ្នករកមាសជាជនជាតិខ្មែរ ដែលមានទុនបានទិញឧបករណ៍សម្រាប់ជីក ម៉ាស៊ីនបាញ់ទឹក និងចំរោះ។ អ្នកដែលមានទុនទាំងនេះបានចាប់ផ្តើមជួល កម្មករដើម្បីចំរោះដីរ៉ែដែលមានបរិមាណច្រើន ដែលពួកគេជីកបាន។

នៅក្នុងឆ្នាំ១៩៩៨ នៅតំបន់អូរខ្ទង ចំនួនអ្នករុករករ៉ែបាន កើនឡើងរហូតដល់ប្រហែល ១០០នាក់ ទាំងសិប្បករធនធានរ៉ែ និងកម្មកររ៉ែ។ ចំនួនប្រជាជនយ៉ាងសន្ធឹកសន្ធាប់នេះ បានទាក់ទាញអោយមានការ

លក់ដូរម្ហូបអាហារនិងភេសជ្ជៈ ហើយក៏មានប៉ូលីសនៅក្នុងមូលដ្ឋានចុះទៅម្តងម្កាល ដើម្បីស្វែងរកកំរៃក្រៅផ្លូវការផងដែរ។ ការកើនឡើងនៃអ្នករកមាសផ្ទាល់ខ្លួន បានកើនឡើងយ៉ាងខ្ពស់ តែទោះជាយ៉ាងណាត្រូវបានធ្លាក់ចុះមកវិញជាបន្តបន្ទាប់។ លំហូរនៃអ្នករករ៉ែនេះអាស្រ័យដោយភាពខ្សត់មាសនៅតាមរណ្តៅរ៉ែដែលធ្វើអោយពួកគេមិនអាចរកផលចំណេញ។ អ្នករកមាសដែលមានទុនក៏មិនអាចរកចំណូលគ្រប់គ្រាន់ទូទាត់កំរៃពលកម្ម និងប្រេងសាំង។ ដូចគ្នានេះដែរ សិប្បករធនធានរ៉ែអាចរកបានត្រឹមតែ១ ឬ២ហ៊ុនប៉ុណ្ណោះ (១ហ៊ុន=0.៣៧៥ក្រាម) ក្នុងមួយថ្ងៃ ហើយពេលខ្លះ ធ្វើការជីករកមាសជាច្រើនថ្ងៃ តែមិនបានទទួលអ្វីសោះ។ ចំនួនអ្នករុករករ៉ែជាជនជាតិខ្មែរបានថយចុះយ៉ាងលឿន។ អ្នកខ្លះអះអាងថា អ្នករករ៉ែបានចាកចេញ ដោយសារតែ ការងារនេះប្រឈមខ្ពស់នឹងគ្រោះថ្នាក់ និង ការឆ្លងជំងឺគ្រុនចាញ់។

## ការរុករករ៉ែរបស់ក្រុមហ៊ុនកូរ៉េ

នៅក្នុងឆ្នាំ១៩៩៩ តំណាងក្រុមហ៊ុនកូរ៉េ ដែលរួមដំណើរដោយអ្នកបកប្រែម្នាក់ បានចូលមកក្នុងភូមិហ្គាទី ដើម្បីពិភាក្សាជាមួយប្រធានភូមិ និងចាស់ទុំ។ បុគ្គលិកក្រុមហ៊ុន បានពន្យល់ប្រាប់ ពីវត្តមាន និងសកម្មភាពដែលពួកគេ បានទទួលការអនុញ្ញាតពីរដ្ឋាភិបាលក្នុងការរុករករ៉ែនៅក្នុងតំបន់អូរខ្វងរយៈពេល ២ឆ្នាំ។ ប៉ុន្តែគេមិនបានប្រាប់អំពីទំហំដីសម្បទានជាក់លាក់ឡើយ។ អ្នករុករករ៉ែជនជាតិកូរ៉េព្យាយាមទំនាក់ទំនងល្អជាមួយអ្នកភូមិហ្គាទី។ ដោយមានការជួបជុំគ្នាច្រើនលើក ចាស់ទុំជនជាតិព្នងបានឆ្លើយតបជាវិជ្ជមានចំពោះក្រុមហ៊ុន ដោយអនុញ្ញាតអោយសាងសង់លំនៅដ្ឋាន នៅក្នុងភូមិសម្រាប់ជនជាតិកូរ៉េ និងកម្មករខ្មែរ។ លំនៅដ្ឋាន ប្រវែង១០ម៉ែត្រ បានធ្វើឡើងសម្រាប់អោយកម្មករ ស្នាក់នៅដោយបំពាក់នូវម៉ាស៊ីនភ្លើងដែលបានជួយផ្គត់ផ្គង់ អគ្គីសនីនៅក្នុងភូមិផងដែរ។

ដំបូង សកម្មភាពរុករករ៉ែរបស់ក្រុមហ៊ុនបានចុះមកពិនិត្យមើលយ៉ាងញឹកញាប់ ហើយដំណើរការរុករករ៉ែ ក៏គ្មានឧបសគ្គអ្វីឡើយ។ នៅពេលចាប់ផ្តើមកម្មករក្រុមហ៊ុនបានជីកដី ហើយយកដីរ៉ែខ្លះដាក់ក្នុងស្បោងដើម្បីធ្វើពិសោធន៍។ នៅក្នុងដំណើរការនេះ អ្នករុករករ៉ែដែលមានបទពិសោធន៍ត្រូវបានជួលឱ្យជូនដំណើរបុគ្គលិកក្រុមហ៊ុនដើម្បីរុករកតំបន់រ៉ែ។ អ្នកភូមិជនជាតិព្នងមួយចំនួនត្រូវបានជួលធ្វើជាកម្មករ ជាមួយក្រុមហ៊ុនកូរ៉េដែលទទួលបានប្រាក់កំរៃ១០ 000រៀល(២.៥0ដុល្លា)ក្នុងមួយថ្ងៃ។ ពីរបីខែបន្ទាប់មកសកម្មភាពមមាញឹករបស់បុគ្គលិកក្រុមហ៊ុនកូរ៉េនិងកម្មករខ្មែរ បានផ្អាកម្តងម្កាល។ ប៉ុន្មានខែក្រោយមកទៀត អ្នករុករករ៉ែមកតែម្តងម្កាលប៉ុណ្ណោះ ឬមិនមកសោះក៏មាន។ ប្រជាពលរដ្ឋបាននិយាយថា ថៅកែក្រុមហ៊ុនម្នាក់បានកើតជំងឺ ហើយស្លាប់ ប៉ុន្តែពុំមានសេចក្តីពន្យល់ឱ្យបានច្បាស់លាស់ឡើយ។ ប្រហែល ១ឆ្នាំក្រោយមក សកម្មភាពរបស់ក្រុមហ៊ុនត្រូវបានបញ្ឈប់ទាំងស្រុង។

## ប្រតិបត្តិការរុករករ៉ែរបស់ក្រុមហ៊ុន ហាយឡាន[៦៧]

នៅក្នុងឆ្នាំ២០០៦ តំណាងមកពីក្រុមហ៊ុនរុករករ៉ែចិន ហាយឡាន បានចូលមកភូមិហ្គាទីដើម្បីប្រមូលសំណាកដីរ៉ែមាសពីកន្លែងជីករ៉ែ។ មិនដូចជាក្រុមហ៊ុនកូរ៉េនោះឡើយ ពួកគេមិនបានជួបជាមួយចាស់ទុំ ឬអាជ្ញាធរភូមិដើម្បីពន្យល់ពីគោលបំណងនោះឡើយ។ ប្រហែលជារយៈពេល ១ឆ្នាំ អ្នករករ៉ែជនជាតិចិនបានចេញចូលម្តងម្កាលនៅតំបន់រុករករ៉ែជាក្រុមតូចៗ ដើម្បីប្រមូលដីរ៉ែយកធ្វើសំណាក ដោយមិនមានការភ្ជាក់ផ្អើលដល់អ្នកភូមិជនជាតិព្នងឡើយ។ តែនៅឆ្នាំ២០០៧ នៅពេលដែលបុគ្គលិកក្រុមហ៊ុនចិនបានដឹកសំភារៈ និងកម្មករពេញរថយន្តចូលទៅកន្លែងរុករករ៉ែ អ្នកភូមិជនជាតិព្នងបានបញ្ឈប់ដំណើររបស់ក្រុមហ៊ុន[៦៨]។ អ្នករុករករ៉ែជនជាតិចិនក៏បានប្រាប់អ្នកភូមិវិញថា ពួកគេមានអាជ្ញាប័ណ្ណមកពីរដ្ឋាភិបាល ដើម្បីរុករករ៉ែមាសនៅ តំបន់នេះ។ នៅពេលដែលជនជាតិព្នងលើកបញ្ហានេះ ជាមួយអាជ្ញាធររដ្ឋបាលនៅមូលដ្ឋាន ទើបពួកគេដឹងថាការអនុញ្ញាតនេះចេញពីថ្នាក់ជាតិ ដែលពួកគេមិនមានជំរើស ទើបសំរបអោយក្រុមហ៊ុន ប្រតិបត្តិការរុករករ៉ែ។

នៅពេលចូលស្នាក់នៅក្នុងភូមិដំបូង អ្នករុករករ៉ែជនជាតិចិនបានជួលផ្ទះនៅក្នុងភូមិ រួចហើយសាងសង់រោងវែងមួយនៅមុខផ្ទះអ្នកភូមិសម្រាប់កម្មករខ្មែរ។ ប៉ុន្តែទំនាក់ទំនងរវាងអ្នករុករករ៉ែទាំងនោះជាមួយអ្នកភូមិជនជាតិព្នងពុំសូវស្និទ្ធស្នាលឡើយ។ ប្រហែលជា ១ឆ្នាំក្រោយមក អ្នករុករករ៉ែទាំងនោះបានចាកចេញពីភូមិ ហើយបាន សាងសង់ផ្ទះវែងផ្ទាល់ខ្លួន ដើម្បីស្នាក់នៅកន្លែងរុករករ៉ែ។ កាលពីដំបូង ក្រុមហ៊ុនចិនបានជួលជនជាតិព្នងមួយចំនួន ធ្វើជាកម្មករជីករណ្តៅយកដីរ៉ែមាស។ កម្មករជនជាតិព្នងទាំងនេះបានឈប់ធ្វើការប្រហែលជាមួយខែក្រោយ ដោយត្អូញត្អែរថាឱ្យពួកគេធ្វើការដូចជាកំលាំងម៉ាស៊ីន។ បន្ទាប់មកទៀត កម្មករជនជាតិខ្មែរក៏ប្រឈមផលលំបាកដូចគ្នា ហើយបានចាកចេញអស់។

នៅខែវិច្ឆិកា ឆ្នាំ២០០៨ ក្រុមហ៊ុនចិនបាននាំកម្មករប្រមាណជា ៦០នាក់ និងអមដោយកំលាំងប្រដាប់អាវុធ ព្រមទាំងនាំមកគ្រឿងចក្រធុនធ្ងន់ដូចជា ម៉ាស៊ីនឈូសដី ម៉ាស៊ីនកាយដី ម៉ាស៊ីនកិនបំបែកថ្ម និងម៉ាស៊ីនភ្លើងជាដើម។ ជាមួយនិងឧបករណ៍ទាំងនេះ ក្រុមហ៊ុនអាចជីករណ្តៅរ៉ែបានកាន់តែធំ ទទឹងជិត១ម៉ែត្រ និងបណ្តោយ ៥ម៉ែត្រ ហើយជំរៅ រហូតដល់ជាង ២-៣ម៉ែត្រ។ ដោយម៉ាស៊ីនទាំងនោះ គេអាចបង្កើនការប្រមូលចំនួនដីរ៉ែទ្វេដង។ ក្នុងការសម្រួលដល់ការដឹកជញ្ជូនចេញចូល ក្រុមហ៊ុនក៏បានឈូសឆាយផ្លូវចូលទៅការដ្ឋាន

---

[67] នៅខែសីហា ឆ្នាំ២០១០ អ្នកសិក្សាស្រាវជ្រាវដឹងថា ក្រុមហ៊ុន ហាយឡាន បានផ្ទេរតំបន់សម្បទានរ៉ែទៅឱ្យក្រុមហ៊ុន ដែលជាជនជាតិវៀតណាម ប៉ុន្តែមិនមានព័ត៌មានច្បាស់ពីបញ្ហានេះទេ។

[68] នៅក្នុងឆ្នាំ១៩៩៨ អ្នកភូមិហ្គាទីបានធ្វើការតវ៉ាជាមួយក្រុមហ៊ុនសម្បទានព្រៃឈើ សាមលីញ ដែលចូលកាប់ឈើច្បោះរបស់ពួកគេ ដោយរឹបអូសនូវរណាយន្ត ទៅទុកនៅសាលាស្រុក។ សូមមើល McAndrew, John P., Mam Sambath, Hong Kimly, and Ly Bunthai, *Indigenous Adaptation to a Decline in Natural Resources: The Experience of Two Phnong Communities in Northeast Cambodia*, Phnom Penh, CIDSE, September 2003.

រុករករ៉ែផងដែរ។ នៅចុងរដូវប្រាំងខែមេសា ឆ្នាំ២០០៩ ម៉ាស៊ីនកាយដីនិង មាស៊ីនឈូសដីត្រូវបានគេយកទៅជួសជុល ដូច្នេះមានកំលាំងកម្មករតិចតួចនៅកន្លែងការដ្ឋាន។

ក្នុងខែ មេសា ឆ្នាំ២០០៩ ក្រុមហ៊ុនបានប្រាប់ជនជាតិព្នងនៅភូមិហ្គាទីក្នុងកិច្ចប្រជុំថា ក្រុមហ៊ុនអាចពង្រីកសកម្មភាពរុករករ៉ែពី ២០ គ.ម$^{២}$. ដែលកំពុងប្រតិបត្តិការសព្វថ្ងៃ ទៅ ៨០ គ.ម$^{២}$. ដូចអាជ្ញាប័ណ្ណដែលបានទទួល។ ការពង្រីកនេះមិនត្រឹមតែនៅក្នុងភូមិហ្គាទីប៉ុណ្ណោះទេ តែនឹងចូលដល់ភូមិពូគង់ ពូយា និងអូរច្រាថែមទៀត។ ក្រុមហ៊ុនក៏បានប្រកាសផងដែរថា ពួកគេនឹងទំនងជាសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្មរ៉ែក្នុងពេលអនាគតឆាប់ៗនេះ។

## ការពង្រីកសកម្មភាពដីភូមិពូរ៉ាប៉ែត

តំបន់រុករករ៉ែនៅភូមិពូរ៉ាប៉ែតក៏ត្រូវបានគេស្គាល់ថា ជាព្រៃមាសផងដែរ ព្រោះសំបូរទៅដោយរ៉ែមាស និងត្បូង ដែលស្ថិតនៅតំបន់ខ្ពង់រាប នៅតាមបណ្តោយអូរផ្លែ និងមានចំងាយប្រមាណ២០គីឡូម៉ែត្រ ពីភូមិពូរ៉ាប៉ែត ឃុំក្រងតេះ (រូបទី៦)។ ទោះបីជាជនជាតិព្នងជាអ្នកស្រុកដើមបានដើររើសត្បូងនៅក្នុងតំបន់នោះក្តី តែពួកគេបានពឹងផ្អែកយ៉ាងសំខាន់លើការដាំដុះចំការវិលជុំ នេសាទ និងប្រមូលផលិតផលព្រៃឈើ សម្រាប់ការចិញ្ចឹមជីវិត។ ប៉ុន្តែសកម្មភាពរុករករ៉ែមិនធ្លាប់មានពីមុនទេ ទោះបីជាពួកគេធ្លាប់ដឹងថា តំបន់នេះមានត្បូងតាំងពីទសវត្សរ៍ឆ្នាំ១៩៦០ ក៏ដោយ ទើបតែដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ នៅពេលដែលមានជនជាតិឡាវ និងជនជាតិខ្មែរចំណាកស្រុកចូលមក ទើបសកម្មភាពរ៉ែ ចាប់ផ្តើមឡើង។ អ្នករករ៉ែមួយចំនួនបានស្នាក់នៅកន្លែងជីករ៉ែ ហើយអ្នកខ្លះទៀត បានជួលផ្ទះស្នាក់នៅភូមិពូរ៉ាប៉ែត។ នៅពេលនោះអ្នកចំណាកស្រុក ដើម្បីរករ៉ែផ្ទាល់ខ្លួនមានប្រហែល ជា៣០នាក់។ ក្រៅពីនេះ នៅមានជនជាតិព្នងប្រហែលជា១០នាក់ ធ្វើការរុករករ៉ែគ្រាន់តែជាការងារបន្ទាប់បន្សំ ក្រៅពីមុខរបរចិញ្ចឹមជីវិតសំខាន់តាមបែបប្រពៃណី។ ចំពោះសកម្មភាពរុករករ៉ែមាស ភាគច្រើននៅក្នុងព្រៃនោះ ធ្វើឡើងនៅរដូវប្រាំង ចាប់ពីខែវិច្ឆិកា ដល់ខែមិនា។

កាលពីដំបូងរណ្តៅរ៉ែភាគច្រើនបានជីកជាលក្ខណៈបុគ្គល ឬ គ្រួសារ នៅតាមបណ្តោយអូរផ្លែ។ ក្រៅពីនេះ ជាធម្មតាក៏មានអ្នកជីករណ្តៅរួមគ្នាជាក្រុមពី៣-៤នាក់ ហើយចែកមាសដែលរកបានស្មើៗគ្នា។ អ្នករករ៉ែទាំងនោះបានប្រើប្រាស់ឧបករណ៍ដោយដៃដូចជាចបកាប់ ចបជីក ដើម្បីជំរះ និងជីករណ្តៅរ៉ែ។ រណ្តៅខ្លះមានជំរៅជ្រៅ ដែលអាចបង្ករបួសស្នាមនៅពេលដែលធ្លាក់ចូល។ អ្នករុករករ៉ែមាសមិនអាចដឹងថា តើរណ្តៅណាមានមាសច្រើន ឬក៏អត់នោះឡើយ ដូច្នេះការទទួលផលគឺមិនទៀងទាត់នោះឡើយ។ ពេលខ្លះគេព្យាយាមជីករណ្តៅធំៗ ប៉ុន្តែជាក់ស្តែងគេមិនអាចទទួលបានអ្វីសោះក៏មាន។ ហេតុដូច្នេះហើយ ចំនួននៃអ្នករុករករ៉ែផ្ទាល់ខ្លួននៅតាមបណ្តោយអូរផ្លែមិនមានការប្រែប្រួលឡើយ នៅទសវត្សរ៍ឆ្នាំ១៩៩០។ មកដល់ទសវត្សរ៍បន្ទាប់ទៀត នៅពេលដែលមានការនាំមកនូវសំភារៈ និងបច្ចេកទេសទំនើប ទើបមានការហូរចូលនូវអ្នករុករករ៉ែកាន់តែកើនឡើង។

### រូបទី៦: ផែនទីភូមិពូរ៉ាប៉ែត និងតំបន់រុករករ៉ែ ឃុំក្រងតេះ




ចាប់តាំងពីឆ្នាំ២០០០ ចំនួនអ្នករុករករ៉ែចូលមកក្នុងភូមិពូរ៉ាប៉ែតកាន់តែកើនឡើងច្រើន។ អ្នកចំណាកស្រុកជនជាតិខ្មែរ ភាគច្រើនមកពីខេត្តកំពង់ចាម ស្វាយរៀង និងក្រចេះ បានចូលមកខេត្តមណ្ឌលគីរី ហើយបានសំរុកនាំគ្នាមកជីកមាស ដែលពួកគេបានដឹងពីមាត់មួយទៅមាត់មួយថា មានមាសច្រើននៅតំបន់អូរផ្លែ។ នៅពេលនោះដែរ ជនជាតិខ្មែរដែលមានទុន បាននាំយកនូវឧបករណ៍បច្ចេកទេសថ្មីៗ សម្រាប់ចំរោះមាស ដែលពួកគេអាចទាញយកមាសបានច្រើនពីដីរ៉ែ និងទទួលផលចំណេញច្រើន។ អ្នកជីករ៉ែមួយចំនួនបានជួលឧបករណ៍ និងម៉ាស៊ីន ដើម្បីចំរោះមាសហើយបានលក់មាសទៅអោយម្ចាស់ម៉ាស៊ីននោះវិញ ចំណែកអ្នកខ្លះទៀត បានលក់ដីរ៉ែទៅអោយម្ចាស់ម៉ាស៊ីន។ ចំនួនអ្នកចំណាកស្រុកជីករ៉ែបានកើនឡើងយ៉ាងលឿនរហូតដល់ ១០០នាក់ នៅដើមសហសវត្សរ៍ថ្មីនេះ។

ជនជាតិព្នងនៅភូមពូរ៉ាប៉ែតក៏នៅតែបន្តទទួលផលប្រយោជន៍ពីសកម្មភាពរុករ៉ែនេះ។ អ្នកភូមិជនជាតិដើមមួយចំនួនបានធ្វើជាកម្មករអោយអ្នកដែលមានទុនជាជនជាតិខ្មែរទាំងនោះ ដោយទទួលបានប្រាក់ឈ្នួល ៧០០០រៀល ក្នុងមួយថ្ងៃ ទោះបីជាពួកគេរកមាសបាន ឬក៏អត់ក៏ដោយ។ ហើយខ្លះទៀតធ្វើការរុករករ៉ែមាសជាក្រុម ៤-៥នាក់ ដោយជីករណ្តៅរួមគ្នាពី៤-៥ថ្ងៃ។ បន្ទាប់ពីចំរោះដីរ៉ែរួច ពួកគេអាចចែកមាសគ្នាបាន ៣ ទៅ ៤ ជី (១ជី=៣.៧៥ក្រាម)។ ជនជាតិព្នងម្នាក់បានអះអាងថា ជួនកាលគាត់អាចរកមាសបាន ១០ជី បន្ទាប់ពីធ្វើសកម្មភាព ៤-៥ថ្ងៃ។ ប៉ុន្តែការរកមាសបានកាន់តែច្រើន ការបំពុលបរិស្ថានក៏កាន់តែកើនឡើងដែរ។ បច្ចេកទេសសម្រាប់ចំរោះមាសទំនើប ធ្វើអោយមានការបំពុលទឹកនៅអូរផ្លែកាន់តែច្រើន។

មកដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០ ចំនួនអ្នករុករករ៉ែនៅតំបន់អូរផ្លែ បានកើនឡើង យ៉ាងហោច ណាស់ ៥០០នាក់ ដោយសារតែមានការនិយាយបំផ្លើស ពីផលបានមកពីការជីកមាស។ នៅពេលនោះគេឃើញ មានវត្តមានជនជាតិឡាវ និងជនជាតិចាម នៅកន្លែងជីកមាសផងដែរ។ ដោយហេតុតែ អ្នកចំណាកស្រុក កាន់តែច្រើនស្នាក់នៅកន្លែងរករ៉ែ ដែលមានរយៈពេលយូររហូតដល់ ៦ខែទៅ១ឆ្នាំ បង្កអោយមានអ្នកលក់ដូរ ម្ហូបអាហារ និងភេសជ្ជៈដែលអាចទទួលផលចំណេញយ៉ាងច្រើន។ អ្នករុករករ៉ែមាសកាន់តែកើនឡើងច្រើន នាំឱ្យមាស នៅតាមរណ្តៅដីស្រទាប់លើដែលអាចជីកបាន កាន់តែខ្សត់ទៅៗហើយធ្វើអោយចំនួនសិប្បករ ធនធានរ៉ែមានការធ្លាក់ចុះ។ ជាងនេះទៀត ការប្រឈមមុខនឹងជំងឺគ្រុនចាញ់កាន់តែខ្ពស់ នៅពេលដែលពួកគេ ចូលជីករណ្តៅរ៉ែនៅក្នុងព្រៃជ្រៅៗ ដែលនេះជាសញ្ញានៃការចាប់ផ្តើមចាកចេញពីតំបន់របស់អ្នកចំណាកស្រុក ទាំងនោះ។ នៅត្រឹមឆ្នាំ២០០៦ អ្នករករ៉ែមាស និងត្បូង នៅតំបន់អូរផ្លែបានកើនឡើងខ្ពស់ ហើយបានធ្លាក់ចុះ វិញ ជាបណ្តើរៗដែរ។

## ប្រតិបត្តិការរុករករ៉ែរបស់ក្រុមហ៊ុន ហ្គោលមេថលគ្រុប

នៅឆ្នាំ២០០៦ ក្រុមហ៊ុន ហ្គោលមេថលគ្រុប ដែលអ្នកភូមិស្គាល់ថា ជាក្រុមហ៊ុនវៀតណាម បាន ប្រើប្រាស់សិទ្ធិទាំងស្រុង នៅកន្លែងរុករករ៉ែមាសក្នុងតំបន់អូរផ្លែ ដែលមានចំងាយរាប់សិបគីឡូម៉ែត្រពីភូមិ ពូរ៉ាប៉ែត។ ជាលទ្ធផល អ្នកជីករ៉ែទាំងអស់ដែលជាជនជាតិខ្មែរចំណាកស្រុក និងជនជាតិព្នងត្រូវបានគេបង្ខំឱ្យ ចាកចេញពីតំបន់ជីកមាស។ ក្រោយមក ក្រុមហ៊ុនបានព័ទ្ធរបងលើផ្ទៃដីប្រហែល ១គ.ម$^{2}$. ហើយបានសាងសង់ ជំរុំ ដើម្បីធ្វើសកម្មភាពរុករករ៉ែនៅទីនោះ។ នៅក្នុងជំរុំនោះគឺជាជំរកស្នាក់នៅរបស់កម្មករជនជាតិវៀតណាម និង សម្រាប់ទុកឧបករណ៍ធុនធ្ងន់របស់ក្រុមហ៊ុន។ បុគ្គលិកក្រុមហ៊ុនមានទំនាក់ទំនងតិចតួចជាមួយអាជ្ញាធរ ឃុំក្រងតេះ និងចាស់ទុំនៅក្នុងភូមិពូរ៉ាប៉ែត ហើយមិនធ្លាប់បានប្រាប់អ្នកភូមិអោយចូលរួមកិច្ចប្រជុំផ្លូវការ ជា សាធារណៈ ដើម្បីប្រាប់ដំណឹងដល់ជនជាតិដើមភាគតិចពីសកម្មភាពរបស់ពួកគេទេ។ នៅក្នុងដំណើរការនេះ អ្នកភូមិជនជាតិព្នងក្នុងតំបន់ ដែលទៅនេសាទ បរបាញ់សត្វព្រៃ និងប្រមូលអនុផលព្រៃឈើ នៅតាមបណ្តោយ អូរផ្លែ ត្រូវដើរវាងជំរុំរ៉ែនោះដែរ ឬពួកគេអាចប្រឈមនឹងគ្រោះថ្នាក់ដោយកងកំលាំងប្រដាប់អាវុធ។ អ្នកភូមិ ជនជាតិព្នងមានការព្រួយបារម្ភផងដែរថា នៅក្នុងជំរុំនោះកំពុងតែចំរោះដីរ៉ែ ដែលមានប្រើប្រាស់ជាតិគីមីដែល អាចបំពុលដល់ទឹកនៅក្នុងអូរ ហើយប៉ះពាល់យ៉ាងខ្លាំងដល់ត្រី និងសត្វព្រៃ។ អ្នកភូមិបានត្អូញត្អែរផងដែរថា គ្រឿងចក្រ និងរថយន្តរបស់ក្រុមហ៊ុនបានបំផ្លាញផ្លូវសំខាន់ចូលទៅក្នុងភូមិដែលធ្វើឡើងដោយប្រើប្រាស់ថវិកា ឃុំ។

ក្នុងឆ្នាំ២០០៦នោះ ក្រុមហ៊ុនហ្គោលមេថលគ្រុបបានទទួលអាជ្ញាប័ណ្ណរុករករ៉ែលើផ្ទៃដីទំហំ២០៤គ.ម$^{2}$. នៅក្នុងតំបន់អូរផ្លែ ស្រុកពេជ្រាដា។ នៅក្នុងឆ្នាំ២០០៨ អាជ្ញាប័ណ្ណត្រូវបានពន្យាររយៈពេល២ឆ្នាំទៀត ដោយ សុំកាត់បន្ថយផ្ទៃដីត្រឹម ១៧៣ គ.ម$^{2}$. ជាងនេះទៅទៀត នៅឆ្នាំ២០០៦ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណរុករករ៉ែ

លើផ្ទៃដី ១៥៨ គ.ម$^{២}$. នៅតំបន់ភ្នំង្ហូត នៅក្នុងស្រុកពេជ្រាដា។ នាយកក្រុមហ៊ុនហ្គោលមេថលគ្រុប គឺជាជនជាតិបារាំងសញ្ជាតិខ្មែរ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីពាណិជ្ជករជនជាតិវៀតណាម។ ក្រុមហ៊ុនមិនទាន់បានចាប់ដៃគូជាមួយក្រុមហ៊ុនដទៃនៅឡើយ ប៉ុន្តែក្រុមហ៊ុនកំពុងសិក្សាពីលទ្ធភាពដែលអាចធ្វើទៅបានរួចហើយនឹងសំរេចស្វែងរកដៃគូធ្វើប្រតិបត្តិការការងារជាមួយ ប្រសិនបើក្រុមហ៊ុនអាចទទួលបានអាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវកម្មរ៉ែនោះ។

# សិទ្ធិជនជាតិដើមភាគតិច និងប្រតិបត្តិការធនធានរ៉ែ

ការរុករករ៉ែក្នុងទ្រង់ទ្រាយធំ នៅខេត្តមណ្ឌលគីរី មិនត្រឹមតែមាននៅក្នុងតំបន់ដែលត្រូវបានកំណត់ថាជាតំបន់ការពារតែប៉ុណ្ណោះទេ តែវាមានផងដែរនៅលើទឹកដីដូនតារបស់ក្រុមជនជាតិព្នង។ ការនេះនាំអោយមានការចោទសួរ ទៅលើសិទ្ធិជនជាតិដើមភាគតិចលើដីធ្លីនិងធនធានធម្មជាតិរបស់ពួកគេ ហើយនិងភាពចាំបាច់ដែលរដ្ឋត្រូវទទួលស្គាល់ និង គោរពសិទ្ធិទាំងនេះ។ ផ្នែកនេះចាប់ផ្តើមជាមួយការពិភាក្សាលើអនុសញ្ញាអន្តរជាតិដែល ការពារសិទ្ធិរបស់ជនជាតិដើមភាគតិច និងទំនាក់ទំនងទៅនឹងក្របខណ្ឌថ្មីនៃសកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវ។ ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការផ្តល់នូវការយល់ព្រមដោយសេរីនិងប្រាប់អោយដឹងជាមុនលើការធ្វើប្រតិបត្តិការរ៉ែដែលប៉ះពាល់ដែនដីនិងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ការផ្តល់សិទ្ធិក្នុងការយល់ព្រមពីសហគមន៍ ក៏ជាសកម្មភាពមួយនៃការធ្វើជំនួញដែលមានលក្ខណៈត្រឹមត្រូវ។ ហេតុផលលើកឡើងទាំងនេះត្រូវបានពិនិត្យ នៅក្នុងបរិបទនៃក្របខណ្ឌច្បាប់នាពេលបច្ចុប្បន្នរបស់ប្រទេសកម្ពុជា ហើយយកទៅ អនុវត្តក្នុងស្ថានភាពជាក់ស្តែង ដែលកំពុងមាននៅក្នុងភូមិដែលបានសិក្សាស្រាវជ្រាវ។

## សិទ្ធិជនជាតិដើមភាគតិច ដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិ

អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ការពារសិទ្ធិរបស់បុគ្គលនិងក្រុមជនជាតិដើមភាគតិចដែលមានសិទ្ធិពេញលេញសម្រាប់ខ្លួនគេ នៅក្រោមច្បាប់។ យ៉ាងណាក្តី ជនជាតិដើមភាគតិចមានវប្បធម៌ដោយឡែករបស់គេដែល ទាមទារឱ្យមានការទទួលស្គាល់សិទ្ធិសមូហភាពរបស់គេ ក្នុងការរស់នៅជាក្រុមមនុស្ស។ ជនជាតិដើមភាគតិច មានសិទ្ធិលើដីធ្លី ដែនដី និងធនធាន សិទ្ធិរក្សាវប្បធម៌ និងអត្តសញ្ញាណដោយឡែក និងសិទ្ធិស្វ័យគ្រប់គ្រង និងស្វ័យសំរេច។ ដើម្បីអោយគេទទួលស្គាល់ច្បាស់លាស់ សិទ្ធិទាំងនេះត្រូវតែបង្ហាញឱ្យឃើញពីលក្ខណៈសមូហភាព។ ការនេះបាននាំអោយអង្គការសហប្រជាជាតិ និងភ្នាក់ងារនានារបស់អង្គការនេះ បង្កើតបទដ្ឋានអន្តរជាតិដាច់ដោយឡែកមួយដែលទទួលស្គាល់និងតំកល់សិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច[៦៩]។

ការអនុម័តក្នុងមហាសន្និបាត លើសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចកាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧ គឺជាឱកាសប្រវត្តិសាស្ត្រមួយ សម្រាប់ការទទួលស្គាល់ និង ការពារសិទ្ធិរបស់ជនជាតិដើមភាគតិច។ សេចក្តីប្រកាសនេះទទួលស្គាល់សិទ្ធិស្វ័យសំរេចរបស់ជនជាតិដើមភាគតិច សិទ្ធិក្នុងការសំរេចលើអាទិភាពអភិវឌ្ឍន៍របស់គេ សិទ្ធិក្នុងការគ្រប់គ្រងដីធ្លី ដែនដី និងធនធានរបស់គេ សិទ្ធិក្នុងការផ្តល់ការយល់ព្រមដោយសេរីនិងប្រាប់អោយដឹងជាមុន លើការអភិវឌ្ឍន៍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើ

[69] United Nations Development Group Guidelines on Indigenous Peoples’ Issues, February 2008.

ធនធានរ៉ែ និងត្រូវតែទទួលបានសំណងចំពោះការប្រើប្រាស់ធនធានទាំងនេះដោយមិនត្រឹមត្រូវ (ប្រអប់ទី១)។ ជនជាតិដើមភាគតិចត្រូវបានផ្តល់អោយនូវការការពារពិសេសលើដីធ្លី ដែនដី និងធនធានរបស់ពួកគេ ដោយសារទំនាក់ទំនងរបស់គេជាមួយធនធានទាំងនោះ គឺជាផ្នែកមួយនៃជីវិត វប្បធម៌ ជំនឿ ការរៀបចំសង្គម សន្តិសុខស្បៀង សេដ្ឋកិច្ច និង សុខភាព។ សិទ្ធិរបស់ជនជាតិដើមភាគតិចលើកម្មសិទ្ធិ និង ការគ្រប់គ្រងដីធ្លី ដែនដី ធានាថា គេអាចប្រើប្រាស់ធនធានធម្មជាតិដោយសេរី និងតម្រូវឱ្យមានការព្រមព្រៀងគ្នា នៅពេលដែលមានជាប់ពាក់ព័ន្ធជាមួយអ្នកខាងក្រៅ [៧០] ។

| **ប្រអប់ទី១: សំរង់ចេញពីសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០០៧** |
|---|
| **មាត្រា ៣**<br>ជនជាតិដើមភាគតិចមានសិទ្ធិស្វ័យសំរេច។<br>**មាត្រា ២៦**<br>ជនជាតិដើមភាគតិចមានសិទ្ធិទទួលបានដីធ្លី ដែនដី និងធនធានដែលពួកគេមានឬបានកាន់កាប់ ឬបានប្រើប្រាស់ ឬទទួល បានជាប្រពៃណី។ រដ្ឋត្រូវទទួលស្គាល់ និងការពារតាមផ្លូវច្បាប់លើដីធ្លី ដែនដី និងធនធានទាំងនេះ។<br>**មាត្រា ២៨**<br>ជនជាតិដើមភាគតិចមានសិទ្ធិទទួលបានដំណោះស្រាយ... សម្រាប់ដីធ្លី ដែនដី និងធនធាន ដែលគេបានប្រើប្រាស់ជាប្រពៃណី... ដែលត្រូវបានដកហូតយក បានកាន់កាប់ បានប្រើប្រាស់ ឬបានធ្វើឱ្យអន្តរាយដោយគ្មានការយល់ព្រមដោយសេរី និង មិនបានប្រាប់អោយដឹងជាមុន។<br>**មាត្រា ៣២**<br>ជនជាតិដើមភាគតិចមានសិទ្ធិសំរេចនិងបង្កើតផែនការអាទិភាពនិងយុទ្ធសាស្ត្រនានាសម្រាប់អភិវឌ្ឍន៍ឬការប្រើប្រាស់ដីធ្លី ឬដែនដី និង ធនធានផ្សេងទៀតរបស់ពួកគេ។<br><br>រដ្ឋទាំងឡាយត្រូវពិគ្រោះយោបល់និងសហការដោយសុច្ចរិតជាមួយជនជាតិដើមភាគតិច... ដើម្បីទទួលបានការយល់ព្រមដោយសេរី និងប្រាប់ឱ្យដឹងជាមុន មុននឹងអនុម័តលើគម្រោងណាមួយ ដែលប៉ះពាល់ដីធ្លី ឬ ដែនដី និងធនធាននានារបស់ពួកគេ ជាពិសេសគម្រោងទាំងឡាយដែលទាក់ទងនឹងការអភិវឌ្ឍន៍ ការប្រើប្រាស់ ឬ ការធ្វើអាជីវកម្មរ៉ែ ទឹក ឬធនធានផ្សេងៗទៀត។ |

អនុសញ្ញា (លេខ ១៦៩) ស្តីពីជនជាតិកុលសម្ព័ន្ធ និងជនជាតិដើមភាគតិច ដែលត្រូវបានអនុម័ត នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨៩ ដោយអង្គការពលកម្មអន្តរជាតិ (ILO) កំណត់ឱ្យមានការការពារនិង ការទទួលស្គាល់តាមផ្លូវច្បាប់យ៉ាងសំខាន់ ចំពោះសិទ្ធិរបស់ជនជាតិដើមភាគតិច ។ ដូច្នេះ អនុសញ្ញានេះទ្រទ្រង់សិទ្ធិ

[70] Miranda et al, *Framework for Responsible Mining.*

ជនជាតិដើមភាគតិច ក្នុងការសំរេចលើអាទិភាពនៃការអភិវឌ្ឍន៏របស់គេ មានការកាន់កាប់ដីធ្លី និងចូលរួមប្រើប្រាស់និងគ្រប់គ្រងធនធានធម្មជាតិនៅលើដីទាំងនេះ។ អនុសញ្ញានេះទាមទារផងដែរ អោយភាគីរដ្ឋាភិបាលធានាការ ការពារសិទ្ធិលើកម្មសិទ្ធិរបស់ជនជាតិដើមភាគតិច លើធនធាន និងដីធ្លី និងមានការពិគ្រោះយោបល់ជាមួយក្រុមជនជាតិដើមភាគតិចមុនពេលអនុញ្ញាត ឬអនុវត្តគម្រោងរុករក ឬធ្វើអាជីវកម្មរ៉ែ។ ជនជាតិដើមភាគតិច មានសិទ្ធិចូលរួមទទួលផលប្រយោជន៍ ពីការធ្វើអាជីវកម្មរ៉ែ និងទទួលបានសំណងខូចខាតសមស្របពីការធ្វើសកម្មភាពនេះ ( ប្រអប់ទី ២) ។

| **ប្រអប់ទី ២: សំរង់ចេញពីអនុសញ្ញា ( លេខ ១៦៩) ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច និង កុលសម្ព័ន្ធ អនុម័តដោយអង្គការពលកម្មអន្តរជាតិ (ILO) កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨៩** |
|---|
| **មាត្រា ៧**<br>ប្រជាជនដែលពាក់ព័ន្ធត្រូវមានសិទ្ធិសំរេចអំពីអាទិភាពរបស់ខ្លួន សម្រាប់កិច្ចដំណើរការអភិវឌ្ឍន៍... និងដីធ្លី ដែលពួកគេកាន់កាប់ ឬប្រើប្រាស់ និងប្រើសិទ្ធិគ្រប់គ្រង... លើការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ផ្ទាល់ខ្លួន។<br>**មាត្រា ១៤**<br>សិទ្ធិកម្មសិទ្ធិ និង ភោគៈរបស់ប្រជាជនពាក់ព័ន្ធ លើដីដែលគេកាន់កាប់តាមប្រពៃណី ត្រូវបានទទួលស្គាល់។<br>រដ្ឋាភិបាលត្រូវ... កំណត់អត្តសញ្ញាណដីធ្លី ដែលប្រជាជនពាក់ព័ន្ធ កាន់កាប់ជាប្រពៃណី និងដើម្បីធានាសិទ្ធិកម្មសិទ្ធិ និង ភោគៈរបស់គេ។<br>**មាត្រា ១៥**<br>សិទ្ធិប្រជាជនពាក់ព័ន្ធលើធនធានធម្មជាតិ ដែលជាប់នឹងដីធ្លីរបស់គេ ត្រូវបានការការពារពិសេស។ សិទ្ធិទាំងនេះមានរួមបញ្ចូលនូវសិទ្ធិរបស់ប្រជាជន ដើម្បីចូលរួមក្នុងការប្រើប្រាស់ គ្រប់គ្រង និងអភិរក្សធនធានទាំងនេះ។<br>នៅក្នុងករណីដែលរដ្ឋបានដកហូតភាពជាកម្មសិទ្ធិលើរ៉ែ ឬធនធានផ្នែកខាងលើ ឬសិទ្ធិលើធនធានដទៃទៀត ដែលទាក់ទងនឹងដីរបស់គេ រដ្ឋត្រូវការបង្កើតនិតិវិធី ឬធានាអោយមានការពិគ្រោះយោបល់ជាមួយក្រុមមនុស្សទាំងនេះ... មុនពេលអនុញ្ញាត ឬអនុវត្តគម្រោងផ្សេងៗក្នុងការរុករក ឬធ្វើអាជីវកម្មធនធានរ៉ែ ដែលប៉ះពាល់ដីរបស់ពួកគេ។<br>អ្នកដែលទាក់ទង ទោះជាយ៉ាងណាអាចចូលរួមទទួលយកផលប្រយោជន៍ពីសកម្មភាពនេះនិងទទួលបាននូវសំណងសមរម្យចំពោះការខូចខាតពីសកម្មភាពនេះ។<br>ទោះជាយ៉ាងណា អ្នកដែលពាក់ព័ន្ធ អាចចូលរួមទទួលយកផលប្រយោជន៍ពីសកម្មភាពបែបនោះនិងទទួលបាននូវសំណង សមរម្យចំពោះការខូចខាតពីសកម្មភាពនេះ។ |

ផ្អែកតាមអនុសញ្ញាអន្តរជាតិរបស់សហប្រជាជាតិស្តីពី ការលុបបំបាត់គ្រប់ទម្រង់ទាំងអស់នៃការរើសអើងជាតិសាសន៍ ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥ រដ្ឋជាហត្ថលេខីមានកាតព្វកិច្ចទទួលស្គាល់ គោរព និងធានាសិទ្ធិរួមមាន" កម្មសិទ្ធិលើទ្រព្យសម្បត្តិជាលក្ខណៈបុគ្គល និងសិទ្ធិជាលក្ខណៈសមូហភាពជាមួយអ្នកដទៃ" និង សិទ្ធិក្នុងការទទួលមរតក ទ្រព្យសម្បត្តិ

ដោយមិនមានការរើសអើង (មាត្រា ៥)។ នៅក្នុងអនុសាសន៍រួមលេខ ២៣ ស្តីពីជនជាតិដើមភាគតិចដែលត្រូវបានធ្វើនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ ១៩៩៧ គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់ការរើសអើងជាតិសាសន៍ អំពាវនាវអោយរដ្ឋហត្ថលេខី " ទទួលស្គាល់និងការពារសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងភាពជាម្ចាស់ អភិវឌ្ឍន៍ គ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដែនដី និងធនធានសម្ភូហភាពរបស់គេ ហើយត្រូវចាត់វិធានការធ្វើយ៉ាងណាប្រគល់ដី និងទឹកដីទៅអោយពួកគេវិញ ក្នុងករណីដែលពួកគេ ត្រូវបានរឹបអូសដីធ្លី និងដែនដីដែលគ្រប់គ្រងជាលក្ខណៈប្រពៃណី ឬ បានប្រើប្រាស់ ឬរស់នៅ ដោយមិនមានការយល់ព្រមដោយសេរី និងប្រាប់អោយដឹងជាមុន"។

នៅក្រោមអនុសញ្ញាអន្តរជាតិរបស់សហប្រជាជាតិស្តីពីសិទ្ធិផ្នែកវប្បធម៌ សង្គម និងផ្នែកសេដ្ឋកិច្ច និងអនុសញ្ញាអន្តរជាតិរបស់សហប្រជាជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦:"មនុស្សទាំងអស់មានសិទ្ធិស្វ័យសំរេច" ហើយតាមរយៈសិទ្ធិរបស់គេ "អាចកំណត់ឋានៈនយោបាយរបស់គេដោយសេរី និងធ្វើការអភិវឌ្ឍន៍ផ្នែកវប្បធម៌ សង្គមនិងផ្នែកសេដ្ឋកិច្ចរបស់គេដោយសេរី។ " ដូច្នេះ "មនុស្សទាំងអស់អាច... ប្រើប្រាស់ធនធាន និងទ្រព្យសម្បត្តិធម្មជាតិរបស់គេ" ហើយ "ទោះបីក្នុងករណីណាក៏ដោយ គ្មាននរណាម្នាក់ត្រូវបានគេដកហូតមធ្យោបាយ ក្នុងការចិញ្ចឹមជីវិតរបស់គេទេ"(មាត្រា ១)។ រដ្ឋហត្ថលេខីធានាថា សិទ្ធិដែលចែងនៅក្នុងអនុសញ្ញាទាំងនេះនឹងត្រូវអនុវត្តដោយមិនមានការរើសអើងបែបណាមួយឡើយទាំងចំពោះ"សញ្ជាតឬដើមកំណើតសង្គម"(មាត្រា ២)។ រដ្ឋហត្ថលេខីនៃអនុសញ្ញាស្តីពីសិទ្ធិវប្បធម៌ សង្គម និងសេដ្ឋកិច្ច ក៏ទទួលស្គាល់ផងដែរចំពោះ "មនុស្សគ្រប់រូបមានសិទ្ធិមានជីវភាពរស់នៅគ្រប់គ្រាន់សម្រាប់ខ្លួនគេ និងគ្រួសាររបស់គេ រួមទាំងការមានអាហារបរិភោគ សំលៀកបំពាក់គ្រប់គ្រាន់ និងមានផ្ទះសម្បែងសមស្រប និងសិទ្ធិក្នុងការបន្តឱ្យមានជីវភាពកាន់តែប្រសើរឡើង" (មាត្រា ១១)។

## សិទ្ធិជនជាតិដើមភាគតិច និងការធ្វើអាជីវកម្មរ៉ែដោយមានទំនួលខុសត្រូវ

ការធ្វើអាជីវកម្មរ៉ែនាំឱ្យមានការផ្លាស់ប្តូរផ្នែកសង្គម និងបរិស្ថាន នៅគ្រប់កន្លែងដែលមានសកម្មភាពនេះ។ ក្នុងគ្រប់ដំណើរការសកម្មភាពរ៉ែ ការរំខានណាមួយ ដល់ការរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងសហគមន៍ជៀសមិនផុតឡើយ។ ថ្វីបើមានរឿងនេះក៏ដោយ ផលប៉ះពាល់អវិជ្ជមានជាច្រើនផ្នែកបរិស្ថាន និងសង្គមអាចជៀសវាងបាន ប្រសិនបើតម្រូវឱ្យក្រុមហ៊ុនមានគណនេយ្យភាពចំពោះបទដ្ឋាននៃការអនុវត្តល្អ។ អ្នកពាក់ព័ន្ធកាន់តែចាប់ផ្តើមទទួលស្គាល់ថា ការគោរពរបស់ក្រុមហ៊ុនចំពោះច្បាប់នៅក្នុងប្រទេសដែលខ្លួនធ្វើសកម្មភាពនោះប្រហែលមិនគ្រប់គ្រាន់ទេ ដើម្បីការពារបរិស្ថាន ឬសហគមន៍ដែលងាយរងគ្រោះ។ អ្នកពាក់ព័ន្ធជាច្រើនលើកឡើងបញ្ហាទាំងនេះ ហើយមានក្រុមហ៊ុនរ៉ែខ្លះទទួលយក ក្នុងការតម្រូវអោយមានការគោរពតាម

ក្រមុ្យ ពិធីសារ អនុសញ្ញា សេចក្តីប្រកាស ឯកសារគោល និងទំលាប់ប្រពៃណីដែលការពារសិទ្ធិមនុស្ស ជាមូលដ្ឋាន សិទ្ធិស្វ័យសំរេច ភាពថ្លៃថ្នូរនៃវប្បធម៌ សិទ្ធិសង្គមនិងពលកម្ម ហើយនិងបរិស្ថានធម្មជាតិ។ ឆ្លើយតបនឹងតម្រូវការនេះ អង្គការមិនមែនរដ្ឋាភិបាល អ្នកលក់ដូរ វិនិយោគិន ក្រុមហ៊ុនធានារ៉ាប់រង និង អ្នកបច្ចេកទេសក្នុងវិស័យរ៉ែ កំពុងតែរៀបចំក្របខណ្ឌសម្រាប់ការធ្វើអាជីវកម្មរ៉ែប្រកបដោយទំនួលខុសត្រូវ ដើម្បីបង្កើតបទដ្ឋានសម្រាប់គោលនយោបាយធ្វើអាជីវកម្ម និងវិនិយោគប្រកបដោយទំនួលខុសត្រូវ[៧១] ។

ជនជាតិដើមភាគតិច បានទទួលរងគ្រោះកាន់តែកើនឡើងពីសកម្មភាពរ៉ែ នៅពេលក្រុមហ៊ុនបានពង្រីក ចូលទៅតំបន់ឆ្ងាយដាច់ស្រយ៉ាលជុំវិញពិភពលោក។ ដីរបស់ជនជាតិដើមភាគតិច ច្រើនសំបូរធនធានធម្មជាតិ មានតម្លៃដូចជារ៉ែ ដូច្នេះហើយ ក្រុមជនជាតិដើមភាគតិចច្រើនរងនូវការប៉ះពាល់ច្រើនជាងគេ ដោយសារ សកម្មភាពរ៉ែ។ អង្គការ Earthwork និង អុកហ្វាមអាមេរិកប៉ាន់ប្រមាណថា ពាក់កណ្តាលនៃមាសដែលបានជីក ចន្លោះ ឆ្នាំ១៩៩៥ និង ឆ្នាំ២០១៥ ច្រើនបានមកពីដីរបស់កុលសម្ព័ន្ធ[៧២] ។ បើគ្មានការគោរពចំពោះសិទ្ធិរបស់គេ ជនជាតិដើមភាគតិច ដែលជាញឹកញាប់ស្ថិតនៅក្រោមការប្រឈម នឹងគ្រោះថ្នាក់ខ្លាំង។

បញ្ហាសង្គម ដែលក្រុមជនជាតិប្រឈមចំពោះសកម្មភាពជីករ៉ែ មានដូចជា:

- កំណើននៃភាពក្រីក្រដែលបណ្តាលមកពីការខូចបរិស្ថានក្នុងតំបន់ដាំដុះ និងតំបន់ព្រៃដែលទ្រទ្រង់ ដល់ការចិញ្ចឹមជីវិតប្រចាំថ្ងៃ ឬភាពក្រីក្របណ្តាលមកពីកំណើននៃចំណាយសម្រាប់ជីវភាព ប្រចាំថ្ងៃ ដោយសារមានកម្មកររ៉ែដែលមានប្រាក់កំរៃខ្ពស់។
- វិសមភាពសេដ្ឋកិច្ចកាន់តែច្រើនឡើង រវាងអ្នកមានការងារធ្វើតាមការដ្ឋានជីករ៉ែ និងអ្នកដែល គ្មានការងារធ្វើ រវាងបុរស និងស្ត្រីដែលមានការងារធ្វើ និងរវាងអ្នកដែលអាចទទួលផល ដោយប្រយោលពីរ៉ែ និងអ្នកដែលមិនបានទទួលផលនេះ។
- ទំនាក់ទំនងនៃអំណាចដែលមិនមានស្មេរភាព និងជំលោះដែលកើតចេញមកពីការបែកបាក់នៃ សាមគ្គីភាព និងរចនាសម្ព័ន្ធសង្គមជាប្រពៃណី។
- ផ្នែកសេដ្ឋកិច្ចមិនមានឯករាជ្យ និងភាពងាយរងគ្រោះខ្ពស់ ដោយសហគមន៍រៀបចំសកម្មភាព ផ្លាស់ប្តូរសេដ្ឋកិច្ចឡើងវិញ ដើម្បីបំពេញតាមសេចក្តីត្រូវការនៃអាជីវកម្មរ៉ែ។
- ការប្រើប្រាស់កំលាំងយោធា ដោយសារតម្រូវការក្នុងការការពាររ៉ែពីពួកចោរ ឬអ្នកមូលដ្ឋាន ដែលធ្វើការប្រឆាំង។

---

[71] This section draws substantially on Miranda et al, *Framework for Responsible Mining.*
[72] Earthwork and Oxfam America, *Dirty Metals: Mining, Communities, and Environment,* 2004 cited in Miranda et al, Framework for Responsible Mining.

- ការត្រូវរើទីកន្លែង ដោយសារមានការបង្ខំអោយចេញ ឬ ប្តូរលំនៅដ្ឋាន។
- ជម្លោះបណ្តាលមកពីអ្នកខាងក្រៅ ដែលមានចិត្តគំនិតខុសគ្នា ចូលទៅនៅទីនោះ។
- ការប្រឈមនឹងជំងឺ ដូចជាចម្លងស្គាល់សាយ និង ជំងឺអេដស៍ ដែលអ្នកក្រៅនាំចូលទៅ។
- កំណើននៃការប្រើគ្រឿងស្រវឹង ពេស្យាចារ និងការលេងល្បែងស៊ីសង ដោយសារប្រុសៗនៅក្នុងមូលដ្ឋានរកលុយបាន ហើយប្រុសៗជីករ៉ែដែលធ្វើចំណាកស្រុកចូលទៅមិនព្រមទទួលយកបំរាមជាទំលាប់ របស់អ្នកមូលដ្ឋាន។
- ការរំលោភសិទ្ធិមនុស្សបណ្តាលមកពីការមានទាហានចូលច្រើន ការបង្ខិតបង្ខំ ឬហឹង្សាផ្លូវភេទ។
- ការបាត់បង់មុខរបរចិញ្ចឹមជីវិតពីការជីករ៉ែតូចតាច ដោយសារក្រុមហ៊ុនធ្វើអាជីវកម្មរ៉ែផ្តាច់មុខលើទឹកដីរបស់ជនជាតិដើមភាគតិច។
- ការបាត់បង់ឯកភាពវប្បធម៌ ក្នុងពេលដែលមានការបំផ្លាញទីសក្ការៈ។
- ការបាត់បង់ការគ្រប់គ្រងលើការសំរេចចិត្តរបស់សហគមន៍ និងជំរើសសម្រាប់ការអភិវឌ្ឍន៍ នៅពេលអនាគត។
- ការបំពានលើបទដ្ឋានសុខាភិបាល សុវត្ថិភាព និងការងារ សម្រាប់អ្នកធ្វើការក្នុងផ្នែករ៉ែ។

ក្របខណ្ឌសម្រាប់ការធ្វើអាជីវកម្មរ៉ែប្រកបដោយទំនួលខុសត្រូវ មានមូលដ្ឋានផ្អែកលើច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ហើយកំណត់កាតព្វកិច្ចរបស់រដ្ឋចំពោះជនជាតិដើមភាគតិច និងការទាញយកធនធានលើដីរបស់គេ។ យ៉ាងហោចណាស់ អាជីវកម្មរ៉ែមិនគួរធ្វើឱ្យស្ថានភាពជនជាតិដើមភាគិតចយ៉ាប់យ៉ឺនជាង មុនពេលចាប់ផ្តើមធ្វើអាជីវកម្មទេ។ គ្រោះថ្នាក់ដែលអាចមានផ្នែកសង្គម និងបរិស្ថាន ដូចចំណុចដែលមានរៀបរាប់ខាងលើនេះ ត្រូវកំណត់ឱ្យបានច្បាស់ នៅពេលចាប់ផ្តើមគម្រោងត្រូវទទួលស្គាល់ និងពិភាក្សាជាមួយក្រុមជនជាតិដើមភាគតិច។ ត្រូវរិះរកមធ្យោបាយដើម្បីកាត់បន្ថយគ្រោះថ្នាក់ទាំងនេះអោយនៅតិចបំផុត ហើយត្រូវមានការធានាជាសំណងលុយកាក់។ គួរមានកិច្ចព្រមព្រៀងតាមច្បាប់ត្រឹមត្រូវផងដែរ ដើម្បីអោយសហគមន៍កុលសម្ព័ន្ធទទួលបានផលប្រយោជន៍ពីរ៉ែផង។

## សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការយល់ព្រមដោយសេរី និងប្រាប់អោយដឹងជាមុន

សិទ្ធិដែលមានចែងក្នុងច្បាប់អន្តរជាតិសម្រាប់ការធ្វើអាជីវកម្មប្រកបដោយការទទួលខុសត្រូវ ជាមួយក្រុម ជនជាតិ តាមគោលការណ៍យល់ព្រមដោយសេរី និងប្រាប់អោយដឹងជាមុន ត្រូវតែសុំការយល់ព្រមលើគម្រោងទាំងឡាយណា ដែលមានការប៉ះពាល់ដល់ដីនិងធនធានរបស់គេ។ ការយល់ព្រមដោយសេរី មានន័យថាការយល់ព្រមនោះត្រូវបានផ្តល់ដោយមិនមានការបង្ខិតបង្ខំ ឬការប្រើល្បិចកល្បនោះឡើយ។ រីឯការយល់ព្រមជាមុន គឺសំដៅលើការយល់ព្រមដែលកើតឡើងមុនពេលការអនុញ្ញាតរបស់រដ្ឋ ឬ មុនពេលចាប់ផ្តើម នៃសកម្មភាពរបស់ក្រុមហ៊ុន។ ចំណែកឯការយល់ព្រមដោយប្រាប់ឱ្យដឹងច្បាស់សំដៅលើការបង្ហាញឱ្យឃើញនូវរាល់ព័ត៌មានទាក់ទងក្នុងលក្ខណៈធ្វើឱ្យគេមានការងាយយល់ ឬជ្រួតជ្រាបដល់សហគមន៍ជនជាតិដើមភាគតិច។ ដូច្នេះ ការយល់ព្រមដោយសេរីនិងប្រាប់ដឹងច្បាស់ត្រូវតែធ្វើឡើងនូវគ្រប់ដំណាក់កាលនៃសកម្មភាពរ៉ែ ហើយអាចនឹង ត្រូវបានបដិសេធចំពោះការយល់ព្រមនេះ មុនពេលឈានចូលទៅដំណាក់កាលបន្ទាប់[៧៣]។

រដ្ឋាភិបាលជាច្រើនតែងអះអាងថា ផលប្រយោជន៍ជាតិមានអាទិភាពលើសិទ្ធិជនជាតិដើមភាគតិចក្នុងការផ្តល់ការយល់ព្រមដោយសេរីនិងប្រាប់អោយដឹងជាមុន។ តែអ្នកឯកទេសស្តីពី សិទ្ធិជនជាតិដើមភាគតិចបានតបវិញថា គោលការណ៍នេះគឺជាសិទ្ធិមនុស្ស ដូច្នេះមិនអាចផាត់ចោលដោយសំអាងលើអធិបតេយ្យភាពរបស់រដ្ឋបានទេ[៧៤]។ ដូចគ្នានេះដែរ រដ្ឋាភិបាលច្រើនលើកឡើងថា ធនធានរ៉ែនៅស្រទាប់ដីខាងក្រោម តាមច្បាប់ត្រូវតែជារបស់រដ្ឋ។ គោលការណ៍ណែនាំស្តីពីបញ្ហាជនជាតិដើមភាគតិច របស់ក្រុមអភិវឌ្ឍន៍ របស់សហប្រជាជាតិបានអះអាងផ្សេងពីនេះ ដោយនិយាយថា "ក្នុងករណីធនធានរបស់រដ្ឋនៅក្នុងដីស្រទាប់ក្រោមស្ថិតនៅក្នុងដីរបស់ជនជាតិដើមភាគតិច ជនជាតិដើមភាគតិចនៅតែមានសិទ្ធិផ្តល់ការយល់ព្រមដោយសេរីនិងប្រាប់ឱ្យដឹង ជាមុនសម្រាប់ការរុករកនិងធ្វើអាជីវកម្មធនធានទាំងនោះ ហើយមានសិទ្ធិទទួលចំណែកពីធនធាននោះដែរ[៧៥]។"

ករណីគួរអោយកត់សំគាល់មួយគឺប្រទេសហ្វីលីពីន ជាឧទាហរណ៍មួយនៃប្រទេសក្នុងសមាគមអាស៊ានដែលបានអនុម័តច្បាប់ទទួលស្គាល់និងការពារសិទ្ធិនៃជនជាតិដើមភាគតិចរបស់ខ្លួន។ ច្បាប់ស្តីពីរ៉ែរបស់ប្រទេសហ្វីលីពីនដែលបានអនុម័តនៅឆ្នាំ ១៩៩៥ និងច្បាប់ស្តីពីសិទ្ធិជនជាតិដើមភាគតិចរបស់ប្រទេសនេះ ដែលត្រូវបានអនុម័តនៅ ឆ្នាំ១៩៩៧ គាំទ្រសិទ្ធិក្នុងការផ្តល់ការយល់ព្រមដោយសេរី និងប្រាប់អោយដឹងជាមុន ដល់ជនជាតិដើមភាគតិច។ ច្បាប់ឆ្នាំ ១៩៩៥ ស្តីពីរ៉ែរបស់ប្រទេសហ្វីលីពីនអះអាងថា "គ្មានទឹកដីដូនតាណាមួយ ត្រូវបើកឱ្យ

---

[73] Miranda et al, *Framework for Responsible Mining:* see also United Nations Development Group Guidelines on Indigenous People's Issues.
[74] Miranda et al, *Framework for Responsible Mining.*
[75] United Nations Development Group Guidelines on Indigenous People's Issues.

មាន សកម្មភាពរ៉ែបានដោយមិនមានការយល់ព្រមជាមុនពីសហគមន៍ជនជាតិដើមភាគតិច ដែលមានការពាក់ព័ន្ធនោះទេ។" ច្បាប់ឆ្នាំ ១៩៩៧ ស្តីពីសិទ្ធិជនជាតិដើមភាគតិចប្រទេសហ្វីលីពីន តម្រូវឱ្យគណៈកម្មការជាតិទទួលបន្ទុកការិយាល័យទឹកដីដូនតារបស់ជនជាតិដើមឱ្យមានសិទ្ធិចេញ " លិខិតបញ្ជាក់មុនពេលផ្តល់អាជ្ញាប័ណ្ណការជួលឬ អនុញ្ញាតសម្រាប់ធ្វើអាជីវកម្មលើធនធានធម្មជាតិ ដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ជនជាតិដើមភាគតិច ឬ ដីដូនតារបស់ពួកគេ និងដើម្បីជួយសហគមន៍ជនជាតិដើមភាគតិច ក្នុងការការពារបុរណភាពដែនដីដូនតាទាំងអស់ នៅពេលដែលបានទទួលការយល់ព្រមដោយសេរីនិងប្រាប់អោយដឹងជាមុនដល់សហគមន៍ជនជាតិដើមភាគតិច។

ជាការពិត ការចាប់អារម្មណ៍សំខាន់របស់ក្រុមហ៊ុនរ៉ែគឺសុំឱ្យបានអាជ្ញាប័ណ្ណរ៉ែពីអាជ្ញាធររដ្ឋាភិបាល និងការបំពេញតាមលក្ខខណ្ឌផ្លូវការនិងក្រៅផ្លូវការ ដើម្បីទទួលបានអាជ្ញាប័ណ្ណ។ យ៉ាងណាក្តី ក្រុមហ៊ុនរ៉ែកាន់តែដឹងថា គេត្រូវមានអាជ្ញាប័ណ្ណសង្គមសម្រាប់ធ្វើសកម្មភាពដែរ។ តាមធម្មតា ក្រុមហ៊ុនរ៉ែធំៗទាក់ទងជាមួយសហគមន៍ជនជាតិដើមភាគតិច ក្នុងដំណើរការពិគ្រោះយោបល់បែបណាមួយ ហើយមានក្រុមហ៊ុនមួយចំនួនបានបង្កើត គម្រោងសង្គម ឬមូលនិធិសង្គមសម្រាប់ផ្តល់ជំនួយដើម្បីការអភិវឌ្ឍន៍។ តាមធម្មតា គេប្រជុំពិគ្រោះយោបល់ ដើម្បីជំរាបសហគមន៍ពីសកម្មភាពអាជីវកម្មរ៉ែទូទៅ និងដើម្បីធានាចំពោះពួកគេ នូវសំណងដល់ការខូចខាត ចំពោះមុខ និងការទទួលបានអត្ថប្រយោជន៍ច្រើននៅពេលអនាគត។ ក្រុមហ៊ុនរ៉ែពុំសូវធ្វើការពិគ្រោះយោបល់ជាមួយជនជាតិដើមភាគិចដោយទទួលស្គាល់ជាចំហ និងគោរពសិទ្ធិរបស់ពួកគេ ក្នុងការមិនផ្តល់ការយល់ព្រមចំពោះ គម្រោងនោះ ។ ដរាបណាការប្រឆាំង របស់សហគមន៍ធ្វើអោយអាក់ខានដល់សកម្មភាពរបស់គេនោះ ក្រុមហ៊ុនតែងតែងាកមករករដ្ឋាភិបាល អោយផ្តល់ការអនុញ្ញាតអោយនូវអាជ្ញាប័ណ្ណ ដើម្បីធានាបាននូវការយល់ព្រមរបស់សហគមន៍[៧៦]។

## ករណីទាក់ទងនឹងជំនួញ ដោយមានការយល់ព្រមរបស់សហគមន៍

ការសិក្សារបស់វិទ្យាស្ថានធនធានពិភពលោក (WRI) ដែលអំពីការអភិវឌ្ឍន៍ដោយ មិនមានជំលោះករណីទាក់ទងនឹងជំនួញ ចំពោះការយល់ព្រមរបស់សហគមន៍ លើកហេតុផលថា ឧបសគ្គបណ្តាលមកពីការខកខានមិនបានសុំការយល់ព្រមដោយសេរី និងប្រាប់អោយដឹងជាមុន ពីសហគមន៍ គឺសំខាន់ និងមានទំហំអាចវាស់វែងបានដូចគ្នាទៅនឹងផលប្រយោជន៍ ដែលបានមកពីការពិគ្រោះយោបល់យ៉ាងហ្មត់ចត់ ជាមួយសហគមន៍ដូច្នោះដែរ[៧៧]។ របាយការណ៍បានរៀបរាប់ឧបសគ្គ ដែលអាចមានទាក់ទងនឹងការប្រឆាំងរបស់

[76] Miranda et al, *Framework for Responsible Mining.*

[77] This section draws substantially on Herz, Steven, Antonio La Vina, and Jonathan Sohn, *Development without Conflict: The Business Case for Community Consent*, World Resource Institute, May 2007. See also

សហគមន៍ដូចជា ១- កំណើននៃការចំណាយដោយសារការពន្យាពេលក្នុងការសាងសង់ និងប្រតិបត្តិការ ២- តម្រូវការទៅលើលទ្ធផលរបស់គម្រោងថយចុះ ៣- លទ្ធភាពថយចុះក្នុងការទទួលបានធនធានចាំបាច់សម្រាប់គម្រោង ៤- កំណើននៃការចំណាយក្នុងការបន្ថយផលប៉ះពាល់ផ្នែកសង្គមនិងបរិស្ថាន ៥- អន្តរាគមន៍ របស់រដ្ឋាភិបាលក្នុងការផាកពិន័យ ដកអាជ្ញាប័ណ្ណ និងបញ្ឈប់សកម្មភាព និង ៦- ការគំរាមកំហែងចំពោះជោគជ័យក្នុងមុខជំនួញឬស្ថេរភាពហិរញ្ញវត្ថុ ។

ដោយយោងលើករណីសិក្សាចំនួន ៤ នៅប្រទេសហ្វីលីពីន ថៃ អាហ្សង់ទីន និងប៉េរូ ការស្រាវជ្រាវបានផ្តល់អនុសាសន៍ជាគោលការណ៍ចំនួន ៦ សម្រាប់អោយក្រុមហ៊ុនកំណត់យកជានិតិវិធីចាំបាច់ ដើម្បីកាត់បន្ថយឧបសគ្គក្នុងមុខជំនួញដែលបណ្តាលមកពីកង្វះការចូលរួមរបស់សហគមន៍មូលដ្ឋាន ។ ផ្នែកទាំង ៦ នេះមាន:

- *ព័ត៌មាន:* សហគមន៍ដែលរងការប៉ះពាល់គួរទទួលបាននូវព័ត៌មានគ្រប់គ្រាន់ ជាភាសាផ្ទាល់របស់គេ ស្តីពីគម្រោង ហើយគួរតែត្រូវបានគេផ្តល់ពេលវេលាអោយគ្រប់គ្រាន់សម្រាប់ពិនិត្យមើល និងពិភាក្សាពីព័ត៌មាន ដែលគេបានទទួល ។

- *ការទទួលអោយចូលរួម:* អ្នកពាក់ព័ន្ធទាំងអស់ក្នុងសហគមន៍គួរត្រូវបានគេអនុញ្ញាតនិងលើក ទឹកចិត្ត អោយចូលរួមក្នុងដំណើរការផ្តល់ការយល់ព្រម ដោយសេរី និងប្រាប់អោយដឹងជាមុនរួមទាំងអ្នកដែលរងការប៉ះពាល់ដោយប្រយោលផងដែរ ។

- *ការពិភាក្សា:* ការពិភាក្សាក្នុងដំណើរការ ការផ្តល់ការយល់ព្រមដោយសេរី និង ប្រាប់អោយដឹងជាមុន គួរមានលក្ខណៈផ្លូវការ បន្តក្នុងអំឡុងពេលទាំងមូលនៃគម្រោង ហើយមាន ការចូលរួមរបស់តំណាងមកពីអាជ្ញាធរ និងសហគមន៍មូលដ្ឋាន ។

- *ការទទួលស្គាល់តាមផ្លូវច្បាប់:* ការផ្តល់ការយល់ព្រមដោយសេរី និង ប្រាប់អោយដឹងជាមុន គួរតែត្រូវបានទទួលស្គាល់ជាផ្លូវការនៅក្នុងកិច្ចព្រម ព្រៀងដែលមានសុពលភាព តាមផ្លូវច្បាប់ ។

- *ការតាមដាន និងវាយតម្លៃ:* និតិវិធីសម្រាប់ការតាមដានរបស់សហគមន៍បានសមស្រប និងដោយឯករាជ្យគួរតែត្រូវបានបង្កើតឡើង ដើម្បីធ្វើយ៉ាងណាដោះស្រាយកង្វល់ របស់សហគមន៍ក្នុងអំឡុងពេលទាំងមូលនៃគម្រោង ។

- *ការទិញចូលរបស់ក្រុមហ៊ុន* : អ្នកគាំទ្រគម្រោងគួរចាត់ទុកសិទ្ធិក្នុងការផ្តល់ការយល់ព្រមដោយសេរី និងប្រាប់អោយដឹងជាមុន ថាជាការចំណាយចាំបាច់ដែលត្រូវតែមានក្នុងគម្រោង ។

---

Power, Thomas, *Metals Mining and Sustainable Development in Central America: An Assessment of Benefits and Costs,* Oxfam America, 2008.

អ្នកសិក្សាស្រាវជ្រាវ បានសង្កេតឃើញថា ដំណើរការនៃការសុំការយល់ព្រមដោយសេរី និងប្រាប់ឱ្យដឹងជាមុន ដល់សហគមន៍មានដំណើរការបានល្អប្រសើរល្អ នៅក្នុងប្រទេសដែលរដ្ឋាភិបាលគាំទ្រគោលការណ៍នេះ ទុកដូចជា ច្បាប់ ឬគោលនយោបាយដែរ។ គេលើកទឹកចិត្តអោយអ្នកគាំទ្រគម្រោងធ្វើការជាមួយរដ្ឋាភិបាល ដើម្បីទទួលបាននូវការគាំទ្រនិង ការចូលរួមរបស់រដ្ឋាភិបាល ក្នុងដំណើរការសុំការយល់ព្រម និងការចូលរួមរបស់សហគមន៍។

## ក្របខណ្ឌច្បាប់ស្តីពី សិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជា

ប្រទេសកម្ពុជា រួមជាមួយនឹងរដ្ឋសមាជិកចំនួន ១៤២ ទៀត បានបោះឆ្នោតអនុម័ត*សេចក្តីប្រកាសរបស់ សហប្រជាជាតិ ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច* នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧។ ការបោះឆ្នោតគាំទ្រសេចក្តីប្រកាស របស់កម្ពុជានេះគឺជាជំហានទៅមុខមួយយ៉ាងសំខាន់ ក្នុងការទទួលស្គាល់និងឆន្ទៈរបស់កម្ពុជា ក្នុងការការពារសិទ្ធិរបស់ជនជាតិដើមភាគតិច។ គោលនយោបាយរដ្ឋដែលស្របតាមសេចក្តីប្រកាសនេះត្រូវធ្វើឱ្យប្រាកដថា ការធ្វើអាជីវកម្មនិងការរុករករ៉ែមិនត្រូវរំលោភសិទ្ធិជនជាតិដើមភាគតិច។

កម្ពុជាគឺជាប្រទេសហត្ថលេខីនៃ*អនុសញ្ញារបស់សហប្រជាជាតិ ស្តីពីការ លុបបំបាត់គ្រប់ទំរង់ទាំងអស់នៃការប្រកាន់ពូជសាសន៍* (ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ១៩៨៣) *អនុសញ្ញាអន្តរជាតិរបស់សហប្រជាជាតិស្តីពីសិទ្ធិវប្បធម៌ សង្គមនិងសេដ្ឋកិច្ច* (ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២) និង *អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយនិងសិទ្ធិពលរដ្ឋ* (ថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២)។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានស្រង់យកអនុសញ្ញាទាំងនេះជាក្របខណ្ឌគតិយុត្តិសម្រាប់ប្រទេសខ្លួន។ យោងតាមមាត្រា៣១ ប្រទេសកម្ពុជាគួរទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាទាក់ទងសិទ្ធិមនុស្ស ព្រមទាំងសិទ្ធិស្ត្រីនិងកុមារ។ ប៉ុន្តែកម្ពុជាមិនបានធ្វើសច្ចានុម័តលើ *អនុសញ្ញា (លេខ ១៦៩) ស្តីពីជនជាតិដើមភាគតិចនិងកុលសម្ព័ន្ធ* របស់អង្គការពលកម្មអន្តរជាតិនៅឡើយទេ។

រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តនៅឆ្នាំ ១៩៩៣ មិនមានខ្លឹមសារពិសេសណាមួយស្តីពីជនជាតិដើមភាគតិចទេ តែរដ្ឋធម្មនុញ្ញបានបញ្ជាក់ថា ពលរដ្ឋខ្មែរត្រូវមានភាពស្មើគ្នាចំពោះមុខច្បាប់ ហើយមានសិទ្ធិ សេរីភាព និងកាតព្វកិច្ចដូចគ្នា ដោយមិនគិតពីជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធាន និងស្ថានភាពផ្សេងទៀតឡើយ (មាត្រា ៣១)។ ទោះបីជា ទស្សនៈស្តីពី "ពលរដ្ឋខ្មែរ" ផ្តល់សញ្ជាតិដល់ " ខ្មែរលើ" ក្តី តែមិនមានការគិតដល់ភាសាដោយឡែករបស់ជនជាតិដើមភាគតិច ដែលមានវប្បធម៌និងភាសាខុសពីពលរដ្ឋខ្មែរភាគច្រើននោះទេ។ ដូច្នេះ

ពាក្យពេជន៍នៅក្នុងរដ្ឋធម្មនុញ្ញ បង្ហាញថា កម្ពុជាគឺជារដ្ឋកសាងជាតិ ដោយផ្សាយចេញនូវវប្បធម៌សង្គមរួមមួយនៅក្នុងប្រទេសទាំងមូល [៧៨]។

នៅប្រទេសកម្ពុជា គណៈកម្មាធិការអន្តរក្រសួង សម្រាប់ការអភិវឌ្ឍន៍ជនជាតិតំបន់ភ្នំ ដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលនៅឆ្នាំ ១៩៩៤ បានធ្វើសេចក្តីព្រាង *គោលនយោបាយរួមសម្រាប់ការអភិវឌ្ឍន៍ជនជាតិតំបន់ភ្នំ* ដោយមានការជួយពីអង្គការអន្តរជាតិ ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ។ ឯកសារគោនយោបាយនេះ ដែលផ្អែកលើ អនុសញ្ញាលេខ ១៦៩ របស់អង្គការពលកម្មអន្តរជាតិ ត្រូវបានដាក់ជូនទៅគណៈរដ្ឋមន្ត្រី នៅឆ្នាំ ១៩៩៧ ហើយត្រូវបានពិភាក្សាចំនួន ២ ដង។ គោលនយោបាយនេះមិនត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីដោយសារទាក់ទងទៅនឹងសិទ្ធិដីធ្លីនិងព្រៃរបស់ជនជាតិដើមភាគតិច ហើយបញ្ហាទាំងនេះមិនត្រូវដាក់បញ្ចូលក្នុងច្បាប់ភូមិបាលឆ្នាំ១៩៩២។ ក្រោយមកគណៈកម្មាធិការអន្តរក្រសួង ត្រូវបានរំសាយនិងជំនួសដោយនាយកដ្ឋានជនជាតិដើមភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ បានបន្តធ្វើសេចក្តីព្រាងគោលនយោបាយឡើងវិញ ប៉ុន្តែនៅខែមេសា ឆ្នាំ២០០៧ គណៈរដ្ឋមន្ត្រីនៅតែមិនបានអនុម័តនៅឡើយ [៧៩]។ នៅខែមេសា ឆ្នាំ២០០៩ គណៈរដ្ឋមន្ត្រីបានអនុម័តលើ គោលនយោបាយស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច។ គោលនយោបាយនេះលើកកំពស់ខ្លឹមសារផ្សេងៗ ដែលមាននៅក្នុងច្បាប់រ៉ែនិង ច្បាប់ភូមិបាលដែលទាក់ទងនឹងរ៉ែ និងការផ្លាស់ប្តូរទីតាំងរស់នៅរបស់ជនជាតិដើមភាគតិច ហើយបានជំរុញឱ្យសម្បទានិករ៉ែ កសាងសាលារៀន និងមន្ទីរពេទ្យនៅតំបន់ជនជាតិដើមភាគតិច ព្រមទាំងផ្តល់ការងារ និងការបណ្តុះបណ្តាលដល់ជនជាតិដើមភាគតិច ពីឧស្សាហកម្មរ៉ែគ្រប់ក៏រិត (មាត្រា១០, ៤-៦)។

## ការធ្វើសកម្មភាពរ៉ែនៅលើដីរបស់ជនជាតិដើមភាគតិច

ច្បាប់ភូមិបាល ដែលប្រកាសអោយប្រើកាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ទទួលស្គាល់សិទ្ធិគ្រប់គ្រងដីធ្លីរបស់ក្រុមជនជាតិដើមភាគតិច។ ច្បាប់នេះអនុញ្ញាតអោយសហគមន៍ជនជាតិដើមភាគតិច មានកម្មសិទ្ធិសមូហភាព លើដីជាប្រពៃណីរបស់គេ ដែលកំណត់ថា ជាដីលំនៅដ្ឋាន ដីកសិកម្ម និងដីបំរុងទុកសម្រាប់ចំការវិលជុំ (មាត្រា២៥)។ ជាងនេះទៀត ច្បាប់ភូមិបាលការពារសិទ្ធិប្រើប្រាស់និងគ្រប់គ្រងដីជាប្រពៃណីរបស់ជនជាតិដើមភាគតិច សូម្បីមុនសិទ្ធិកម្មសិទ្ធិរបស់គេ ត្រូវបានទទួលស្គាល់ តាមរយៈការផ្តល់កម្មសិទ្ធិសមូហភាពក៏ដោយ (មាត្រា ២៣)។ ដូច្នេះហើយការលក់ដីជនជាតិដើមភាគតិច ក្រៅរង្វង់សហគមន៍ ដោយគិតចាប់តាំងពីចេញច្បាប់ភូមិបាលមកត្រូវចាត់ទុកថា ជាអំពើខុសច្បាប់។ អង្គការមិនមែនរដ្ឋាភិបាលបានលើកឡើងថា អាជ្ញាប័ណ្ណរុករករ៉ែលើដីរបស់ជនជាតិដើមភាគតិច គឺជាអំពើខុសច្បាប់ ប្រសិនបើរារាំងដល់លទ្ធភាពរបស់

---

[78] Ehrentraut, Stefan, "The Theory of Multiculturalism and Cultural Diversity in Cambodia," Postdam University, 2004.
[79] Andersen, Kirsten Ewers, *Indigenous Communities' Rights to Land and Natural Resources in Cambodia*, World Bank, July 2007.

សហគមន៍បន្តគ្រប់គ្រងដីធ្លីតាមលក្ខណៈប្រពៃណីដូចដែលបានការពារដោយមាត្រា ២៣ នៃច្បាប់ភូមិបាល [៨០]។ ការលក់ដីរបស់បុគ្គល និងដីរួម ត្រូវបានហាមឃាត់ បន្ទាប់ពីមានការចេញកម្មសិទ្ធិសមូហភាព តែបុគ្គលមានសិទ្ធិសេរីភាព កាន់កាប់និងប្រើប្រាស់ដីសមូហភាពបាន យោងតាមទម្លាប់ពីមុនមក ហើយធ្វើយ៉ាងណាឱ្យស្របជាមួយនឹង ការបែងចែកជាប្រពៃណី នូវសិទ្ធិប្រើប្រាស់លើដីរួម សម្រាប់បុគ្គលនិងគ្រួសារនីមួយៗ។

បញ្ហាទាក់ទងនឹងនិតិវិធីក្នុងដំណើរការផ្តល់កម្មសិទ្ធិរួមដែលទាក់ទងនិងច្បាប់ភូមិបាល និង ត្រូវបំភ្លឺក្នុងអនុក្រិត្យមួយ។ ទោះបីជាមានការចាប់ផ្តើមយ៉ាងល្អក្តី តែដំណើរការនៃការធ្វើសេចក្តីព្រាង និងអនុម័តអនុក្រិត្យស្តីពី *និតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច* ត្រូវបានផ្អាក។ នៅខែឧសភាឆ្នាំ២០០៥ ការពិនិត្យឡើងវិញដោយឯករាជ្យស្តីពីច្បាប់បានប្រកាសថា ក្របខណ្ឌនៃការចុះបញ្ជីប័ណ្ណកម្មសិទ្ធិរួមរបស់ជនជាតិដើមភាគតិច ជាទូទៅត្រូវរៀបចំរួច។ ការពិនិត្យឡើងវិញនោះបានផ្តល់ជាអនុសាសន៍ថាអនុក្រិត្យ គួរតែត្រូវបានព្រាង និងអនុម័ត ទោះក្នុងលក្ខណៈសាមញ្ញក្តី ដើម្បីដាក់ចេញនូវដំណើរការសម្រាប់ទទួលស្គាល់ សហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល [៨១]។ នៅដំណាក់កាលដែលមានការបាត់បង់ដីកាន់តែច្រើនរបស់ជនជាតិដើមភាគតិចពេលកន្លងមក រដ្ឋាភិបាលខ្វះឆន្ទៈនយោបាយក្នុងការអនុម័តអនុក្រិត្យ និងដំណើរការផ្តល់ប្លង់កម្មសិទ្ធិដីសមូហភាព [៨២]។ នៅទីបំផុត អនុក្រិត្យមួយដែល មិនជាទីពេញចិត្តត្រូវបានអនុម័តនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៩។

## ការប្តូរលំនៅដ្ឋាន និងសំណងដល់ម្ចាស់ដី

ច្បាប់រ៉ែចែងថា មុនពេលចូលទៅក្នុងដីជាកម្មសិទ្ធិឯកជនសម្រាប់ធ្វើការរុករករ៉ែឬធ្វើអាជីវកម្មរ៉ែ សម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែត្រូវមានកិច្ចព្រមព្រៀងជាលាយល័ក្ខអក្សរពីម្ចាស់ និង ត្រូវតែទូទាត់សងម្ចាស់កម្មសិទ្ធិនូវការខូចខាត ឬ ការប៉ះពាល់ (មាត្រា៧ និង២៥) ។ ការចែងនេះស្របទៅជាមួយច្បាប់រដ្ឋធម្មនុញ្ញ (មាត្រា៤៤) និងច្បាប់ភូមិបាលឆ្នាំ២០០១ (មាត្រា៥) ដែលបង្ហាញពីការដែលមិនអាចដកហូតនូវសិទ្ធិកម្មសិទ្ធិពីអ្នកណាម្នាក់បាន លុះត្រាតែការដកហូតនោះ ដើម្បីផលប្រយោជន៍សាធារណៈ បន្ទាប់ពីមានសំណងសមស្រប ដែលស្របទៅតាមនិតិវិធីនៃច្បាប់ [៨៣]។ ដីកម្មសិទ្ធិឯកជនចង់សំដៅលើដី ដែលមានប័ណ្ណកម្មសិទ្ធិចុះក្នុងបញ្ជី។ ការនេះធ្វើអោយម្ចាស់ដីដែលមិនមានចុះបញ្ជីដីតាមផ្លូវច្បាប់ត្រឹមត្រូវ ហើយចំនួនភាគច្រើននោះទទួលបាននូវការការពារតិចតួច ពីការប៉ះពាល់ ឬរងការបណ្តេញចេញពីកន្លែងធ្វើសកម្មភាព រ៉ែ។ អង្គការមិនមែនរដ្ឋាភិបាលបានលើកឡើងថា សិទ្ធិកម្មសិទ្ធិ ស្របច្បាប់ដែលមានចែងក្នុងលក្ខខណ្ឌនៃច្បាប់

[80] "Environmental and Social Impacts of Expansion of the Extractive Industries Sector," November 2008.
[81] Brown, Susie, Katrin Seidel and Todd Sigaty, *Legal Issues Related to Registration of Lands of Indigenous Communities in Cambodia*, GTZ, 2005.
[82] "Environmental and Social Impacts of Expansion of the Extractive Industries Sector," November 2008.
[83] Grimsditch, *Analysis of the Legal Framework Related to Mining in the Kingdom of Cambodia*.

ភូមិបាល គួរតែត្រូវគោរពផងដែរ[៨៤]។ សហគមន៍ជនជាតិដើមភាគតិច គួរតែទទួលបាននូវការការពារ ពីព្រោះច្បាប់ភូមិបាលឆ្នាំ២០០១ ទទួលស្គាល់សិទ្ធិរបស់គេ ក្នុងការប្រើប្រាស់ និងគ្រប់គ្រងដីជាប្រពៃណីរបស់គេមុនពេល មានផ្តល់កម្មសិទ្ធិសមូហភាពទៅទៀត (មាត្រា២៣)។ ច្បាប់ភូមិបាលចែងផងដែរថា គ្មានអាជ្ញាធរណាក្រៅសហគមន៍ តម្រូវឱ្យមានសិទ្ធិដោះដូរទ្រព្យសម្បត្តិសហគមន៍ឡើយ(មាត្រា២៨)។ ប្រហាក់ប្រហែលគ្នានេះដែរ គោលនយោបាយជាតិសម្រាប់ការអភិវឌ្ឍន៍ជនជាតិដើមភាគតិចលើកឡើងថាដីសហគមន៍ជនជាតិដើមភាគតិច ជាសម្បត្តិរួមដែលមិនអាចលក់ឬផ្ទេរឱ្យបុគ្គល ឬក្រុមណាមួយ នៅក្រៅសហគមន៍ឡើយ (មាត្រា៥, ៧)។ ថ្វីបើ មានខ្លឹមសារទាំងនេះក៏ដោយ ក្រុមហ៊ុនរ៉ែនៅមណ្ឌលគិរីដែលធ្វើសកម្មភាពហាក់ដូចជាចាត់ទុកថា អាជ្ញាប័ណ្ណ របស់ខ្លួនទទួលសិទ្ធិផ្តាច់មុខលើដែនដីជនជាតិដើមភាគតិច[៨៥]។

## ការចូលរួមជាមួយក្រុមហ៊ុនរ៉ែរបស់អ្នកភូមិហ្គាទី និងពូរ៉ាប៉ែត

ជាច្រើនសតវត្សរ៍មកហើយ ដែនដីនៅភូមិហ្គាទី ស្រុកកែវសីមា និងភូមិពូរ៉ាប៉ែត ស្រុកពេជ្រាដា គឺជារបស់ជនជាតិព្នងនៅទីនោះ ដែលជាកុលសម្ព័ន្ធមួយមានភាសា និងវប្បធម៌ខុសពីសង្គមខ្មែរ ជាជនភាគច្រើន។ នៅក្នុងឆ្នាំ១៨៦៣ នៅពេលដែលប្រទេសកម្ពុជាចុះសន្ធិសញ្ញាជាមួយប្រទេសបារាំង ជាអាណាព្យាបាល ជនជាតិព្នង ដែលបច្ចុប្បន្នរស់នៅក្នុងខេត្តមណ្ឌលគិរីធ្លាប់បានរស់តាមប្រព័ន្ធនយោបាយនិងសង្គមរបស់ពួកគេ ហើយក៏មិនដែលជិទាស់ ឬធ្វើតាមច្បាប់ប្រទេសកម្ពុជា ហើយក៏មិនបាននាំសួយសារអាករថ្វាយព្រះមហាក្សត្រដែរ។ បើតាមសៀវភៅរបស់លោក Mathieu Guerin ដែលមានចំណងជើងថា Paysans de la Foret a L’Epoque Coloniale គោលនយោបាយបារាំងមិនសូវផ្តោតលើការគ្រប់គ្រងដែនដីដែលសំបូរព្រៃនៅ ភាគឦសាននោះឡើយ ដែលពេលនោះ ពួកគេគិតថាតំបន់នេះមានតម្លៃសេដ្ឋកិច្ចតិចតួចណាស់ ហើយក៏មិនចង់ត្រួតត្រាសម្រាប់ការអភិវឌ្ឍន៍នាពេលអនាគតនោះដែរ។ នេះបង្ហាញអោយឃើញនូវផលលំបាក។ សង្គ្រាមបានផ្ទុះឡើងតាមកន្លែងមួយចំនួននៅដើមទសវត្សរ៍ ឆ្នាំ១៩០០ និងបន្តអស់រយៈពេលជាងពីរទសវត្សរ៍។ រហូតដល់ចុងឆ្នាំ១៩៣៥ កំលាំងយោធាបារាំង និងកម្ពុជាបានទទួលការគ្រប់គ្រងនៅក្នុងតំបន់នេះ[៨៦]។ ជនជាតិព្នងត្រូវបានគេចាត់ទុកថា ជាជនជាតិដើមភាគតិច ដោយសារជាជនជាតិភាគតិចនៅក្នុងប្រទេស ដែលមិនមានការស្ម័គ្រចិត្តរួមចូលក្នុងសង្គមទាំងមូល ហើយក៏មិនបានចូលរួម ក្នុងដំណើរការបង្កើតរដ្ឋ[៨៧]។ ការណ៍នេះ

[84] “Environmental and Social Impacts of Expansion of the Extractive Industries Sector,” in *NGO Position Papers on Cambodia’s Development in 2009-2010 to the 3rd Cambodia Development Cooperation Forum, 02-03 June 2010: Monitoring the Implementation of the National Strategic Development Plan and the 2008 CDCF Joint Monitoring Indicators,* Phnom Penh, May 2010. See also Grimsditch, *Analysis of the Legal Framework Related to Mining in the Kingdom of Cambodia.*

[85] See Kinetz and Yun, “Mining Companies, Villagers Vie for Gold in Mondulkiri Province.”

[86] Vachon, Micelle, “The Past Rediscovered,” The Cambodia Daily, 6-7 June 2009.

[87] Kymlicka, Will, *Contemporary Political Philosophy,* Oxford University Press, 2002 cited in Ehrentraut, “The Theory of Multiculturalism and Cultural Diversity in Cambodia.”

តម្រូវការអោយ ជនជាតិព្នងនៅភូមិហ្គាទី និងភូមិពូរ៉ាប៉ែតមានសិទ្ធិអោយមានការយល់ព្រមដោយសេរី និងផ្តល់ព័ត៌មានជាមុន ទាក់ទងនឹងសកម្មភាពរ៉ែ ដែលប៉ះពាល់ដល់ដែនដីរបស់ពួកគេ។ ជាអកុសល ពួកគេមិនអាចប្រើប្រាស់សិទ្ធិទាំងនោះទេ។ ផ្នែកនេះនឹងរៀបរាប់ ពីការចូលរួមរបស់ជនជាតិព្នង ក្នុងគម្រោងជីករ៉ែ ដែលត្រូវបានផ្តើមឡើង ក្នុងឆ្នាំ២០០៦ ដោយក្រុមហ៊ុនរ៉ែហាយឡាន នៅភូមិហ្គាទី ស្រុកកែវសីមា និង ក្រុមហ៊ុនរ៉ែហ្គោលមេថលគ្រុប នៅភូមិពូរ៉ាប៉ែត ស្រុកពេជ្រាដា។

## ការចូលរួមរបស់ជនជាតិព្នងក្នុងគម្រោងក្រុមហ៊ុនរ៉ែហាយឡាន ក្នុងភូមិហ្គាទី

នៅឆ្នាំ ២០០៦ ជនជាតិចិនដែលធ្វើការក្នុងក្រុមហ៊ុនរ៉ែហាយឡាន បានមកកាន់ភូមិហ្គាទីជាមួយ នឹងមន្ត្រីខ្មែរដែលគេមិនធ្លាប់ស្គាល់។ ពួកគេបានតំរង់ឆ្ពោះទៅមើលកន្លែងរណ្តៅចាស់ពីមុន ហើយជីកយកដីរ៉ែមាសជាសំណាក រួចបើកបររថយន្តចេញទៅវិញ។ ក្រុមពួកគេមិនដែលបានជួបជាមួយចាស់ទុំ ឬអាជ្ញាធរមូលដ្ឋានទេដូច្នេះ អ្នកភូមិមិនដឹងច្បាស់ទេថា តើពួកគេតំណាងអោយក្រុមហ៊ុន ឬស្ថាប័នរដ្ឋណា ឬមានបំណងធ្វើអ្វី នៅក្នុងតំបន់នោះទេ។ នៅពេលដែលពួកចិនបានចេញចូលនៅក្នុងភូមិ ប៉ុន្មានខែក្រោយមកទៀតនោះ ហើយបានជីកយកសំណាកដីរ៉ែ ទើបអ្នកភូមិបានដឹងពីអ្នកបកប្រែភាសាខ្មែរថា ពួកគេមកពីក្រុមហ៊ុនរ៉ែចិន។ ដោយសារពួកនោះមានគ្នាតិច ហើយចេញចូលម្តងម្កាលក្នុងភូមិហ្គាទី អ្នកភូមិមិនមានទំនាក់ទំនងដោយផ្ទាល់ជាមួយពួកគេនោះឡើយ។

នៅឆ្នាំ ២០០៧ ជនជាតិចិននោះបានត្រឡប់មកកាន់ភូមិហ្គាទីវិញ ដោយនាំមកជាមួយនូវកម្មករ និងគ្រឿងចក្រពេញទាំងរថយន្ត ដើម្បីបំរើអោយសកម្មភាពរុករករ៉ែរបស់គេ។ ក្នុងដំណើរនេះមានទាំងកំលាំងប្រដាប់អាវុធយោធានិងប៉ូលីសអមដំណើរផងដែរ។ បញ្ហានេះធ្វើអោយអ្នកភូមិព្នងមានការភ្ញាក់ផ្អើល និងមិនសប្បាយចិត្ត។ អ្នកភូមិមួយក្រុមដែលមានគ្នាចំនួនប្រហែល ៣០ នាក់ រួមទាំងចាស់ទុំ និងអាជ្ញាធរផង បានបញ្ឈប់រថយន្តមិនអោយចូលទៅតំបន់នោះ។ គេចង់ដឹងថា ហេតុអ្វីក៏ពួកគេមិនត្រូវបានប្រាប់ពី សកម្មភាពរបស់ក្រុមហ៊ុន ហើយក៏បានចោទសួរក្រុមហ៊ុនពីបំណងដែលចូលមកក្នុងភូមិ។ តំណាងជនជាតិព្នងម្នាក់ បានសំដែងអារម្មណ៍របស់ពួកគេថា *“នេះគឺជាសហគមន៍របស់យើង ហើយដីនេះគឺជាដីរបស់យើង។ តែអ្នកឯងចេញចូល ហាក់បីដូចជាទឹកដីនេះគឺជារបស់អ្នកឯង។’* ចិនបានឆ្លើយតបវិញថា គាត់បានទទួលអាជ្ញាប័ណ្ណដែលចេញដោយរដ្ឋាភិបាល ដែលអនុញ្ញាតអោយគេធ្វើការរុករករ៉ែមាសនៅក្នុងតំបន់នេះ។ កងកំលាំងប្រដាប់អាវុធបានក្នុងន័យបំផិតបំភ័យ ចំពោះអ្នកភូមិ។

បន្ទាប់មក អ្នកភូមិហ្គាទីបានសាកសួរដល់អាជ្ញាធរឃុំ ស្រុក ឬរហូតដល់ខេត្ត អោយជួយអន្តរាគមន៍ និងបញ្ឈប់សកម្មភាពរបស់ក្រុមហ៊ុនរ៉ែចិន។ តែគេបានប្រាប់អ្នកភូមិវិញថា ការរុករករ៉ែរបស់ក្រុមហ៊ុននេះ បាន

ការអនុញ្ញាតពីថ្នាក់ជាតិ ដូច្នេះហើយអ្នកភូមិមិនអាចបញ្ឈប់សកម្មភាពគេបានទេ។ ដូចនេះហើយពួកគេគួរតែបន្ថយការតវ៉ា ហើយចរចាជាមួយក្រុមហ៊ុនវិញជាការប្រសើរជាង។ អង្គការមិនមែនរដ្ឋាភិបាលខ្លះ ដែលធ្វើការនៅភូមិហ្គាទី ក៏បានផ្តល់យោបល់ស្របគ្នានេះដែរ ហើយប្រាប់អោយអ្នកភូមិស្នើក្រុមហ៊ុនអោយជួយអភិវឌ្ឍន៍នៅក្នុងភូមិវិញ។ ដោយមិនអាចស្វែងរកបានការគាំទ្រចំពោះការប្រឆាំងជាមួយក្រុមហ៊ុនរ៉ែ អ្នកភូមិជនជាតិព្នងធ្លាក់ក្នុងស្ថានភាពមិនអាចធ្វើអ្វីបានក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិរបស់គេ។

នៅឆ្នាំ ២០០៧ អ្នករុករករ៉ែចិនបានជួលផ្ទះមួយពីគ្រួសារព្នង-ខ្មែរនៅក្នុងភូមិហ្គាទី ហើយបានសង់រោងវែងបណ្តោះអាសន្ននៅពីមុខផ្ទះនោះសម្រាប់អោយកម្មករខ្មែរដែលបានជួលមកអោយធ្វើការរុករករ៉ែស្នាក់នៅ។ វត្តមានរបស់កម្មករខ្មែរច្រើនដែលចូលមកពីខាងក្រៅ គឺជាបញ្ហាដែលបង្កអោយជនជាតិព្នងមិនសប្បាយចិត្ត។ នៅពេលយប់ ពួកកម្មករទាំងនោះផឹកស្រា ហើយច្រៀងខារ៉ាអូខេ រំខានដល់អ្នកជិតខាង។ ជាងនេះទៅទៀតក៏មានបញ្ហាកើតឡើងរវាងកម្មករខ្មែរ និងយុវជនព្នងផងដែរ ហើយឪពុកម្តាយអ្នកភូមិជនជាតិព្នងក៏មានកង្វល់ពីសន្តិសុខនៃកូនស្រីរបស់គេដែរ។ ភាពតានតឹងនេះកើតឡើងអស់រយៈពេលជាច្រើនខែរហូតកម្មករ ចាកចេញពីភូមិ ហើយក្រោយមកសាងសង់ផ្ទះផ្ទាល់ខ្លួនដើម្បីស្នាក់នៅ ក្នុងការដ្ឋានរុករករ៉ែរបស់គេ។

នៅពេលដែល ចិនបានត្រឡប់មកវិញ នៅដើមរដូវប្រាំងឆ្នាំ ២០០៨ ដោយនាំមកជាមួយនូវកម្មករខ្មែរ និង រួមដំណើរដោយទាហាននិង នគរបាលប្រដាប់អាវុធ។ ក្រុមហ៊ុនបាននាំមកនូវ គ្រឿងចក្រធំៗ ដូចជាម៉ាស៊ីនឈូសដី ម៉ាស៊ីនជីកដី ម៉ាស៊ីនបំបែកថ្ម និងម៉ាស៊ីនភ្លើង ហើយបានឈូសឆាយផ្លូវ ទៅកាន់តំបន់រ៉ែ។ សកម្មភាពរុករករ៉ែនៅពេលនោះ កំពុងដំណើរការទៅយ៉ាងពេញលេញ។ ការដ្ឋានរ៉ែស្ថិតនៅ ក្នុងតំបន់ដែលអ្នកភូមិព្នងគិតថាជាព្រៃអ្នកតា ហើយពួកគេមិនដែលហ៊ានកាប់ឆ្ការព្រៃនៅកន្លែងនោះទេ។ ដោយសារពួកគេមានកង្វល់ពីការរានព្រៃរុករករ៉ែរបស់ក្រុមហ៊ុនដោយប្រើគ្រឿងម៉ាស៊ីនផ្សេងៗនោះ វានឹងធ្វើអោយអារក្សអ្នកតាខឹង ហើយប៉ះពាល់ ដល់សុខមាលភាពរបស់ពួកគេ ទើបចាស់ទុំបានចរចាជាមួយក្រុមហ៊ុន អោយរៀបចំធ្វើសែនព្រេនតាមប្រពៃណី។ ក្រោយមក នៅដើមឆ្នាំ ២០០៩ ក្រុមហ៊ុនបានរៀបចំពិធីសែនព្រេន នោះឡើងដោយ បានផ្តល់ថវិកាខ្លះដល់ចាស់ទុំអោយជួយរៀបចំ។ ពិធីកាប់ក្របីនិងផឹកស្រាបានរៀបចំឡើង ដើម្បីថ្វាយដល់ព្រលឹងអ្នកតា។ អ្នកភូមិជនជាតិព្នងជាច្រើនបានចូលរួមជាមួយខាងក្រុមហ៊ុនក្នុងពិធីនេះ។

មកត្រឹមដើមឆ្នាំ ២០០៩ អ្នកជីករ៉ែទាំងអស់បានស្នាក់នៅក្នុងផ្ទះឬស្សីដែលត្រូវបានសង់នៅកន្លែងការដ្ឋានជីករ៉ែ។ ការធ្វើដូច្នោះ បានកាត់បន្ថយភាពតានតឹងនៅក្នុងភូមិ តែមិនបានកាត់បន្ថយកង្វល់របស់អ្នកភូមិជនជាតិព្នង លើការទន្ទ្រានចូលក្នុងដីចំការរបស់គេ ការបំផ្លាញដើមដំរ និងការហាមមិនអោយចេញចូលក្នុងតំបន់ព្រៃនោះទេ។ ថ្វីបើក្រុមហ៊ុនបានអះអាងជាមួយអ្នកភូមិហ្គាទីថា ពួកគេអាចចេញចូលតំបន់ព្រៃដែលស្ថិតនៅក្រោម អាជ្ញាប័ណ្ណរ៉ែក្តី តែអ្នកភូមិព្នងមិនទុកចិត្តពាក្យសន្យារបស់ក្រុមហ៊ុនរ៉ែរបស់ចិននោះទេ។

### អង្គការមិនមែនរដ្ឋាភិបាលសម្របសម្រួលក្នុងការចូលរួមរវាងអ្នកភូមិ និងក្រុមហ៊ុនហាយឡាន

មានកម្មវិធីមួយចំនួនរបស់អង្គការមិនមែនរដ្ឋាភិបាលកំពុងដំណើរការ នៅភូមិហ្កាទី។ អង្គការអភិរក្សសត្វព្រៃ (WCS) ធ្វើការជាដៃគូជាមួយរដ្ឋបាលព្រៃឈើ ដើម្បីការពារតំបន់អភិរក្សជីវចំរុះសីមា ដែលរួមមានភូមិហ្កាទី និងការដ្ឋានរុករករ៉ែស្ថិតក្នុងតំបន់នោះផងដែរ។ អង្គការ DPA ដំណើរការកម្មវិធីអភិវឌ្ឍន៍ចំរុះ តាមសហគមន៍នៅ ឃុំស្រែព្រះ រួមទាំងភូមិហ្កាទី។ អង្គការក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT)ជួយគម្រោងផ្នែកកសិកម្មនៅភូមិហ្កាទី។ វត្តមាននៃអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ និងអង្គការដទៃទៀត នៅភូមិហ្កាទី ដោយមានការទាក់ទងរបស់គេជាមួយនឹងអាជ្ញាធរស្រុក និងអាជ្ញាធរខេត្ត ក្នុងស្ថាប័នរដ្ឋាភិបាល បានជួយធ្វើឱ្យមានដំណើរការពិគ្រោះយោបល់ រវាងក្រុមហ៊ុនហាយឡាន និងអ្នកភូមិជនជាតិព្នង។

អង្គការ WCS បានតាមដានសកម្មភាពរបស់ក្រុមហ៊ុនរ៉ែយ៉ាងយកចិត្តទុកដាក់ ហើយបានផ្តល់ព័ត៌មានដល់សហគមន៍មូលដ្ឋាន។ អង្គការ WCS បានជំទាស់ចំពោះផែនការរបស់ក្រុមហ៊ុន ក្នុងការកសាងផ្លូវថ្មីមួយទៀត ចូលទៅតំបន់ការដ្ឋានរ៉ែ ដោយសារវានឹងងាយធ្វើអោយព្រៃឈើខ្ទេចខ្ទាំក្នុងតំបន់អភិរក្ស។ អង្គការ DPA ជួយរៀបចំគណៈកម្មការជំរទឹក នៅភូមិហ្កាទី ហើយបានលើកទឹកចិត្តអោយអ្នកភូមិជនជាតិព្នង ទាក់ទងជាមួយ ក្រុមហ៊ុនរ៉ែ។ អង្គការ DPA បានជួយចេញសោហ៊ុយចំណាយលើការធ្វើដំណើរដល់តំណាងជនជាតិព្នងម្នាក់ទស្សនកិច្ចរៀនសូត្រពីការដោះស្រាយបញ្ហារ៉ែរបស់សហគមន៍នៅប្រទេសហ្វីលីពីន។ ទាំងអង្គការ WCS ទាំងអង្គការ DPA បានធ្វើការលើកកំពស់ការយល់ដឹងស្តីពីសិទ្ធិជនជាតិដើមភាគតិច ហើយបានជួយសម្របសម្រួល ការប្រជុំរវាងក្រុមហ៊ុន និងអ្នកភូមិហ្កាទី។

នៅខែឧសភា ឆ្នាំ២០០៩ អង្គការ DPA បានរៀបចំការពិគ្រោះយោបល់ចំនួនកន្លះថ្ងៃ នៅស្រុកកែវសីមា ដែលមានតំណាងក្រុមហ៊ុនហាយឡាន មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល អង្គការមិនមែនរដ្ឋាភិបាលពីភ្នំពេញនិងខេត្តមណ្ឌលគិរី និងតំណាងជនជាតិព្នងក្នុងឃុំស្រែព្រះ ដែលក្នុងនោះមានភូមិហ្កាទីផងដែរ។ សមាជិកក្រុមស្រាវជ្រាវរបស់ គម្រោងវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) ឆ្លៀតឱកាសនោះ ដើម្បីចូលរួមផងដែរ។ ក្នុងពេលសួរឆ្លើយ អ្នកភូមិបានលើកឡើងនូវបញ្ហារណ្តៅចំហដែលបន្សល់ទុកដោយក្រុមហ៊ុន ក្រោយពេលជីកយកដីរ៉ែមាសហើយ។ រណ្តៅ ចំហទាំងនេះ អាចធ្វើអោយមានគ្រោះថ្នាក់ ដល់មនុស្ស និងសត្វ នៅក្នុងតំបន់រ៉ែ។ គេបានសុំអោយក្រុមហ៊ុនរ៉ែ ចាត់វិធានការលើរឿងនេះ។

អ្នកភូមិបានបន្តពន្យល់ថា គេបានដាំដំណាំខ្លះ ដូចជាស្វាយចន្ទី និងដំឡូង នៅលើដីចំការ របស់គេ ហើយថា គេនឹងបាត់បង់ចំណូល បើសិនជាចំការរបស់គេត្រូវបានបំផ្លាញ។ ដូចគ្នានេះដែរ អ្នកភូមិបានលើកឡើងនូវកង្វល់ ស្តីពីការកាប់ដើមឈើយកជ័ររបស់គេ នៅក្នុងតំបន់រ៉ែ។ តំណាងរបស់ក្រុមហ៊ុនចិនចង់អោយមន្ត្រីរដ្ឋាភិបាលជួយឆ្លើយទៅនឹងសំណួរជំនួសវិញ។ អ្នកភូមិបានទទួលការសន្យាថា ពួកគេនឹងទទួលបានសំណងចំពោះការខាតបង់ដល់ដំណាំ និងដើមជ័ររបស់គេ ថ្វីបើនៅដំណាក់កាលនេះ មិនទាន់មានការកំណត់បរិមាណ

នៃសំណងនៅឡើយទេ។ ការឆ្លើយតបនេះ មិនបានពេញចិត្តដល់ជនជាតិព្នងនោះឡើយ។ តំណាងជនជាតិព្នងម្នាក់ បានត្អូញត្អែថា "*យើងមិនចង់បានសំណងសម្រាប់ដីនិងធនធានរបស់យើងទេ។ យើងចង់រក្សាដីរបស់យើងសម្រាប់កូនចៅជំនាន់ក្រោយ។* " ការសុំនេះមិនមានអ្នកណាស្តាប់ទេ។ តំណាងរបស់ក្រុមហ៊ុន និង មន្ត្រីរដ្ឋាភិបាល មិនបានស្វែងយល់ពីការយល់ព្រមរបស់អ្នកភូមិព្នងទេ។ ផ្ទុយទៅវិញ ពួកគេមានបំណងបញ្ជាក់ពីសិទ្ធិរបស់រដ្ឋ នៅក្រោមច្បាប់ស្តីពីកម្មសិទ្ធិធនធានរ៉ែ និងមានបំណងបញ្ជាក់ទៅអ្នកភូមិព្នងថា ពួកគេនឹងទទួលបានសំណងគ្រប់គ្រាន់ចំពោះការខាតបង់។ សិទ្ធិរបស់ជនជាតិព្នងក្នុងការផ្តល់ឬមិនផ្តល់ការយល់ព្រមដោយសេរី និងប្រាប់អោយដឹងជាមុន មិនដែលត្រូវបានគេទទួលស្គាល់ ឬការពារនោះទេ។

## ការចូលរួមរបស់ជនជាតិព្នង ក្នុងគម្រោងរបស់ក្រុមហ៊ុនដីហ្គោលមេថលគ្រុប នៅភូមិពូរ៉ាប៉ែត

នៅឆ្នាំ ២០០៦ តំណាងរបស់ក្រុមហ៊ុនហ្គោលមេថលគ្រុប បានចូលមកតំបន់រ៉ែ នៅអូរវ៉ៃ្ល ដោយរាយការណ៍ថា មាននគរបាលការពារមកជាមួយផង ហើយបានប្រាប់ដល់ខ្មែរចំណាកស្រុកនិង ជនជាតិព្នង ដែលជាអ្នកជីករ៉ែ អោយចាកចេញពីតំបន់រ៉ែនោះ ពីព្រោះក្រុមហ៊ុនមានអាជ្ញាប័ណ្ណផ្តាច់មុខសម្រាប់ធ្វើការរុករករ៉ែនៅ កន្លែងនោះ។ ដោយបានឮថា ក្រុមហ៊ុនបានទទួលការអនុញ្ញាតជាផ្លូវការ និងឃើញវត្តមាននៃកងកំលាំងប្រដាប់អាវុធ អ្នកជីករ៉ែជាបុគ្គលទាំងនោះក៏ដកខ្លួនចេញដោយមិនមានការតវ៉ា។ ទោះជាយ៉ាងណាក្តី ការបង្ខំឱ្យអ្នកជីកមាសផ្ទាល់ខ្លួនទាំងនោះអោយចាកចេញពីកន្លែងនោះ បានធ្វើអោយអ្នកភូមិ ជនជាតិព្នងជាច្រើនមិនសប្បាយចិត្ត។ ជនជាតិព្នងម្នាក់ដែលធ្លាប់ជីកមាសបានបង្ហាញថា "*ដូនតារបស់យើង ជាអ្នករកឃើញរ៉ែនេះ ហើយរក្សាវាទុកសម្រាប់កូនចៅជំនាន់ក្រោយ។ ពេលនេះក្រុមហ៊ុនមកក្តោបក្តាប់យកអស់ ហើយហាមប្រាមយើងមិនអោយជីករ៉ែដូចមុនបានទៀត។*"

ក្រុមហ៊ុនហ្គោលមេថលគ្រុប ដែលជារបស់វៀតណាម នៅពេលនោះបានធ្វើរបងព័ទ្ធជុំវិញដី ១ត.ម[២]. នៅតំបន់ព្រៃមាស ហើយសាងសង់ជំរុំជីកមាសនៅក្នុងនោះ។ គ្រឿងចក្រធុនធ្ងន់ ដូចជារថយន្តធំ និង ម៉ាស៊ីនឈូសដីត្រូវបានគេទុកនៅទីនោះ និងសម្រាប់ការស្នាក់នៅរបស់កម្មករផងដែរ។ ក្រុមហ៊ុនក៏បានឈូសឆាយផ្លូវចូលទៅកាន់ការដ្ឋាននោះ។ នៅពេលឈូសផ្លូវ និងសាង់សង់ជំរុំនៅកន្លែងរ៉ែ ក្រុមហ៊ុនបានធ្វើការសែនព្រេនដោយបានអញ្ជើញមេភូមិ និងមេឃុំអោយចូលរួម។ គេមិនបានអញ្ជើញអោយជនជាតិព្នងសាមញ្ញចូលរួមទេ។ លើសពីនេះទៀត ពិធីនោះធ្វើឡើងតាមរបៀបវៀតណាម ដោយមានជ្រូកខ្វៃ មាន់និងទា និងផឹកស្រាបៀ។ ជនជាតិព្នងជាច្រើនមានការខឹងសម្បា ចំពោះការមិនអញ្ជើញអោយចូលរួម និងការមិនគោរពចំពោះ ព្រលឹងអ្នកតា ដែលត្រូវធ្វើការសែនព្រេនតាមប្រពៃណីរបស់ជនជាតិព្នងនូវការកាប់ក្របី និងស្រាពាង។ បន្ទាប់មកក្រុមហ៊ុនបានលួងចិត្តអ្នកភូមិពូរ៉ាប៉ែត ដោយធ្វើការសែនព្រេនជាលើកទី ២ ដោយកាប់ក្របី និងស្រាពាង។

ទោះបីជាប្រជាជននិងចាស់ទុំជនជាតិព្នងចំនួនប្រហែល ២០ នាក់ ត្រូវបានអញ្ជើញអោយចូលរួមក្នុងពិធីនេះក្តី តែមនុស្សជាច្រើននៅតែមានការអាក់អន់ចិត្តដដែល។

ការចូលរួមរបស់ជនជាតិព្នងជាមួយក្រុមហ៊ុនរ៉ែ បានបង្កអោយមានការបែកបាក់ផ្ទៃកសាមគ្គីភាពរបស់ជនជាតិព្នងនៅក្នុងភូមិ ដែលបញ្ហានេះធ្លាប់បានកើតឡើងពីរបីឆ្នាំមុនតាំងពីមានទំនាស់ដីធ្លីកើតមាននៅក្នុងសហគមន៍ដោយសារតែវត្តមានរបស់ក្រុមហ៊ុនចំការកៅស៊ូនៅភូមិពូរ៉ាប៉ែត។ ជនជាតិព្នងមួយចំនួនបានជំទាស់ជាមួយនឹងក្រុមហ៊ុន ចំណែកឯជនជាតិព្នងនិងថ្នាក់ដឹកនាំដែលទទួលប្រយោជន៍បានសហការជាមួយក្រុមហ៊ុនចំការកៅស៊ូនេះ។ បញ្ហានេះបានបំផ្លាញនូវសេចក្តីទុកចិត្តចំពោះចាស់ទុំ ក៏ដូចជាថ្នាក់ដឹកនាំជនជាតិព្នង ហើយធ្វើអោយពួកគេពិបាករួបរួមគ្នាបាន។ ជនជាតិព្នងដែលមានឥរិយាបថចំពោះក្រុមហ៊ុនរ៉ែ មានលំនាំដូចគ្នានឹងក្រុមហ៊ុនចំការកៅស៊ូដែរ។

ក្រុមហ៊ុនហ្គោលមេថល បានចាប់ផ្តើមប្រតិបត្តិការរុករករ៉ែជាក់ស្តែង នៅឆ្នាំ២០០៧។ កម្មកររ៉ែទាំងអស់ដែលធ្វើការអោយក្រុមហ៊ុននេះជាជនជាតិវៀតណាម។ មានតែអ្នកបើកបរខ្លះ និង នគរបាល ទាហានដែលត្រូវបានជួលអោយការពារការដ្ឋាន ដែលជាជនជាតិខ្មែរ។ កម្មករវៀតណាមដែលស្នាក់នៅក្នុង ការដ្ឋានមិនសូវមានការទាក់ទងជាមួយនឹងអ្នកភូមិពូរ៉ាប៉ែតទេ។ អ្នកលក់អាហារ និង ភេសជ្ជៈមិនត្រូវបានអនុញ្ញាតអោយចូលលក់នៅក្នុងតំបន់នោះទេ។ ក្រុមហ៊ុនផ្តល់អោយកម្មករនូវអាហារ និងទឹក ដែលដឹកយកមកពីស្រុកសែនមនោរម្យក្នុងទីរួមខេត្ត ដែលមានចំងាយប្រហែល ៥០ គ.ម.។

ការសំភាសន៍ជាមួយនឹងមេឃុំជនជាតិព្នងនៅក្រងតេះ និងមេភូមិជនជាតិព្នង នៅពូរ៉ាប៉ែត បានបង្ហាញអោយឃើញថា ពួកគាត់ បានដឹងតិចតួចពីសកម្មភាពរបស់ក្រុមហ៊ុនជីករ៉ែនេះ។ ក្រុមហ៊ុនមិនបានប្រាប់ អាជ្ញាធរមូលដ្ឋាន ឬចាស់ទុំជាជនជាតិព្នងនូវសកម្មភាពជាក់លាក់របស់គេក្នុងការរុករករ៉ែទេ។ ដោយសារតែមានទំនាក់ទំនងដ៏តិចតួចជាមួយក្រុមហ៊ុន អាជ្ញាធរមូលដ្ឋានមានអារម្មណ៍ថាមិនមានឥទ្ធិពលគ្រប់គ្រាន់ ដើម្បីរៀបចំអោយមានកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈពីសកម្មរ៉ែ រវាងក្រុមហ៊ុននិងអ្នកភូមិជនជាតិព្នង។ ដូចដែលអ្នកភូមិជនជាតិព្នងម្នាក់បានសង្កេតឃើញថា *"ហោប៉ៅរបស់ក្រុមហ៊ុនធំ ហើយគេមានលុយច្រើន។ គេមិនគិតគូរពីពួកយើងទេ។"* មន្ត្រីម្នាក់នៅមន្ទីរឧស្សាហកម្ម រ៉ែនិងថាមពលខេត្តបាននិយាយអោយដឹងថា អាជ្ញាប័ណ្ណរ៉ែត្រូវបានចេញដោយរដ្ឋាភិបាលថ្នាក់ជាតិ។ ចំណែកឯខាងក្រុមហ៊ុនវិញហ្គោលមេថលគ្រប់ក្នុងបទសំភាសន៍តាមទូរស័ព្ទបានអះអាងដែរថា គេបានទាក់ទង ជាមួយបុគ្គលិកមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត ហើយនិងអាជ្ញាធរមូលដ្ឋានក្នុងដំណើរចុះមកមើលតំបន់រ៉ែនេះ។

# សុវត្ថិភាពនៃការចិញ្ចឹមជីវិតរបស់អ្នកភូមិហ្កាទីនិង ភូមិពូរ៉ាប៉ែត ស្ថិតក្រោមការគំរាមកំហែងពីការរុករកនិងធ្វើអាជីវកម្មរ៉ែ

កម្ពុជាបានធ្វើសច្ចាប័នលើសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីជនជាតិដើមភាគតិចដែលអះអាងថា "ជនជាតិដើមភាគតិចមានសិទ្ធិ... ដើម្បីធានាបាននូវមធ្យោបាយចិញ្ចឹមជីវិត និងអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់ពួកគេ និងដើម្បីចូលរួមដោយសេរីនៅគ្រប់សកម្មភាពជាប្រពៃណី និង សេដ្ឋកិច្ចផ្សេងៗទៀត (មាត្រា២០)។ សេចក្តីប្រកាស បានបង្ហាញបន្ថែមទៀតថា "ជនជាតិដើមភាគតិចមានសិទ្ធិក្នុងការអភិរក្ស និងការពារបរិស្ថាន និងសមត្ថភាពផលិតកម្មលើដីធ្លីឬដែនដី និងធនធានរបស់ពួកគេ (មាត្រា២៩)។ ប្រទេសកម្ពុជាក៏បានធ្វើសច្ចាប័នលើ *អនុសញ្ញាអន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពី សិទ្ធិផ្នែកវប្បធម៌ សង្គម និងសេដ្ឋកិច្ច* និង *អនុសញ្ញាអន្តរជាតិ របស់អង្គការសហប្រជាជាតិស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ* ដែលបានបញ្ជាក់ថា : "គ្មានករណីណាមួយដែលមនុស្សត្រូវបានគេ ដកហូតមធ្យោបាយរបស់ខ្លួនក្នុងការប្រកបរបរ ចិញ្ចឹមជីវិតឡើយ" (មាត្រា១)។ ដូចគ្នានេះដែរ ប្រទេសកម្ពុជាបានអនុម័តលើ *គោលនយោបាយថ្នាក់ជាតិ ស្តីអំពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិច*ដែលបានចែងថា" ជនជាតិដើមភាគតិចទាំងអស់ត្រូវរួចផុតពីភាពក្រីក្រនិងភាពអត់ឃ្លាន"។ ផ្នែកនេះ ពិនិត្យមើលលើសុវត្ថិភាពនៃការចិញ្ចឹមជីវិត ដែលបានធានាបានដោយការប្រើប្រាស់សិទ្ធិ របស់ជនជាតិព្នងនៅភូមិហ្កាទី និងភូមិពូរ៉ាប៉ែត និងពិនិត្យមើលថាតើសកម្មភាពនៃការរុករករ៉ែនិង ធ្វើអាជីវកម្មរ៉ែ ធ្វើអោយប៉ះពាល់អ្វីខ្លះដល់សកម្មភាពនៃការរស់នៅរបស់ពួកគេ។

## ចំណាត់ថ្នាក់ប្រភពនៃការចិញ្ចឹមជីវិត

គ្រួសារជនជាតិព្នងនៅភូមិហ្កាទី និងភូមិពូរ៉ាប៉ែត បានធ្វើចំណាត់ថ្នាក់ ទៅលើការប្រមូលផលដំណាំកសិកម្ម ការដងជ័រទឹក និងការប្រមូលអនុផលព្រៃឈើផ្សេងៗ ជាប្រភពរបរចិញ្ចឹមជីវិតសំខាន់បំផុតកាលពីឆ្នាំកន្លងទៅ។ ការនេះបង្ហាញពីសារសំខាន់នៃធនធានធម្មជាតិសម្រាប់ជីវភាពរស់នៅក្នុងគ្រួសារ ហើយនិងសក្តានុពល ក្នុងការគំរាមកំហែងដោយសារសំណើពង្រីកសកម្មភាពរ៉ែ។ ការដងជ័រ និងការប្រមូលផលផ្សេងៗទៀត ពីព្រៃឈើមានចំណាត់ថ្នាក់សំខាន់ជាងគេសម្រាប់ជីវភាពរស់នៅក្នុងភូមិហ្កាទី ចំណែកឯភូមិពូរ៉ាប៉ែតវិញ ដំណាំដាំដុះមានសារៈសំខាន់ជាងគេ។ បើប្រៀបធៀបជាមួយភូមិហ្កាទី ដំណាំដាំដុះជាប្រភពសំខាន់ទីពីរ ចំណែង

ប្រភពសំខាន់ទីពីរភូមិពូរ៉ាប៉ែតវិញគឺការដងជ័រ និងផលផ្សេងៗពីព្រៃឈើ [88]។ សំណាកគ្រួសារក្នុងភូមិហ្កាទី និងភូមិពូរ៉ាប៉ែតមានទំនាក់ទំនងគ្នាជាមួយឧស្សាហកម្មព្រៃឈើ (ការដងជ័រ ប្រមូលផល និង អនុផលព្រៃឈើ ហើយ/ឬ បរបាញ់និងដាក់អន្ទាក់)។ គ្រួសារទាំងអស់ លើកលែងតែមួយ ក្នុងភូមិទាំងពីរបានធ្វើដំណាំដាំដុះ។

ការចិញ្ចឹមសត្វស្ថិតក្នុងប្រភពចិញ្ចឹមជីវិតសំខាន់ទីបីនៅភូមិទាំងពីរ។ ក្របីត្រូវបានចិញ្ចឹម និងលក់សម្រាប់រៀបចំ ពិធីបែបប្រពៃណីផ្សេងៗ ចំណែកឯការចិញ្ចឹមជ្រូកនិងមាន់គឺសំរាប់ជួយផ្តល់ជាប្រាក់ចំណូលបន្ថែមមួយសំខាន់ដែរ។ ការនេសាទត្រីជួយផ្តល់ជាម្ហូបប្រូតេអ៊ីន ប៉ុន្តែមិនជាប់ចំណាត់ថ្នាក់ថាជាប្រភពចិញ្ចឹមជីវិត សំខាន់សម្រាប់គ្រួសារនៅក្នុងភូមិទាំងពីរឡើយ។ មានគ្រួសារតិចជាងពីរភាគបីនៅក្នុងភូមិទាំងពីរបានធ្វើការដើម្បីប្រាក់កំរៃនិង/ឬជួញដូរ បើទោះបី ជាការងារនេះត្រូវបានគ្រួសារនៅភូមិពូរ៉ាប៉ែត ចាត់ចំណាត់ថ្នាក់ខ្ពស់ជាងគ្រួសារនៅភូមិហ្កាទីបន្តិចក៏ដោយ (តារាងទី១)។ ការតាំងទីលំនៅរបស់អ្នកភូមិពូរ៉ាប៉ែតប្រមាណជា២៥ គីឡូម៉ែត្រពីទីរួមខេត្ត ជាឱកាសមួយងាយក្នុងការធ្វើការដើម្បីប្រាក់កំរៃ និង/ឬជួញដូរ។

**តារាងទី ១: ចំណាត់ថ្នាក់សកម្មភាពមុខរបររបស់គ្រួសារនៅក្នុងភូមិហ្កាទីនិងភូមិពូរ៉ាប៉ែត**

| | **ភូមិហ្កាទី** | **ភូមិពូរ៉ាប៉ែត** |
|---|---|---|
| | ចំណាត់ថ្នាក់ជាមធ្យម | |
| ការដងជ័រ ប្រមូលស្បៀងនិងផលិតផលពីព្រៃឈើ ការបរបាញ់ និង ដាក់អន្ទាក់សត្វ | 1.6 (n=32) | 2.3 (n=39) |
| ដំណាំដាំដុះ (ស្រូវ ស្វាយចន្ទី កាហ្វេ បន្លែ និងផ្លែឈើ) | 1.7 (n=32) | 1.4 (n=38) |
| ការចិញ្ចឹមជ្រូក មាន់ ទា គោ និង ក្របី | 3.0 (n=31) | 3.0 (n=39) |
| ការរកត្រី | 4.0 (n=30) | 4.1 (n=33) |
| ការងារដើម្បីប្រាក់កំរៃ (រួមមានការយករ៉ែ និង ការងារកសិកម្ម) ការធ្វើនិងលក់ទំនិញ ការទិញនិងលក់ទំនិញ | 4.4 (n=20) | 1.4 (n=24) |

n=ចំនួនគ្រួសារដែលបានចូលរួមផ្តល់ចំណាត់ថ្នាក់ពីប្រភពមុខរបរ។ ចំនួនគ្រួសារសរុបនៅភូមិហ្កាទីគឺ៣២ និងភូមិពូរ៉ាប៉ែតគឺ ៣៩។ អ្នកផ្តល់ចម្លើយបានធ្វើចំណាត់ថ្នាក់នៃប្រភពមុខរបរ ពី ១ ទៅ ៥ ទៅតាមលំដាប់ថ្នាក់ពីសំខាន់ បំផុតគឺលេខ ១។

---

[88] សូមមើលលំអិតពីការសិក្សាឆ្នាំ ២00៣/២00៣ ស្តីពីប្រភពចំណូលក្នុងគ្រួសារនៅឃុំស្រែព្រះ រួមមានភូមិហ្កាទីដែលបង្ហាញថាផលិតផលព្រៃឈើ ការបរបាញ់និងដាក់អន្ទាក់ផ្តល់ចំណូល ៤៩.៥ ភាគរយក្នុងគ្រួសារ រីឯដំណាំដាំដុះស្មើនឹង ២៤.0 ភាគរយនៃចំណូលគ្រួសារ។ សូមមើល McAndrew et al, *Indigenous Adaptation to a Decline in Natural Resources*.

## យុទ្ធសាស្ត្រប្រកបរបរចិញ្ចឹមជីវិតផ្សេងៗ

ជីវភាពគ្រួសារនៅក្នុងភូមិហ្គាទីនិងភូមិពូរ៉ាប៉ែត អាស្រ័យដោយការប្រកបរបរ និងការស្វែងរកផលិតផលចំរុះច្រើនយ៉ាង (តារាង២)។ គ្រួសារទាំងអស់ក្នុងភូមិហ្គាទី និងភូមិពូរ៉ាប៉ែត លើកលែងតែ ២គ្រួសារប៉ុណ្ណោះក្នុងភូមិពូរ៉ាប៉ែត បានដាំដំណាំផ្សេងទៀត លើដីចម្ការដែលភាគច្រើនដាំស្រូវ ដាំបន្លែនិងផ្លែឈើផ្សេងៗ។ គ្រួសារជនជាតិដើមភាគតិច ភាគច្រើននៅភូមិហ្គាទីដាំស្វាយចន្ទី តែមានតិចតួចជាងនៅភូមិពូរ៉ាប៉ែត។ គ្រួសារក្នុងភូមិពូរ៉ាប៉ែតតិចជាងមួយភាគពីរធ្វើស្រែវស្សា និងមានតិចជាងមួយភាគបួនក្នុងភូមិហ្គាទី។ ចំណែកឯការចិញ្ចឹមមាន់ និងជ្រូក គឺមានការពេញនិយមក្នុងភូមិទាំងពីរ ហើយការចិញ្ចឹមទាឃើញមានរិតតែច្រើននៅភូមិពូរ៉ាប៉ែត។ ចំពោះការចិញ្ចឹមគោ និង/ឬក្របី មានប្រហែលជាមួយភាគពីរនៃគ្រួសារក្នុងភូមិហ្គាទី និងពីរភាគបីនៅភូមិពូរ៉ាប៉ែត។ អ្នកភូមិហ្គាទីស្ទើរតែទាំងអស់ និងជាងពាក់កណ្តាលភូមិពូរ៉ាប៉ែតប្រកបរបរដងជ័រ។ គ្រួសារជាច្រើននៅ ភូមិទាំងពីរបានប្រមូលបន្លែ ផ្លែឈើ និងអនុផលផ្សេងៗទៀតពីព្រៃឈើ។ រីឯការប្រមាញ់ និងដាក់អន្ទាក់ គឺ មានតិចតួចនៅក្នុងភូមិទាំងពីរ។ នេះបញ្ជាក់ពីភាពចាំបាច់នៃធនធានព្រៃឈើ ក្នុងការប្រករបរចិញ្ចឹមជីវិត របស់គ្រួសារជនជាតិដើមភាគតិច។ ជាងនេះទៅទៀត ការនេសាទត្រីក៏មានភាពលេចធ្លោក្នុងភូមិទាំងពីរដែរ។ ផ្ទុយទៅវិញ មិនថានៅក្នុងភូមិណាមួយទេ គ្រួសារជនជាតិដើមភាគតិចមិនសូវមានរបរក្នុងការផលិត ការទិញ និងការទិញនិងលក់ទំនិញទេ។ ស្រដៀងគ្នានេះដែរ ក្នុងភូមិទាំងពីរ ជនជាតិព្នងតិចជាងមួយ ភាគពីរ ចូលរួមក្នុងការងាររកប្រាក់កម្រៃផ្សេងៗ។

### ការដាំដំណាំ

គ្រួសារទាំង៣២នៅភូមិហ្គាទីដាំដំណាំលើដីចម្ការកាលពីឆ្នាំកន្លងទៅដែលមានទំហំដីជាមធ្យម ១,៧ហិកតា។ ក្នុងចំណោមគ្រួសារនេះ មាន ២៦ គ្រួសារ បានដាំស្រូវលើដីចម្ការ ដែលទទួលបានទិន្នផលប្រហែល ៣៧៨ គីឡូក្រាម។ ស្រដៀងគ្នានេះដែរ ៣១គ្រួសារ ក្នុងភូមិហ្គាទី ដាំស្វាយចន្ទីលើដីចម្ការ ដែលប្រមូលផលជាមធ្យមគឺ ៣៩៣ គីឡូក្រាម។ អ្នកភូមិហ្គាទីក៏បានដាំដំណាំផ្សេងៗ ជាង២០ប្រភេទទៀតដូចជា ល្ពៅ ពោត ស្លឹកគ្រៃ ននោង ម្ទេស ត្រប់ ល្ហុង ចេក ល្ពៅ ត្រសក់ ម្នាស់ ឃ្លោក ត្រាវ និង អំពៅ។ មានតែ ៧ គ្រួសារប៉ុណ្ណោះក្នុងភូមិហ្គាទី ដែលធ្វើស្រូវវស្សាកាលពីឆ្នាំកន្លងទៅលើផ្ទៃដីជាមធ្យមមួយហិចតា និង ទទួលទិន្នផលមធ្យម ៤៨៤ គីឡូក្រាម។

| តារាងទី ២. យុទ្ធសាស្ត្រក្នុងការប្រកបមុខរបរកាលពីឆ្នាំកន្លងទៅ គិតតាមគ្រួសារជនជាតិដើមភាគតិច ភូមិហ្គាទី និងភូមិពូរ៉ាប៉ែត ខែឧសភា ឆ្នាំ២០០៩ | | |
|---|---|---|
| | ភូមិហ្គាទី | ភូមិពូរ៉ាប៉ែត |
| *ចំនួនករណីគ្រួសារសរុប* | ***32*** | ***39*** |
| ការដាំស្រូវលើដីចម្ការ | 26 | 34 |
| ការដាំស្វាយចន្ទី | 31 | 7 |
| ការដាំបន្លែ និង ផ្លែឈើផ្សេងៗ | 30 | 37 |
| ការធ្វើស្រូវវស្សា | 7 | 18 |
| ការចិញ្ចឹមមាន់ | 30 | 37 |
| ការចិញ្ចឹមជ្រូក | 27 | 36 |
| ការចិញ្ចឹមគោ/ក្របី | 15 | 28 |
| ការចិញ្ចឹមទា | 3 | 19 |
| ការដងជ័រឈើ | 31 | 24 |
| ការរកបន្លែ និងផ្លែឈើពីព្រៃ | 30 | 36 |
| គាររកផលិតផល (ក្រៅពីជ័រឈើ)ពីព្រៃ | 30 | 37 |
| ការបរបាញ់ ឬ ការដាក់អន្ទាក់សត្វ | 12 | 21 |
| ការរកត្រី | 30 | 33 |
| ការធ្វើ និងលក់ទំនិញ | 9 | 10 |
| ការទិញ និងលក់ទំនិញ | 2 | 3 |
| ការងារមានប្រាក់កម្រៃ | 13 | 19 |

ក្នុងឆ្នាំកន្លងទៅ ភូមិពូរ៉ាប៉ែតមាន ៣៧ គ្រួសារនៃ គ្រួសារទាំងអស់៣៩ បានដាំដំណាំលើដីចម្ការរបស់ខ្លួន ដែលមានទំហំជាមធ្យមគឺមួយហិកតា។ គ្រួសារចំនួន៣៤ ក្នុងចំណោមគ្រួសារទាំង៣៩ បានប្រមូលផលស្រូវលើដីចម្ការរបស់ខ្លួន ដែលទិន្នផលជាមធ្យមគឺ ៣៤0 គីឡូក្រាម។ មានតែ ៧ គ្រួសារប៉ុណ្ណោះដែលដាំស្វាយចន្ទីលើដីចម្ការ។ អ្នកភូមិពូរ៉ាប៉ែតក៏បានដាំដំណាំផ្សេងៗទៀតជាង២0ប្រភេទផងដែរដូចជា ឃ្លោក ពោត ននោង ម្ទេស ល្ពៅ ត្រប់ ត្រសក់ ល្ហុង ស្លឹកគ្រៃ ល្មៀត ចេក និង ដំឡូង។ មានគ្រួសារ ១៨ គ្រួសារក្នុងចំណោមគ្រួសារទាំង៣៩ បានធ្វើស្រូវវស្សាក្នុងឆ្នាំកន្លងទៅលើដីជាមធ្យម ១.៥ ហិកតា ហើយទទួលផលជាមធ្យម ១ ០១៦ គីឡូក្រាម។

## ការប្រមូលជ័រ បន្លែ ផ្លែឈើ និងផលិតផលព្រៃឈើផ្សេងទៀត

ភូមិហ្កាទីគ្រួសារចំនួន ៣១ ក្នុងចំណោមគ្រួសារសិក្សាទាំង៣២ ប្រកបរបរដងជ័រ ក្នុងឆ្នាំកន្លងទៅ។ ក្នុងចំណោមគ្រួសារទាំងនេះ ៣០ គ្រួសារមានដើមជ័រជាមធ្យម ៦៥ដើម។ ស្រដៀងគ្នានេះដែរ កាលពីឆ្នាំកន្លងទៅ មានគ្រួសារចំនួន ៣០ ក្នុងចំណោមគ្រួសារទាំង ៣២ បានបេះបន្លែ និងផ្លែឈើពីព្រៃ រួមមាន ត្រពាំង ផ្សិត បន្លែស្លឹកបៃតង ផ្លែភ្សេវ ស្វាយព្រៃ សាវម៉ាវព្រៃ ចេកព្រៃ។ លើសពីនេះ ទៅទៀតគ្រួសារចំនួន ៣០ ក្នុងចំណោមគ្រួសារទាំង ៣២ ក៏បានរកផលិតផល ពីព្រៃឈើដែរ ក្នុងឆ្នាំកន្លងទៅ ដូចជា ឧស ស្បូវ ផ្តៅ ឈើវែងៗ ឫស្សី វល្លិ៍ រុក្ខជាតិថ្នាំ ឈើ និងទឹកឃ្មុំ ។

ភូមិពូរ៉ាប៉ែត គ្រួសារចំនួន២៤ ក្នុងចំណោមគ្រួសារសិក្សាទាំង៣៩ ប្រកបរបរដងជ័រ ក្នុងឆ្នាំកន្លងទៅ។ ក្នុងចំណោមគ្រួសារទាំង៣៩ មានគ្រួសារចំនួន ២៣ ដែលមានដើមជ័រជាមធ្យម ២៤៣ ដើម។ ស្របពេលនេះដែរ ក្នុងឆ្នាំកន្លងទៅ មានគ្រួសារចំនួន៣៦ បានបេះបន្លែ និងផ្លែឈើពីព្រៃរួមមាន ត្រពាំង ផ្សិត បន្លែស្លឹកបៃតង ផ្លែភ្សេវ ស្វាយព្រៃ និងផ្លែឈើតូចៗរាងដូចស្វាយ។ លើសពីនេះទៅទៀត កាលពីឆ្នាំកន្លងទៅ មានគ្រួសារចំនួន ៣៧ ក៏បានរកផលិតផល ពីព្រៃឈើដែរ ដូចជា ឧស ស្បូវ ផ្តៅ ឈើវែងៗ ឫស្សី ទឹកឃ្មុំ វល្លិ៍ រុក្ខជាតិថ្នាំ បង្គោល និង ឈើ។

## ការបរបាញ់សត្វ និងការដាក់អន្ទាក់សត្វ

កាលពីឆ្នាំកន្លងទៅ ក្នុងភូមិហ្កាទី គ្រួសារចំនួន ១២ ក្នុងចំណោមគ្រួសារសិក្សាទាំង ៣២ បានបរបាញ់ ឬ ដាក់អន្ទាក់សត្វ ដូចជា កង្កែប អណ្តើក ត្រកួត នៅក្នុងព្រៃ ជ្រូកព្រៃ សត្វបក្សីព្រៃ និងឈ្លូស។ ផ្ទុយទៅវិញ ក្នុងភូមិពូរ៉ាប៉ែតក្នុងឆ្នាំកន្លងទៅ មាន ២១ គ្រួសារ ក្នុងចំណោមគ្រួសារសិក្សាទាំង ៣៩ បានបរបាញ់ ឬ ដាក់អន្ទាក់សត្វ រួមមានកង្កែប អណ្តើកតូចៗ ត្រកួត សត្វបក្សីព្រៃ ពស់ ទន្សាយ និង ជ្រូកព្រៃ កាំប្រមា ឈ្លូស សំពោច និងក្តាន់ញ៉ៀងតូចឬធំ។ ជនជាតិព្នងនៅក្នុង ភូមិទាំងពីរ តែងតែប្រមាញ់ដោយបណ្តើរឆ្កែ និង ប្រើប្រាស់ឧបករណ៍បុរាណ។

## ការនេសាទ

កាលពីឆ្នាំកន្លងទៅ ភូមិហ្កាទីមានគ្រួសារចំនួន ៣០ នៃគ្រួសារសិក្សាទាំង ៣២ បាននេសាទត្រី ដែលត្រីភាគច្រើនជាត្រីចង្វារ ត្រីអណ្តែង ត្រីរ៉ស់ អន្ទង់ ត្រីឆ្លាំង និង ត្រីកញ្ចុះ។ ផ្ទុយទៅវិញក្នុងភូមិពូរ៉ាប៉ែត គ្រួសារចំនួន ៣៣ ក្នុងចំណោមគ្រួសារសិក្សាទាំង ៣៩ បានរកត្រីក្នុងឆ្នាំកន្លងទៅ ត្រីដែលរកបានភាគច្រើនគឺ ត្រីចង្វារ ត្រីអណ្តែង ត្រីរ៉ស់ ត្រីឆ្លាំង ត្រីកញ្ចុះ និង អន្ទង់។

## ការផលិត ការលក់ដូរ និងការរកប្រាក់កម្រៃផ្សេងទៀត

ក្នុងឆ្នាំកន្លងទៅក្នុងភូមិហ្គាទី មានតែ ៩ គ្រួសារប៉ុណ្ណោះ ក្នុងចំណោមគ្រួសារសិក្សាទាំង ៣២ បានរកចំណូលពីការធ្វើ និងលក់ទំនិញ ដូចជា កញ្ច្រែងរែងអង្ករ ស្រាអង្ករ ឃ្លោក និង កន្ទ្រក។ ដូចគ្នានេះដែរ ក្នុងភូមិហ្គាទី មានគ្រួសារតែ ២ ប៉ុណ្ណោះក្នុងចំណោមគ្រួសារសិក្សាទាំង ៣២ បានរកប្រាក់ចំណូលពីការទិញនិង លក់ទំនិញ ដូចជាការទិញទំនិញពីផ្សារ ដើម្បីយកទៅលក់អោយអ្នកភូមិផ្សេងទៀត។ ក្នុងភូមិហ្គាទី មាន ១៣ គ្រួសារ បានចូលរួមក្នុងការងារមានប្រាក់កម្រៃក្នុងឆ្នាំកន្លងទៅដែលការងារភាគច្រើន រួមមាន ការងារកសិកម្ម ការងារសំណង់ ឬ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។

ក្នុងភូមិពូរ៉ាប៉ែត គ្រួសារចំនួន ១០ ក្នុងចំណោមគ្រួសារសិក្សាទាំង ៣៩ បានរកប្រាក់ចំណូល ពីការធ្វើ និងលក់ទំនិញក្នុងឆ្នាំកន្លងទៅដូចជា ស្រាអង្ករ កញ្ច្រែងរែងអង្ករ និងកន្ទ្រក។ ក្នុងភូមិពូរ៉ាប៉ែត មានតែ ៣ គ្រួសារប៉ុណ្ណោះ បានរកប្រាក់ចំណូលពីការទិញនិងលក់ទំនិញខុសៗគ្នាក្នុងឆ្នាំកន្លងទៅ ដែលទំនិញភាគច្រើន គឺសត្វ គោ និង ក្របី ជ្រូក ត្រី ទឹកឃ្មុំ សត្វព្រៃ បន្លែ និង ផលិតផលផ្សេងទៀត។ ភូមិពូរ៉ាប៉ែត គ្រួសារចំនួន ១៩ បានរកប្រាក់កម្រៃពីការងារផ្សេងទៀតក្នុងឆ្នាំកន្លងទៅ ដូចជាពីការងារកសិកម្ម។ មានគ្រួសារផ្សេងទៀត បានប្រាក់កម្រៃពីការងារអង្គការ និងរដ្ឋាភិបាល។ ដូច្នេះហើយការងារទាំងនេះតម្រូវឱ្យចាកចេញពីភូមិលើសពីពីរសប្តាហ៍។

## សុវត្ថិភាពក្នុងការប្រកបរបរចិញ្ចឹមជីវិតនៅត្រឹមតែសម្រាប់រស់

ជារួម ស្ថានភាពជីវភាពដែលលេចឡើងថ្មីៗ របស់ជនជាតិដើមភាគតិចនៅភូមិហ្គាទី និងពូរ៉ាប៉ែត ប្រឈម ជាមួយនឹងសុវត្ថិភាពម្ហូបអាហារ ដែលសូម្បីតែពេលខ្លះមានភាពខ្វះខាត និងហូបមិនគ្រប់គ្រាន់។ សុវត្ថិភាព ស្បៀងអាហារក្នុងភូមិហ្គាទីពឹងផ្អែកខ្លាំងលើដំណាំចម្ការ និង ថវិកាដែលទទួលបានពីដំណាំស្វាយចន្ទី និង ការដងជ័រ។ ផ្ទុយមកវិញ សុវត្ថិភាពស្បៀងអារហារ នៅភូមិពូរ៉ាប៉ែត ពឹងផ្អែកទាំងស្រុងលើការធ្វើកសិកម្ម ក្នុងដីស្រែ និង ដីចម្ការ និងថវិកាទទួលបានពីការដងជ័រ និងការរកប្រាក់កម្រៃផ្សេងទៀត។ ទិន្នន័យមិនបាន បញ្ជាក់ ច្បាស់ពីភាពខុសគ្នាលើចំនួនដីជាហិកតាសម្រាប់ដំណាំចម្ការនិងស្រែឡើយ ចំនួនជាគីឡូក្រាមទទួលបាន ពីស្រូវចម្ការ ស្រូវស្រែ និងស្វាយចន្ទី និង ទៅតាមចំនួនដើមជ័រដែលបានដង ក្នុងចំណោមគ្រួសារក្នុងភូមិទាំងពីរទេ។ នេះបង្ហាញថាកំរិតចំណូលក្នុងចំណោមអ្នកភូមិទាំងពីរមានភាពមិនស្មើគ្នា។ ខណៈដែល ការសិក្សានេះ មិនបានប្រមូលពីកំរិតចំណូលរបស់គ្រួសារ និងធ្វើការគណនា ឱ្យបានច្បាស់លាស់ ការសិក្សាស្រាវជ្រាវសង្កេតឃើញថា ខេត្តមណ្ឌលគីរីមានអត្រាក្រីក្រខ្ពស់ជាងអត្រាមធ្យមថ្នាក់ជាតិសម្រាប់គ្រួសារនៅជនបទ [៨៩]។ ដោយសារ យុទ្ធសាស្ត្រផ្សេងៗ ក្នុងការប្រកបរបរចិញ្ចឹមជីវិត ផ្តល់នូវសុវត្ថិភាពស្បៀងអាហារដល់ជនជាតិដើម

---

[89] សូមមើល McAndrew et al, *Indigenous Adaptation to a Decline in Natural Resources.*

ភាគតិច ដែលពឹងផ្អែកលើធនធានដីនិងព្រៃឈើ ការនេះធ្វើអោយពួកគាត់ងាយរងគ្រោះធ្ងន់ធ្ងរ ពីការទន្ទ្រាន របស់ ក្រុមហ៊ុនសាជីវកម្មដល់បរិស្ថានធម្មជាតិ [៩០] ។

## ផលប៉ះពាល់ពីសកម្មភាពរ៉ែមកលើការចិញ្ចឹមជីវិតរបស់អ្នកភូមិ

មកដល់សព្វថ្ងៃនេះការរុករករ៉ែនៅភូមិហ្គាទី និង ពូរ៉ាប៉ែតមិនប៉ះពាល់ខ្លាំងដល់សុវត្ថិភាពស្បៀង អាហារនៃគ្រួសារជនជាតិដើមភាគតិចទេ។ អ្នកភូមិនៅតែអាចដាំដំណាំលើដីស្រែនិងដីចម្ការ ចិញ្ចឹមសត្វជាម្ហូប អាហារ និងកំលាំងអូសទាញ ប្រមូលជ័រ និង អនុផលព្រៃឈើផ្សេងៗ បរបាញ់និងដាក់អន្ទាក់សត្វ រកត្រី និង ធ្វើការងាររកប្រាក់កម្រៃផ្សេងទៀត។ ដំណាក់កាលនេះនៃដំណើរអភិវឌ្ឍន៍រ៉ែ នៅភូមិទាំងពីរ មិនមានអ្វីគួរឱ្យ ភ្ញាក់ផ្អើលទេ។ តាមការបង្ហាញរបស់ Roderick G. Eggert នៅក្នុងសន្និសីទអន្តរជាតិស្តីពីរ៉ែ ដែលបានបញ្ជាក់ ក្នុងសេចក្តីផ្តើមនៃការសិក្សានេះដែលថា ផលប៉ះពាល់នៅដំណាក់កាលដើររុករករ៉ែដំបូង និងជាន់ខ្ពស់ មិនសូវ មានផលប៉ះពាល់ខ្លាំងពេកទេ បើប្រៀបធៀបដំណាក់កាលអភិវឌ្ឍរ៉ែនិង ចាប់ផ្តើមប្រតិបត្តិទាញយករ៉ែ [៩១] ។ Eggert ពន្យល់ថាដំណាក់កាលរុករករ៉ែជាន់ខ្ពស់ ប្រហែលនឹងមានការសាងសង់ផ្លូវ ការខួងដី និង ពុះជា បំណែកៗ ក្នុងស្រទាប់ដី។ ស្របពេលជាមួយគ្នានោះដែរក៏មានកម្មកររុករករ៉ែមកពីខាងក្រៅ ក្នុងទីតាំងដែល មានរ៉ែនៅភូមិទាំងពីរ។

ដូច្នេះហើយ នៅពេលដែលមានការរុករករ៉ែ មិនថានៅភូមិមួយណាទេ ដំណើរការអភិវឌ្ឍន៍រ៉ែនិង ស្រទាប់រ៉ែ សម្រាប់ផលប៉ះពាល់ កាន់តែកើនឡើង នៅពេលធ្វើអាជីវកម្មទាញយករ៉ែដែលបង្កដល់បរិស្ថាន និង សង្គមលេចឡើងកាន់តែធ្ងន់ធ្ងរ។ ទាំងនេះហើយ អាចបង្កអោយប្តូរលំនៅដ្ឋានជនជាតិដើមភាគតិចចេញពីដី សហគមន៍ និងព្រៃឈើ ការហូរចូលនៃកម្មករខ្មែរ ការទន្ទ្រានដីដើម្បីបោះទីតាំងរស់នៅ ការរីករាល នៃស្ថានភាពរស់នៅ ផ្អែកលើការប្រើប្រាស់រូបិយវត្ថុ និងបាត់បង់កេរ្តិ៍ដំណែលបរិស្ថាន។ មកទល់ សព្វថ្ងៃ អ្នកភូមិហ្គាទី និង ពូរ៉ាប៉ែត គ្មានផែនការទុកជាមុនអ្វី ដើម្បីដោះស្រាយផលលំបាកលើដំណើរការអភិវឌ្ឍន៍រ៉ែ ទាំងស្រុងឡើយ។

ខណៈនេះ សូម្បីតែស្ថិតក្នុងដំណើរការរុករករ៉ែ តាមលទ្ធផលអង្កេតគ្រួសារ នៅភូមិហ្គាទីនិង ភូមិពូរ៉ាប៉ែតបានរាយការណ៍ពីផលប៉ះអាក្រក់មកលើការប្រកបរបរចិញ្ចឹមជីវិត។ ផលប៉ះពាល់ជាទូទៅហើយ ញឹកញាប់ ដូចជា ការថយចុះផលពីការប្រមាញ់ និង ការដាក់អន្ទាក់សត្វព្រៃ ចំនួនត្រីថយចុះ ការធ្លាក់ចុះ

---

[90] ជាឧទាហរណ៍ នៅភូមិហ្គាទីមានអ្នកភូមិបាត់បង់ដើមជ័រចំនួន២៦ភាគរយ ភាគច្រើនក្នុងឆ្នាំ១៩៩៨ និង ១៩៩៩ ដោយសារតែព្រៃ សម្បទានរបស់ក្រុមហ៊ុន Samling ។ សូមមើល Evans, Tom D., Hout Piseth, Phet Phaktra and Hang Mary, *A Study of Resin-Tapping and Livelihoods in Southern Mondulkiri, Cambodia, with Implications for Conservation and Forest Management*, Phnom Penh, Wildlife Conservation Society, 2003.

[91] Eggert, “Mineral Exploration and Development: Risk and Reward.”

អនុផលព្រៃឈើនិង ការប្រមូលបន្លែបង្កា និងមានការបំផ្លាញដើមជ័រ (តារាងទី៣) ។ ផលប៉ះពាល់អាក្រក់នេះត្រូវបានរាយការណ៍ថា បានកើតមានឡើងនៅភូមិហ្គាទីច្រើនជាង ភូមិពូរ៉ាប៉ែត ពីព្រោះកន្លែងរុករករ៉ែ នៅក្បែរជាង និង ចាប់ផ្តើមប្រតិបត្តិការរុករករ៉ែមុន ។

| តារាងទី៣: ផលប៉ះពាល់ពីសកម្មភាពរ៉ែរបស់ក្រុមហ៊ុនលើការចិញ្ចឹមជីវិតតាំងពីឆ្នាំ២០០៦ ភូមិហ្គាទី និងភូមិពូរ៉ាប៉ែត ខែឧសភា ឆ្នាំ២០០៩ | | |
|---|---|---|
| | **ហ្គាទី** | **ពូរ៉ាប៉ែត** |
| **ចំនួនគ្រួសារសរុប** | **32** | **39** |
| ផលពីការប្រមាញ់ និង ដាក់អន្ទាក់សត្វព្រៃ ក្នុងភូមិថយចុះ | 20 | 13 |
| ផលនេសាទ ក្នុងភូមិថយចុះ | 18 | 10 |
| អនុផលព្រៃឈើ (ក្រៅពីជ័រទឹក) ក្នុងភូមិថយចុះ | 17 | 8 |
| បន្លែ និង ផ្លែឈើ មកពីព្រៃ នៅក្នុងភូមិថយចុះ | 13 | 8 |
| ដើមឈើសម្រាប់យកជ័រនៅក្នុងភូមិត្រូវបានបំផ្លាញ | 12 | 7 |
| ដីសហគមន៍បានគេទន្ទ្រាន | 9 | 10 |
| ដីចំការក្នុងភូមិត្រូវបានទន្ទ្រាន | 6 | 2 |
| គោ រឺក្របីក្នុងភូមិធ្លាប់រងរបួស ឬ សំលាប់ | 5 | 6 |

## រ៉ែ ជាជម្រើសនៃប្រភពចិញ្ចឹមជីវិត

អ្នករុករករ៉ែចូលរួមជាមួយក្រុមហ៊ុន ក៏បានដឹងព្រដែរថា ការអភិវឌ្ឍន៍វិស័យរ៉ែនាំមកនូវការធ្លាក់ចុះនូវការចិញ្ចឹមជីវិតតាមបែបប្រពៃណី ផ្ទុយទៅវិញ ស្ថានភាពនៃសកម្មភាពរ៉ែនេះ មិនបានផ្តល់នូវឱកាសជាជំរើសនៃការចិញ្ចឹមជីវិត សម្រាប់តបស្នងដល់អ្នកក្នុងស្រុកទេ។ ឱកាសនេះមិនទាន់កើតឡើងនៅក្នុងភូមិសិក្សាទាំងពីរឡើយ។ ភូមិហ្គាទី ក្នុងចំណោមគ្រួសារទាំង ៣២ មានតែ ៥គ្រួសារ ដែលធ្លាប់ធ្វើការអោយក្រុមហ៊ុនចិនហាយឡានដែលបាន ដំណើការ ក្នុង ឆ្នាំ២០០៦។ គ្មានគ្រួសារណាមួយក្នុងចំណោម គ្រួសារទាំង៥ នៅបន្តធ្វើការជាមួយក្រុមហ៊ុនចិនទៀតទេ ហើយក្នុងនោះមានតែ១គ្រួសារ មានគំនិតចង់ធ្វើការនេះវិញ។ ក្នុងចំណោម ២៧ គ្រួសារ ដែលមិនធ្លាប់ធ្វើការជាមួយក្រុមហ៊ុន មានតែ ៣ គ្រួសារទេ ដែលបង្ហាញពីចំណាប់អារម្មណ៍ចង់ធ្វើការអោយក្រុមហ៊ុនទៅថ្ងៃអនាគត។

ក្រៅពីធ្វើការដោយផ្ទាល់ជាមួយក្រុមហ៊ុន មាន ៤គ្រួសារ ក្នុងចំណោម ៣២គ្រួសារ នៃភូមិហ្កាទី ដែលបានធ្វើការដោយមិនផ្ទាល់តាំងពីឆ្នាំ២០០៦ ដើម្បីជួយទ្រទ្រង់ឱ្យសកម្មភាពរុករករ៉ែដូចជា ទិញលក់ទំនិញឱ្យអ្នករុករករ៉ែ ឬការងារផ្សេងទៀត។ មាន ៣ គ្រួសារ ក្នុងចំណោមគ្រួសារទាំង ៤ នោះ មានបំណងចង់ធ្វើការអោយក្រុមហ៊ុនចិនទៅថ្ងៃអនាគត។

ភូមិពូរ៉ាប៉ែត តែ ១គ្រួសារប៉ុណ្ណោះ ក្នុងចំណោម ៣៩គ្រួសារ ធ្លាប់ធ្វើការដោយផ្ទាល់ ជាមួយក្រុមហ៊ុនយករ៉ែហ្គោលមេថលដែលដំណើរការតាំងពីឆ្នាំ២០០៦។ មកដល់ពេលធ្វើការសិក្សាស្រាវជ្រាវ គ្រួសារទាំងនោះមិនបានបន្តការងារជាមួយក្រុមហ៊ុនទៀតឡើយ បើទោះជាពួកគេមានផែនការចង់ធ្វើការងារនោះវិញ។ ក្នុងចំណោមគ្រួសារផ្តល់ចំលើយទាំង ៣៨គ្រួសារ ដែលមិនធ្លាប់ធ្វើការអោយក្រុមហ៊ុនរ៉ែ មានតែ១១ គ្រួសារទេ ដែលបង្ហាញ ចំណាប់អារម្មណ៍ ចង់ធ្វើការបែបនេះទៅថ្ងៃអនាគត។

ក្រៅពីធ្វើការដោយផ្ទាល់ជាមួយក្រុមហ៊ុន មានតែ១គ្រួសារទេ ក្នុងចំណោម ៣៩គ្រួសារ ដែលបានធ្វើការដោយមិនផ្ទាល់ជាមួយក្រុមហ៊ុនតាំងពីឆ្នាំ២០០៦ ក្នុងការគាំទ្រអោយសកម្មភាពរ៉ែដូចជា ទិញលក់ ទំនិញអោយអ្នករុករករ៉ែ ឬការងារផ្សេងទៀត។ ហើយគ្រួសារនេះមានបំណងចង់ ធ្វើការអោយក្រុមហ៊ុនវិញ។ ក្នុងចំណោមគ្រួសារផ្តល់ចំលើយទាំង ៣៨គ្រួសារ ដែលមិនធ្លាប់ធ្វើការអោយក្រុមហ៊ុន មានតែ៧ គ្រួសារទេ ដែលបង្ហាញចំណាប់អារម្មណ៍ ចង់ធ្វើការបែបនេះទៅថ្ងៃអនាគត។

ទិន្នន័យបង្ហាញថា មកដល់បច្ចុប្បន្ន ក្រុមហ៊ុនរ៉ែហាយឡាន និង ក្រុមហ៊ុនហ្គោលមេថល មិនបានផ្តល់ប្រភពជម្រើសមុខរបរចិញ្ចឹមជីវិតឱ្យគ្រួសារជនជាតិដើមភាគតិច នៅភូមិហ្កាទី និងភូមិពូរ៉ាប៉ែតទេ។ នៅក្នុងភូមិទាំងពីរ មានជនជាតិដើមភាគតិចមួយចំនួនតូចប៉ុណ្ណោះ ដែលបានជួលឱ្យធ្វើការដោយ ក្រុមហ៊ុនយករ៉ែ ហើយពួកគេទាំងនោះ បានបញ្ឈប់មុនដល់ពេលធ្វើការស្រាវជ្រាវ។ ស្រដៀងគ្នានេះដែរមានជនជាតិដើមភាគតិច តិចណាស់ដែលបាន ធ្វើការ ដោយមិនផ្ទាល់ដែលគាំទ្រអោយសកម្មភាពរុករករ៉ែ ដូចជា ទិញលក់ ទំនិញអោយអ្នករុករករ៉ែ។ ក្នុងភូមិហ្កាទី អ្នកភូមិភាគច្រើនមិនចង់ធ្វើការងារនៅក្នុងសកម្មភាពយករ៉ែទេ ដោយសារពួកគេ យល់ថាជាការងារលំបាក។ ក្នុងភូមិពូរ៉ាប៉ែត ជនជាតិដើមភាគតិចមួយចំនួនចង់ធ្វើការអោយក្រុមហ៊ុនរ៉ែវៀតណាម ប៉ុន្តែពួកគេមិនត្រូវបានអនុញ្ញាតឱ្យធ្វើទេ។

ក្នុងការឆ្លើយតបនឹងលទ្ធផលរកឃើញដំបូង ប្រធានមន្ទីរឧស្សាហកម្ម រ៉ែនិងថាមពល ខេត្តមណ្ឌលគីរី បានទទូចថា អ្នកភូមិនឹងទទួលបានផលប្រយោជន៍ពីវិស័យរ៉ែ។ គាត់បានលើកឡើងថា ”ក្រុមហ៊ុនទាំងអស់កំពុងតែរុករករ៉ែ មិនទាន់ដល់ដំណាក់កាលធ្វើអាជីវកម្មឡើយ ដូច្នេះពួកគេមិនទាន់ត្រូវការកំលាំងកម្មករច្រើនទេ” ដូចនេះ ” ខ្ញុំជឿជាក់ថា វានឹងមានផលប្រយោជន៍ដោយផ្ទាល់និងមិនផ្ទាល់ដល់ប្រជាពលរដ្ឋរស់តំបន់ នៅពេលក្រុមហ៊ុន ទាំងនោះ ចាប់ផ្តើមដំណើរការអាជីវកម្ម [៩២]”។ នៅពេលធ្វើអាជីវកម្មរ៉ែ តើវានឹងផ្តល់ការងារច្រើន

[92] Nguon Sovan, “No boon from mines: survey,” *The Phnom Penh Post*, 11 September 2009.

ដល់ ប្រជាពលរដ្ឋក្នុងតំបន់ឬ? Kuntala Lahiri-Dutt បានសង្កត់ធ្ងន់នៅលើកការសន្និដ្ឋានរបស់គាត់ ក្នុងសន្និសីទអន្តរជាតិស្តីពីរ៉ែថា ខណៈពេលដែលយើងទទួលស្គាល់ថាការពង្រីកសកម្មភាពរ៉ែផ្តល់ឱកាសការងារនោះ គាត់លើកឡើងថា " ទោះជាយ៉ាងណា ការចាំបាច់នោះ ត្រូវចាំថា ភាពទំនើប មូលធនច្រើន ប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងសកម្មភាពរ៉ែ បន្ថយការផ្តល់ការងារតិចជាមុនក្នុងដំណើរការផលិតកម្ម។ ការធ្វើរ៉ែសម័យទំនើប ដំណើរការផលិតកម្មពឹងផ្អែកច្រើនលើការប្រើប្រាស់គ្រឿងម៉ាស៊ីន និង បច្ចេកវិទ្យាធុនធ្ងន់ ដែលនាំឱ្យឱកាសការងារទំនងនឹងថយចុះ [៩៣]។ ការរំពឹកញែកពីការរំពឹងទុកសម្រាប់ឱកាសការងារនៅថ្ងៃអនាគតដល់ប្រជាពលរដ្ឋក្នុងតំបន់មិនទាន់ច្បាស់នៅឡើយ ការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការទាមទារ សិទ្ធិទ្រទ្រង់ជីវភាពរបស់ជនជាតិដើមភាគតិច ក្នុងភូមិហ្គាទី និង ភូមិពូរ៉ាប៉ែត ដែលសុវត្ថិភាពក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតត្រូវធានា និង ការពារនៅគ្រប់ដំណាក់កាលនៃដំណើរការរុករកនិង ធ្វើអាជីវកម្មរ៉ែ។

[93] Lahiri-Dutt, “The People Dimension of Mining.”

# សេចក្តីសន្និដ្ឋាន

យោងទៅតាមប្រសាសន៍របស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជា បានទទួលរបកគំហើញធនធានរ៉ែ និង ការរីកចំរើនយ៉ាងឆាប់រហ័សផ្នែកឧស្សាហកម្មរ៉ែ។ ចាប់តាំងពីឆ្នាំ២០០៦ ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលបានចេញអាជ្ញាប័ណ្ណ រុករករ៉ែចំនួនជាង ១០០ នៅទូទាំងប្រទេស។ នៅក្នុងខេត្តមណ្ឌលគិរី មុនមានការដកចេញរបស់ក្រុមហ៊ុន BHP Billiton និង Mitsubishi Corporation នៅឆ្នាំ ២០០៩ មានក្រុមហ៊ុនរ៉ែចំនួន ១៥ ដែលកាន់កាប់អាជ្ញាប័ណ្ណ ដើម្បីធ្វើការរុករកលើផ្ទៃដី ៤ ៤៧៣ គ.ម² ឬ ៣១ ភាគរយនៃផ្ទៃដីខេត្ត ១៤ ២៨៨ គ.ម²។ ថ្វីត្បិតតែ ធនធានរ៉ែអាចនឹងបង្កើតប្រាក់ចំណូលយ៉ាងច្រើន សម្រាប់រដ្ឋាភិបាលក្តី ការបង្កការខូចខាតបណ្តាលមកពីការពង្រីកសកម្មភាពរ៉ែ នាំមកនូវការគំរាមគំហែងដល់បរិស្ថាននិងសុខុមាលភាពសហគមន៍មូលដ្ឋាន ដែលជាពិសេស ក្រុមជនជាតិដើមភាគតិច។ ដូច្នេះសំនួរដែលចោទសួរក្នុងចំនុចផ្តើមនៃការសិក្សានេះ ថាតើការកើតលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យឧស្សាហកម្មរ៉ែនៅកម្ពុជានឹងរួមចំណែកដល់ការអភិវឌ្ឍន៍មូលដ្ឋានសេដ្ឋកិច្ចរបស់ប្រទេសបានទូលំទូលាយ ឬផ្តល់ផលប្រយោជន៍សម្រាប់តែម្ចាស់ក្រុមហ៊ុនបរទេស និងក្រុមអ្នកមាននៅក្នុងប្រទេស ក្នុងខណៈដែលមានការខាតបង់តំបន់ជីវចំរុះនិង ការផ្លាស់ប្តូរលំនៅដ្ឋានរបស់អ្នកស្រុកក្នុងតំបន់? ចម្លើយចំពោះសំនួរនេះមានសារៈសំខាន់ណាស់ដល់ការរស់នៅរបស់ ក្រុមជនជាតិដើមភាគតិច ដូចជាពួងដែលនៅភូមិហ្គាទី និងភូមិពូរ៉ាប៉ែតស្រុកកែវសីមានិង ស្រុកពេជ្រាដា។ ទោះបី វាស្ថិតនៅក្រៅក្របខណ្ឌនៃការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់ចម្លើយដល់បញ្ហានេះក៏ដោយ ការសិក្សាស្រាវជ្រាវនេះនឹងរួមចំណែកក្នុងការពិភាក្សា តាមរយៈការលើកកំពស់ចំណេះដឹងពីបញ្ហាផ្សេងៗ ទាក់ទងនឹង សកម្មភាពរ៉ែនិង សិទ្ធិជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគិរី។

សន្និសីទអន្តរជាតិស្តីពីរ៉ែកាលពីខែឧសភា ឆ្នាំ២០១០ ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅភ្នំពេញមានសារៈសំខាន់ណាស់ក្នុងការផ្តល់វេទិកាពិភាក្សាអំពី ការធ្វើសកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវ ដល់មន្ត្រីរដ្ឋាភិបាលកម្ពុជា តំណាងក្រុមហ៊ុនសាជីវកម្ម អ្នកពិគ្រោះយោបល់ និងអ្នកសិក្សាអំពីរ៉ែ។ ជារួម បទបង្ហាញក្នុងសន្និសីទបានផ្តល់ក្របខណ្ឌមួយយ៉ាងទូលំទូលាយ និងលំអិតសម្រាប់ធ្វើអោយមានការធ្វើសកម្មភាពរ៉ែមួយប្រកបដោយទំនួលខុសត្រូវ។ សុន្ទរកថាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឯកឧត្តមរដ្ឋមន្ត្រី ស៊ុយ សែម ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និង ឯកឧត្តម សុខ ឡេង បង្ហាញនូវការយល់ដឹងយ៉ាងច្បាស់លើបញ្ហារ៉ែ និងការប្តេជ្ញាចិត្ត ដូចដែលបានបញ្ជាក់យ៉ាងច្បាស់ដោយឯកឧត្តម ស៊ុយ សែម ថា" ត្រូវលុបបំបាត់រាល់បញ្ហាលំបាកដែលមាន"។

## ការខ្វះចន្លោះនៃច្បាប់រ៉ែឆ្នាំ ២០០១

ការវិនិយោគលើវិស័យរ៉ែរបស់ប្រទេសកម្ពុជា ត្រូវបានគេធ្វើយ៉ាងឆាប់រហ័ស តាមរយៈការប្រកាសអោយប្រើប្រាស់ច្បាប់រ៉ែឆ្នាំ ២០០១ ដោយរាជរដ្ឋាភិបាលកម្ពុជា។ ទោះបីជាយ៉ាងណា ច្បាប់រ៉ែនៅមានចន្លោះប្រហោងនៅឡើយ។ លក្ខខណ្ឌសម្រាប់ផ្តល់សម្បទានរ៉ែ នៅខ្វះភាពមិនច្បាស់លាស់ និងក្របខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណរ៉ែនៅមិនទាន់ពេញលេញនៅឡើយ។ ដូចគ្នាទៅនឹងការរក្សាការសម្ងាត់នៅជុំវិញការផ្តល់សម្បទាន និងអាជ្ញាប័ណ្ណរ៉ែដែរ ការចំណាយផ្សេងៗ លើកិច្ចព្រមព្រៀង នាំឱ្យមានកង្វល់អំពីកង្វះតម្លាភាពនិង ការបើកចំហរជាសាធារណៈ។ បញ្ហាទាំងនេះនៅតែមានរហូតទាល់តែរដ្ឋាភិបាលរៀបចំប្រព័ន្ធមួយដែលបើកចំហរជាសាធារណៈនូវរាល់ចំណូលទាំងឡាយពីឧស្សាហកម្មរ៉ែ។ ដូច្នេះការខ្វះតម្លាភាព និងទំនួលខុសត្រូវជាសាធារណៈក្នុងវិស័យរ៉ែ ត្រូវតែគិតគូរនៅក្នុងក្របខណ្ឌច្បាប់។ ច្បាប់រ៉ែធានាការសំងាត់លើរាល់ឯកសារនិង ព័ត៌មានផ្សេងៗ ដែលការនេះជាឧបសគ្គដល់អ្នកត្រួតពិនិត្យឯករាជ្យលើវិស័យឧស្សាហកម្មនេះ។ ផ្ទុយទៅវិញ ច្បាប់ឆ្នាំ១៩៩៦ ស្តីពីកិច្ចការពារបរិស្ថាន និង គ្រប់គ្រងធនធានធម្មជាតិ ដែលគ្របដណ្តប់ផងដែរពីសកម្មភាពរ៉ែមានការគិតគូរទៅលើតម្លាភាព និងគណនេយ្យភាព។

## សិទ្ធិជនជាតិដើមភាគតិច

ប្រទេសកម្ពុជា រួមជាមួយនឹងរដ្ឋសមាជិកចំនួន ១៤២ប្រទេសទៀត បានបោះឆ្នោតអនុម័ត*សេចក្តីប្រកាសរបស់សហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច* នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៧។ ការបោះឆ្នោតគាំទ្រសេចក្តីប្រកាសនេះដោយកម្ពុជា គឺជាជំហានទៅមុខមួយយ៉ាងសំខាន់ បង្ហាញនូវឆន្ទៈនិងការទទួលស្គាល់ក្នុងការការពារសិទ្ធិជនជាតិដើមភាគតិច។ សេចក្តីប្រកាសនេះទទួលស្គាល់ជនជាតិដើមភាគតិចមានសិទ្ធិស្វ័យសំរេច ធ្វើការសំរេចអាទិភាពលើការអភិវឌ្ឍន៍ផ្ទាល់ខ្លួន ការគ្រប់គ្រងដីធ្លី ដែនដី និងធនធាន មានសិទ្ធិក្នុងការយល់ព្រម ដោយសេរី និងប្រាប់អោយដឹងជាមុន លើការអភិវឌ្ឍន៍ទាំងឡាយ ការប្រើប្រាស់និងការធ្វើអាជីវកម្មលើ ធនធានរ៉ែ និង មានសិទ្ធិទទួលបានសំណងពីការប្រើប្រាស់មិនបានត្រឹមត្រូវលើធនធានទាំងនោះ។ សិទ្ធិដែលមាន ចែងក្នុងច្បាប់អន្តរជាតិសម្រាប់ការធ្វើសកម្មភាពប្រកបដោយការទទួលខុសត្រូវជាមួយក្រុមជនជាតិគឺថាផ្តល់ការយល់ព្រមដោយសេរីនិងប្រាប់ឱ្យដឹងជាមុន ដែលនេះជាគោលការចាំបាច់សម្រាប់ការអនុម័តយល់ព្រមលើគម្រោងដែលមានការប៉ះពាល់ដល់ដី និងធនធានរបស់គេ។

*ច្បាប់ភូមិបាល* ឆ្នាំ២០០១ ផ្តល់នូវក្របខណ្ឌគតិយុត្តិសម្រាប់ការទទួលស្គាល់សិទ្ធិ គ្រប់គ្រងដីធ្លីរបស់ក្រុមជនជាតិដើមភាគតិច។ ច្បាប់នេះអនុញ្ញាតអោយសហគមន៍ជនជាតិដើមភាគតិចមានកម្មសិទ្ធិសមូហភាពលើដីជា ប្រពៃណីរបស់គេ ដែលបានកំណត់ដូចជា ដីលំនៅដ្ឋាន ដីកសិកម្ម និងដីបំរុងទុកសម្រាប់ចំការវិលជុំ។ លើសពីនេះ ច្បាប់ភូមិបាលការពារសិទ្ធិប្រើប្រាស់ និងគ្រប់គ្រងដីជាប្រពៃណីរបស់ជនជាតិដើមភាគតិច សូម្បី

មុនសិទ្ធិកម្មសិទ្ធិត្រូវបានទទួលស្គាល់ជាផ្លូវការ តាមរយៈការផ្តល់កម្មសិទ្ធិសមូហភាពក៏ដោយ (មាត្រា២៣)។ ដូច្នេះហើយការលក់ដីជនជាតិដើមភាគតិច ក្រៅរង្វង់សហគមន៍ ដោយគិតចាប់តាំងពីចេញច្បាប់ភូមិបាលមក ត្រូវចាត់ទុកថា ជាអំពើខុសច្បាប់។ អង្គការមិនមែនរដ្ឋាភិបាលបានលើកឡើងថា អាជ្ញាប័ណ្ណរុករករ៉ែលើដីរបស់ជនជាតិដើមភាគតិច គឺជាអំពើខុសច្បាប់ ប្រសិនបើរារាំងដល់លទ្ធភាពរបស់ សហគមន៍បន្តគ្រប់គ្រងដីធ្លីតាមលក្ខណៈប្រពៃណី។ បញ្ហាទាក់ទងនឹងនិតិវិធីក្នុងដំណើរការផ្តល់កម្មសិទ្ធិរួមដែលទាក់ទងនិងច្បាប់ភូមិបាល និងត្រូវបំភ្លឺក្នុងអនុក្រិត្យមួយ។ ទោះបីជាមានការចាប់ផ្តើមយ៉ាងល្អក្តី ដំណើរការនៃការធ្វើសេចក្តីព្រាង និង អនុម័តអនុក្រិត្យស្តីពី*និតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច*ត្រូវបានផ្អាក។ នៅទីបំផុតអនុក្រិត្យមួយដែល មិនជាទីពេញចិត្តត្រូវបានអនុម័ត នៅខែមិថុនា ឆ្នាំ២០០៩។

## ការពង្រីកសកម្មភាពរ៉ែ នៅភូមិហ្គាទី និងភូមិពូរ៉ាប៉ែត

ជនជាតិព្នងនៅភូមិហ្គាទី និងភូមិពូរ៉ាប៉ែត គិតថា តំបន់សម្រាប់ធ្វើការរុករករ៉ែគឺជាកន្លែងស័ក្តិសិទ្ធ។ សកម្មភាពរ៉ែបានចាប់ផ្តើម នៅពេលដែលចំណាកស្រុករករ៉ែជាជនជាតិខ្មែរចូលមក ភូមិហ្គាទី នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ និង ភូមិពូរ៉ាប៉ែត នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០។ ការហូរចូលនូវអ្នកចំណាកស្រុកជនជាតិខ្មែរជាបន្តបន្ទាប់ ដោយមានទាំងសំភារៈនិងបច្ចេកទេសទំនើប ធ្វើឱ្យឆាប់ខ្សត់ធនធានរ៉ែមាសនៅស្រទាប់ដីខាងលើ ហើយមកត្រឹមដើមពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០និងជាពេលដែលចំនួនសិប្បករធនធានរ៉ែដែលឯករាជ្យ ធ្លាក់ចុះទៅវិញនៅភូមិទាំងពីរ។

ក្នុងឆ្នាំ២០០៦ ក្រុមហ៊ុនចិន ហាយឡាន បានចាប់ផ្តើមសកម្មភាពរុករករ៉ែនៅភូមិហ្គាទី។ នៅឆ្នាំ២០០៧ នៅពេលដែលបុគ្គលិកក្រុមហ៊ុនចិនបាន ដឹកសំភារៈ និងកម្មករ ពេញរថយន្តចូលទៅកន្លែងរុករករ៉ែ អ្នកភូមិជនជាតិព្នងបានបញ្ឈប់ដំណើររបស់ក្រុមហ៊ុន។ អ្នករុករករ៉ែជនជាតិចិនក៏បានប្រាប់អ្នកភូមិវិញថាពួកគេមានអាជ្ញាប័ណ្ណមកពីរដ្ឋាភិបាល ដើម្បី រុករករ៉ែមាសនៅតំបន់នេះ។ នៅពេលដែលជនជាតិព្នងប្រឈមបញ្ហានេះជាមួយអាជ្ញាធររដ្ឋបាលនៅមូលដ្ឋាន ទើបពួកគេដឹងថា ការអនុញ្ញាតនេះចេញពីថ្នាក់ជាតិ ដែលពួកគេមិនមានជំរើស ទើបសំរបអោយក្រុមហ៊ុន បន្តដំណើរប្រតិបត្តិការ។

នៅឆ្នាំ ២០០៦ ក្រុមហ៊ុនវៀតណាម ហ្គោលមេថលគ្រុបក៏ចាប់ផ្តើម ប្រតិបត្តិការរ៉ែនៅភូមិពូរ៉ាប៉ែត។ ក្រុមហ៊ុនបានប្រើសិទ្ធិទាំងស្រុងក្នុងការធ្វើសកម្មភាពរ៉ែនៅក្នុងតំបន់ ហើយអ្នកជីករ៉ែផ្ទាល់ខ្លួនទាំងអស់ត្រូវបង្ខំអោយចាកចេញពីតំបន់។ ក្រោយមក ក្រុមហ៊ុនបានព័ទ្ធរបងលើផ្ទៃដីប្រហែល ១ គ.ម$^2$. ហើយបានសាងសង់ជំរុំដើម្បីធ្វើសកម្មភាពរ៉ែនៅទីនោះ។ នៅក្នុងជំរុំនោះគឺជាជំរកស្នាក់នៅរបស់កម្មករជនជាតិវៀតណាម និងសម្រាប់ ទុកឧបករណ៍ធុនធ្ងន់របស់ក្រុមហ៊ុន។ បុគ្គលិកក្រុមហ៊ុនមានទំនាក់ទំនងតិចតួចជាមួយអាជ្ញាធរឃុំ

ក្រុងតេះ និងថ្នាក់ដឹកនាំភូមិពូរ៉ាប៉ែត ហើយមិនធ្លាប់បានប្រាប់អ្នកភូមិឱ្យចូលរួមកិច្ចប្រជុំផ្លូវការជាសាធារណៈ ដើម្បីប្រាប់ដំណឹងពីសកម្មភាពរបស់ពួកគេទេ។

ជនជាតិព្នងនៅភូមិហ្គាទី និង ភូមិពូរ៉ាប៉ែត មិនបានទទួលនូវសិទ្ធិ ផ្តល់ការយល់ព្រមដោយសេរី និង ប្រាប់អោយដឹងជាមុន ក្នុងការធ្វើប្រតិបត្តិការរ៉ែក្នុងភូមិរបស់គេទេ។ អ្នកភូមិហ្គាទីខ្លះត្រូវបានគេជំរាបអំពី សកម្មភាពជីករ៉ែ របស់ក្រុមហ៊ុនហាយឡាន ប៉ុន្តែគ្រាន់តែធ្វើឡើងបន្ទាប់ពីក្រុមហ៊ុនចូលមកដល់ និង បាន ចាប់ផ្តើមប្រតិបត្តិការក្នុងភូមិប៉ុណ្ណោះ។ អង្គការមិនមែនរដ្ឋាភិបាលដូចជា WCS និង DPA មានកម្មវិធីនៅ ភូមិហ្គាទី ហើយជួយបង្កើនការយល់ដឹងស្តីពីសិទ្ធិជនជាតិដើមភាគតិច និងជួយសម្របសម្រួលការប្រជុំរវាង អ្នកភូមិ និងក្រុមហ៊ុន។ ជាទូទៅ អ្នកភូមិពូរ៉ាប៉ែត មិនបានទទួលព័ត៌មានអំពីសកម្មភាពក្រុមហ៊ុនហ្គោលមេថល គ្រុប មុនពេលឬ បន្ទាប់ពីក្រុមហ៊ុនបានចាប់ផ្តើមប្រតិបត្តិការរ៉ែក្នុងភូមិទេ។ មិនដូចនៅភូមិហ្គាទីឡើយ អាជ្ញាធរ ភូមិពូរ៉ាប៉ែត និង អ្នកភូមិមិនមានទំនាក់ទំនងជាមួយក្រុមហ៊ុន និង មិនអាចចូលទៅដល់តំបន់រ៉ែឡើយ។

## សកម្មភាពរ៉ែ និងការប្រកបរបរចិញ្ចឹមជីវិតនៅភូមិហ្គាទី និងភូមិពូរ៉ាប៉ែត

គ្រួសារជនជាតិព្នងនៅភូមិហ្គាទី និង ភូមិពូរ៉ាប៉ែត បានធ្វើចំណាត់ថ្នាក់ ទៅលើការប្រមូល ផលដំណាំ កសិកម្ម ការដងជ័រទឹក និង ការប្រមូលអនុផលព្រៃឈើផ្សេងៗ ជាប្រភពរបរចិញ្ចឹមជីវិតសំខាន់បំផុតកាល ពីឆ្នាំកន្លងទៅ។ នេះជាការបង្ហាញឱ្យឃើញពីសារសំខាន់នៃធនធានធម្មជាតិសម្រាប់ជីវភាពរស់នៅក្នុងគ្រួសារ និង លទ្ធភាពគំរាមកំហែងដោយសារការពង្រីកសកម្មភាពរ៉ែ។ ជារួម ស្ថានភាពសន្តិសុខស្បៀងសម្រាប់ ការចិញ្ចឹមជីវិត របស់ជនជាតិដើមភាគតិចនៅក្នុងភូមិហ្គាទី និងភូមិពូរ៉ាប៉ែត គឺបានត្រឹមសម្រាប់បំពេញក្រពះ តែប៉ុណ្ណោះ។ មកដល់ពេលនេះ ការរុករករ៉ែនៅភូមិទាំងពីរ មិនទាន់បង្កផលប៉ះពាល់អ្វីធ្ងន់ធ្ងរដល់ការចិញ្ចឹមជីវិត របស់គ្រួសារក្នុងភូមិទេ ហើយដំណាក់កាលបច្ចុប្បន្ននេះ សកម្មភាពរ៉ែក៏មិនទាន់មានការវិវត្តអ្វីគួរឱ្យភ្ញាក់ផ្អើល ខ្លាំងដែរ។ ទោះជាយ៉ាងណា ដំណើរការរុករករ៉ែ ចេញពីដំណាក់កាលដំបូង និងជាបន្តបន្ទាប់ទៀត ព្រមទាំង ដំណាក់កាលត្រៀមនិងចាប់ផ្តើមប្រតិបត្តិការ ផលប៉ះពាល់ខ្លាំងដល់បរិស្ថាននិងសង្គមមិនអាចជៀសផុតឡើយ។

តាមលទ្ធផលអង្កេតគ្រួសារ មកត្រឹមដំណាក់កាលនៃការរុករករ៉ែនេះ មានការប៉ះពាល់ច្រើនពី សកម្មភាពរ៉ែដល់ការចិញ្ចឹមជីវិតដូចជា សត្វព្រៃសម្រាប់ប្រម៉ាញ់និងដាក់អន្ទាក់ ការធ្លាក់ចុះធនធានត្រីដែល ប្រមូលបាន ផលិតផលព្រៃឈើ បន្លែ និងការប្រមូលផ្លែឈើ និង ការធ្លាក់ចុះនូវជ័រសម្រាប់ដង។ ក្នុងពេល ដូចគ្នានេះដែរ ក្រុមហ៊ុនជីករ៉ែមិនបានផ្តល់ជំរើសចិញ្ចឹមជីវិត លាភសក្ការៈ និងការងារដល់អ្នករស់នៅក្នុងតំបន់ ឡើយ។ ការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការទាមទារ សិទ្ធិទ្រទ្រង់ជីវភាព របស់ជនជាតិដើមភាគតិច ក្នុងភូមិហ្គាទី និង ភូមិពូរ៉ាប៉ែតអាចកើតឡើងទៅបានអាស្រ័យលើការធានា និងការពារនៅគ្រប់ដំណាក់កាល នៃដំណើរការ រុករកនិង ធ្វើអាជីវកម្មរ៉ែ។

## កត្តាប្រឈមក្នុងការលើកកំពស់សកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវនៅកម្ពុជា

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបង្ហាញយ៉ាងច្បាស់ថា គ្រឹះរឹងមាំសម្រាប់សកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវនៅកម្ពុជា គឺអាស្រ័យលើការអនុវត្តយ៉ាងហ្មត់ចត់នូវក្របខណ្ឌបទបញ្ញត្តិ [៩៤]។ ក្រុមហ៊ុនរ៉ែបស្ចឹមប្រទេសដែលមានសមាជិកច្រើនជាងគេនៅក្នុងសមាគមកម្ពុជាសម្រាប់ក្រុមហ៊ុនរុករកនិងធ្វើអាជីវកម្មរ៉ែ បានអនុម័តនូវគោលការណ៍នេះ តែបច្ចុប្បន្ននេះ ក្រុមហ៊ុនរ៉ែបស្ចឹមប្រទេសមានចំនួនតិច ធៀបនិង ក្រុមហ៊ុនធំៗ ដែលកំពុងធ្វើសកម្មភាពរ៉ែនៅកម្ពុជា។ នៅពេលនេះដែរក្រុមហ៊ុនចិន វៀតណាម និងកូរ៉េ ដែលមិនសូវគិតពីការធ្វើកំណែទម្រង់និងទទួលអាជ្ញាប័ណ្ណសង្គមសម្រាប់ប្រតិបត្តិការ ក្រុមហ៊ុនទាំងនេះនឹងអនុលោមតាមបទដ្ឋានដែលត្រូវជម្រុញការអនុវត្ត យ៉ាងតឹងតែងដោយរដ្ឋាភិបាល។ បញ្ហានេះតម្រូវឱ្យរដ្ឋាភិបាលមានឆន្ទៈនយោបាយដើម្បីអនុវត្ត។ ការទទួលស្គាល់នូវបរិស្ថានដែលមានបទបញ្ញត្តិរឹងមាំសម្រាប់ ទាក់ទាញការវិនិយោគ អាចនឹងលើកទឹកចិត្តរដ្ឋាភិបាលពង្រឹងទិសដៅនេះកាន់តែខ្លាំងឡើង។ សង្គមស៊ីវិលអាចធ្វើការដើម្បីផ្លាស់ប្តូរតាមរយៈសកម្មភាពនិងការទាមទារ និងផ្លាស់ប្តូរគោលនយោបាយតាមរយៈការតស៊ូមតិនិង ការបញ្ចុះបញ្ចូល។ បណ្តាញសង្គមស៊ីវិលដូចជា កម្ពុជាសម្រាប់តម្លាភាពចំណូលធនធាន (CRRT) និងបណ្តាញផលប៉ះពាល់សង្គម និងបរិស្ថានដោយឧស្សាហកម្មនិស្សារណៈកម្ម (EISEI) ជាតំណាងស្ថាប័នយ៉ាងសំខាន់ ទោះបីជាក្រុមនេះតម្រូវឱ្យមានសមាជិកភាពកាន់តែច្រើនចូលរួម ដើម្បីបង្កើនឥទ្ធិពលលើការអភិវឌ្ឍន៍ឧស្សាហកម្មរ៉ែនៅប្រទេសកម្ពុជា។ មេរៀនគំរូសម្រាប់កម្ពុជា គឺការផ្តួចផ្តើមគំនិតពហុភាគីសម្រាប់សកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវ នៅប្រទេសម៉ុងហ្គោលី បង្ហាញនៅក្នុងសន្និសីទអន្តរជាតិស្តីពីរ៉ែ និងបានពិពណ៌នានៅក្នុងសេចក្តីផ្តើមនៃរបាយការណ៍នេះស្រាប់ដែលបង្ហាញថា តំណាងរដ្ឋាភិបាល ឧស្សាហកម្មរ៉ែ និងសង្គមស៊ីវិលដែលធ្វើការរួមគ្នា ដើម្បីលើកកំពស់ និងអនុវត្តការធ្វើអាជីវកម្មរ៉ែប្រកបដោយទំនួលខុសត្រូវ។

ករណីសិក្សានៅភូមិហ្គាទី និង ភូមិពូរ៉ាប៉ែត ក្នុងខេត្តមណ្ឌលគិរី បានបង្ហាញអោយឃើញយ៉ាងស៊ីជំរៅលើបញ្ហាប្រឈមរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តនេះ ដែលបណ្តាលមកពីការពង្រីកសកម្មភាពរ៉ែរបស់ក្រុមហ៊ុនធំៗ នៅលើដីកេរ្តិ៍ពីដូនតារបស់ពួកគេ។ តាមការពិតច្បាប់រ៉ែដែលមានស្រាប់ឆ្នាំ ២០០១ មិនបានផ្តល់នូវក្របខណ្ឌច្បាប់គ្រប់គ្រាន់សម្រាប់ធ្វើការដោះស្រាយបញ្ហានៃសកម្មភាពរ៉ែប្រកបដោយ ទំនួលខុសត្រូវក្នុងតំបន់ជនជាតិដើមភាគតិចនោះទេ។ ដូច្នេះក្របខណ្ឌច្បាប់ថ្នាក់ជាតិទូលំទូលាយត្រូវតែរៀបចំឡើង និងអនុវត្តមុនពេលក្រុមហ៊ុនធ្វើការចូលមករុករកនិង ធ្វើអាជីវកម្មរ៉ែទ្រង់ទ្រាយធំ នៅតំបន់កុលសម្ព័ន្ធភ្នំ ព្រោះថាវប្បធមិ នៃការទ្រទ្រង់ជីវិតរបស់ជនជាតិដើមភាគតិចព្នងនៅខេត្តមណ្ឌលគិរី គឺស្ថិតក្នុងការគំរាមកំហែង។ ការ

[94] This section draws on discussions that took place during a semiar on socially responsible mining convened by the Heinrich Boll Foundation on 21 October 2010 in Phnom Penh.

ទទួលស្គាល់ និងការការពារសិទ្ធិជនជាតិដើមភាគតិច ដែលជាគោលការណ៍មួយដ៏ឧត្តម សម្រាប់សកម្មភាពរ៉ែ ប្រកបដោយការទំនួលខុសត្រូវ មិនអាចពន្យាពេលបានឡើយ ។

# អនុសាសន៍សម្រាប់គោលនយោបាយ

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវជាក់ស្តែង និង ភាពចាំបាច់ដែលកម្ពុជាត្រូវធ្វើ ក្នុងការការពារ និង ធានាសិទ្ធិជនជាតិដើមភាគតិច និងការស្វែងរក និងរៀបចំគោលការណ៍សកម្មភាពរ៉ែប្រកបដោយទំនួលខុសត្រូវ អ្នកសិក្សាស្រាវជ្រាវសូមលើកឡើងនូវយោបល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- ច្បាប់ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែគួរតែធ្វើវិសោធនកម្ម ដោយមានបន្ថែមគោលការណ៍ នៃការយល់ព្រមដោយសេរី និងប្រាប់អោយដឹងជាមុនដល់ ជនជាតិដើមភាគតិច ។
- ក្របខណ្ឌច្បាប់ថ្នាក់ជាតិដែលណែនាំអំពីឧស្សាហកម្មធនធានរ៉ែ គួរតែកែសម្រួល ដោយផ្អែកលើបទដ្ឋានអន្តរជាតិសម្រាប់សកម្មភាពរ៉ែដែលមានទំនួលខុសត្រូវ និង គោលការណ៍របស់ស្ថាប័នគំនិតផ្តួចផ្តើម ដើម្បីតម្លាភាពនៃឧស្សាហកម្មនិស្សារណៈកម្ម (EITI) ។
- គួរតែបញ្ឈប់ការផ្តល់អាជ្ញាប័ណ្ណរុករក និងដកហូតធនធានរ៉ែ នៅតាមតំបន់ជនជាតិដើមភាគតិច ក្នុងខេត្តមណ្ឌលគីរី រហូតដល់ក្របខណ្ឌច្បាប់ត្រូវបានធ្វើឡើងចប់សព្វគ្រប់ ។
- សកម្មភាពរ៉ែក្នុងភូមិហ្គាទី និង ពូរ៉ាប៉ែតគួរតែបញ្ឈប់សិន រហូតដល់ដំណើរចុះប័ណ្ណកម្មសិទ្ធិដីសមូហភាពបានរួចរាល់ ។
- សមាគមកម្ពុជាសម្រាប់ក្រុមហ៊ុនរុករក និងធ្វើអាជីវកម្មរ៉ែ (CAMEC) កម្ពុជាសម្រាប់តម្លាភាពចំណូលធនធាន (CRRT) និង បណ្តាញផលប៉ះពាល់សង្គមនិងបរិស្ថានដោយឧស្សាហកម្មនិស្សារណៈកម្ម (EISEI) និងរដ្ឋាភិបាលគួរតែស្វែងរកមធ្យោបាយក្នុងការរៀបចំការផ្តួចផ្តើមគំនិតសម្រាប់សកម្មភាពរ៉ែដែលមានទំនួលខុសត្រូវ ដោយមានការចូលរួមពីពហុភាគី ដូចដែលមានការរៀបចំនៅក្នុងប្រទេសម៉ុងហ្គោលីស្រាប់ ។

## ឧបសម្ព័ន្ធ១៖ អ្នកស្រាវជ្រាវជាសិក្ខាកាម និងក្រុម អេឌីអាយ

### អ្នកស្រាវជ្រាវជាសិក្ខាកាម អេឌីអាយ

| | |
|---|---|
| កែវ តៃ | អង្គការ អភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (CED) |
| កែវ សំណាង | អង្គការ ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT) |
| សៀង ឈូក | អង្គការ សសរទ្រូង (SST) |
| សម សារិន | អង្គការ សមាគមអាដហុក (ADHOC) |
| ញាណ សុផូ | អង្គការ ភូមិខ្ញុំ (MVI) |
| ធី ទ្រី | អង្គការ អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) |
| ឯម សុភ័ក្រ្ត | អង្គការ មជ្ឈមណ្ឌលអប់រំ ច្បាប់សម្រាប់សហគមន៍ (CLEC) |
| ប៉ែន រតនា | អង្គការ មូលនិធិហេនរិចបូល ស្ទីហ្វទុងកម្ពុជា (HBS) |
| ហេង សុហ៊ាញ | អង្គការ ទស្សនៈពិភពលោកកម្ពុជា (WVI) |
| ថន ប៊ុនលី | អង្គការ សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) |
| ឆាយ គឹមហ៊ាក | អង្គការ សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) |
| ចាន់ រ៉ាមី | អង្គការ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) |
| ផាន ស៊ីណេត | អង្គការ បណ្តាញមូលនិធិសហគមន៍កម្ពុជា ស៊ីហ្វីន (CCFin) |
| ជុំ ឈាន | អង្គការ អនុផលព្រៃឈើ (NTFP) |
| ឡាំ សួត | អង្គការ អនុផលព្រៃឈើ (NTFP) |

### អ្នកស្រាវជ្រាវក្រុមអេឌីអាយ

| | |
|---|---|
| ហាក់ សុចន្ទី | គណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា/គម្រោង អេឌីអាយ |
| ជេន សុជឿន | គណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា/គម្រោង អេឌីអាយ |
| ហ៊ួន កល្យាណ | គណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា/គម្រោង អេឌីអាយ |
| សូ ដាណេ | គណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា/គម្រោង អេឌីអាយ |
| ឃួន ចាន់ដូរេ | គណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា/គម្រោង អេឌីអាយ |
| ចន ម៉ាកខាន់ដ្រូ | គណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា/គម្រោង អេឌីអាយ |

## បញ្ជីឯកសារស្រាវជ្រាវកន្លងមករបស់គម្រោងអេឌីអាយ

**ADI Research Studies**
(www.ccc-cambodia-org)

- ការប្រើប្រាស់ធនធានធម្មជាតិៈ ករណីសិក្សាក្រុមកុលសម្ព័ន្ធកម្ពុជា ដី និងវប្បធម៌នៃការចិញ្ចឹមជីវិតៈ សិទ្ធិលើដីសមូហភាពរបស់ជនជាតិដើមភាគតិចនៅអាស៊ី ធានាគារអភិវឌ្ឍន៍អាស៊ីៈ ឆ្នាំ២០០៩
- ការចរចាទំនាស់ដីធ្លីនៅក្នុងភូមិជនជាតិដើមភាគតិចក្នុងខេត្តរតនគីរី និន្នាការថ្មីៗ ការប្រឈមមុខនិង ការកើតឡើងថ្មីៗ វិទ្យាស្ថានសិក្សាធនធានធម្មជាតិនៅសហគមន៍ៈ លើកទី២ ឆ្នាំ២០០៩
- ចលនាអ្នកភូមិ ដើម្បីទប់ស្កាត់នឹង ការនេសាទខុសច្បាប់នៅតាមដងទន្លេស្រែពក ក្នុងខេត្តរតនគីរី និន្នាការថ្មីៗ ការប្រឈមមុខនិង ការកើតឡើងថ្មីៗ វិទ្យាស្ថានសិក្សាធនធានធម្មជាតិនៅសហគមន៍ៈ លើកទី២ ឆ្នាំ២០០៩
- ការលក់ដូរដើម្បីរស់ៈ អ្នកលក់ដូរខ្នាតតូចនៅក្នុងទីរួមខេត្តកំពង់ចាម ប្រកបរបរចិញ្ចឹមជីវិតនៅក្នុង សេដ្ឋកិច្ចក្រៅប្រព័ន្ធៈ ខែវិច្ឆិកា ឆ្នាំ ២០០៨
- ការផ្តល់បណ្ណ័កម្មសិទ្ធដីធ្លី និងការកាត់បន្ថយភាពក្រីក្រ ៈ ការសិក្សាលើសង្កាត់ពីរ នៃខណ្ឌព្រៃនប់ ក្រុងព្រះសីហនុៈ ខែវិច្ឆិកា ឆ្នាំ២០០៧
- យល់ដឹងអំពីធនធានសង្គមដើម្បីឆ្លើយតបទៅនឹងគ្រោះរាំងស្ងួត និង ទឹកជំនន់ ៈ ការសិក្សាទៅលើភូមិ ចំនួន ៥ ក្នុងតំបន់ភូមិសាស្ត្រពីរផ្សេងគ្នានៅក្នុងខេត្តកំពង់ធំ ៈ ខែសីហា ឆ្នាំ២០០៧
- ការវិវត្តន៍ទៅកាន់វ័យចាស់ជរារបស់ពលរដ្ឋ នៅក្នុងអតីតមូលដ្ឋានដ៏រឹងមាំមួយរបស់ខ្មែរក្រហមៈ ការស្រាវជ្រាវនៅក្នុងសង្កាត់ពីរ នៅក្នុងទីក្រុងប៉ៃលិនៈ ខែវិច្ឆិកា ឆ្នាំ២០០៦
- ការប្រឈមមុខ ក្នុងការរស់នៅរបស់ជនពិការ នៅតំបន់ជនបទ ក្នុងប្រទេសកម្ពុជាៈ ការសិក្សា ស្រាវជ្រាវ អំពីជនពិការដែលមានបញ្ហាបំលាស់ទីនៅក្នុងបរិបទសង្គម ស្រុកព្រៃវែង ខេត្តព្រៃវែងៈ ខែមីនា ឆ្នាំ២០០៦
- ឥទ្ធិពលនៃឧស្សាហកម្មកាត់ដេរ ទៅលើជីវភាពរស់នៅ នៅតំបន់ជនបទៈ បទពិសោធន៍ដែលទទួលបាន ពីកម្មករកាត់ដេរ និងគ្រួសារនៅជនបទ ក្នុងខេត្តព្រៃវែងៈ ខែតុលា ឆ្នាំ២០០៥
- អំពើហឹង្សាក្នុងគ្រួសារនៅក្នុងតំបន់តាំងទីលំនៅថ្មីជាយដែន នៅប៉ោយប៉ែតដែលមានកំណើនមនុស្ស យ៉ាងឆាប់រហ័សៈ ការស្រាវជ្រាវនៅក្នុងភូមិពីរ ក្នុងឃុំប៉ោយប៉ែត ខេត្តបន្ទាយមានជ័យៈ ខែឧសភា ឆ្នាំ២០០៥
- ការឆ្លើយតបរបស់ជនជាតិដើមភាគតិច ទៅនឹងការថយចុះនៃធនធានធម្មជាតិៈ ការសិក្សាស្រាវជ្រាវ នៅ ក្នុងភូមិពីររបស់ជនជាតិស្ទៀង នៅស្រុកស្នួល ខេត្តក្រចេះៈ ខែធ្នូ ឆ្នាំ២០០៤

- ការប្រើប្រាស់គ្រឿងញៀនជាបញ្ហាសង្គមៈ ទស្សនៈរបស់ប្រជាជននៅក្នុងភូមិបី នៅជាយក្រុងបាត់ដំបងៈ ខែមេសា ឆ្នាំ២០០៤
- បទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ ក្នុងការលើកកំពស់ការចូលរួមអភិបាលកិច្ចមូលដ្ឋានៈ ការសិក្សាពីឃុំចំនួន៩ៈ ខែមីនា ឆ្នាំ២០០៤
- ការចេញទៅប្រកបការងារនៅប្រទេសថៃ និងព្រំដែនកម្ពុជា-ថៃ និន្នាការនាពេលបច្ចុប្បន្ន នៅភូមិចំនួន៤ ក្នុងខេត្តបាត់ដំបងៈ ខែធ្នូ ឆ្នាំ២០០៣
- ផលប៉ះពាល់នៃឧស្សាហកម្មទេសចរណ៍ មកលើជីវភាពរស់នៅរបស់ប្រជាជន នៅខេត្តសៀមរាប តំបន់ឧទ្យានអង្គរៈ ខែធ្នូ ឆ្នាំ២០០២
- ការសិក្សាខ្នាតតូច ស្តីពីការបែងចែកដីធ្លី នៅប្រទេសកម្ពុជាៈ ចំនុចសំខាន់៧ដែលទទួលបានពីករណីសិក្សាចំនួន៣ៈ ខែវិច្ឆិកា ឆ្នាំ២០០១

## ទស្សនវិស័យ:

សង្គមស៊ីវិលមួយដែលមានការសហការដ៏រឹងមាំ និងមានសមត្ថភាព ឆ្លើយតបទៅនឹងបញ្ហានៃ ការអភិវឌ្ឍន៍នៅកម្ពុជា ។

## បេសកកម្ម:

ក្នុងឋានៈជាសមាគមនដែលមានវិជ្ជាជីវៈមួយនៃអង្គការមិនមែន រដ្ឋាភិបាលនៅកម្ពុជា គណៈកម្មាធិការសហប្រតិបត្តិការដើម្បី កម្ពុជាផ្តល់សេវាកម្មប្រកបដោយគុណភាពខ្ពស់ជូនដល់សង្គម ស៊ីវិល និង បង្ករលក្ខណៈ អោយមានឥទ្ធិពលដល់ដៃគូអភិវឌ្ឍន៍នៃ ប្រទេស កម្ពុជា យើង ។

## គុណតំលៃ:

- សុច្ចរិតភាព
- កិច្ចសហប្រតិបត្តិការ
- ភាពឆ្លើយតប
- គុណភាព

eed Evangelischer Entwicklungsdienst

Broederlijk Delen omdat het zuiden plannen heeft

TROCAIRE Working for a Just World

樂施會 Oxfam Hong Kong

DanChurchAid christian aid JOINT PROGRAMME

esp ecumenical scholarships programme


ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ ទួលទំពូង ១ ខណ្ឌ ចំការមន
ប្រអប់សំបុត្រលេខ: ៨៨៥ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ១៥២/ ២១៦ ០០៩
ទូរសារលេខ: (៨៥៥-២៣) ២១៦ ០០៩
អ៊ីមែល: info@ccc-cambodia.org
គេហទំព័រ: www.ccc-cambodia.org



9 789995 080464